ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



## មជ្ឈមណ្ឌល ឯកសារខេត្តព្រៃវែង

- ការបង្កើត និងការអនុវត្តសកម្មភាពការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង
- ឯកអគ្គរាជទូតអង់គ្លេស លោកស្រី ឌីណា វ៉េជស ទស្សនាសំណង់ចេតិយសំណង និម្មិតរូប និងផ្ទាំងពាក្យស្លោករំឭកពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខពិសេស ឆ្នាំ២០២៤

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

លេខពិសេស ឆ្នាំ២០២៤



សុខ ថា គឺជាកម្មាភិបាលខ្មែរក្រហម ដែលបានចុះចូលជាមួយរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ក្នុងឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា/ភ្នាក់ងារសារព័ត៌មានវៀតណាម)

### មាតិកា

### ផ្នែកសំបុត្រ


- ការបង្កើត និងការអនុវត្តសកម្មភាពការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង................ ១


### ផ្នែកឯកសារ


- គុយ យ៉ុន គណៈយោធាស្រុកត្របែក ......... ៤
- សួស ណាន ហៅ ទេព ណាន គណៈ ............ ៧


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- ឯកអគ្គរាជទូតអង់គ្លេស លោកស្រី ធីណា រ៉េដស ទស្សនាសំណង់ចេតិយសំណាង ........ ៩
- រមណីយដ្ឋានសត្វស្លាបធម្មជាតិទួលព័ន្ធតាឡី.. ១៣
- វត្តរោងដំរី..................................... ១៦
- ស្រី សំអាង៖ អតីតពេទ្យយោធាតំបន់២០.. ១៨
- សុខ រី ៖ ប្រធានក្រុមដឹកនាំប្រជាជនក្នុងភូមិ ..២០
- ប៉ុល ខន ៖ ជាងសាងសង់ផ្ទះ ............... ២២
- អ៊ុច ហាំ ៖ ប្រជាជនក្នុងភូមិរើសអើង........ ២៤
- យ៉ាន់ វ៉ាន់ ៖ អ្នកគ្រប់គ្រងកន្លែងធ្វើប្រហុក.. ២៦
- រស់ សៀត ៖ អតីតយុទ្ធនារីខ្មែរក្រហម .....២៨
- ប្រជាជនភូមិសំរោងវត្តហូបចុកគ្រប់គ្រាន់ ... ៣០
- សម្រេចចិត្តចូលបម្រើកងទ័ពព្រោះមិនចង់... ៣២
- យាន់ យួន ៖ កងសែងយុទ្ធជនខ្មែរក្រហម .. ៣៤
- ឈា សុខឿន៖ នារីពេទ្យឃុំសម័យខ្មែរ ..... ៣៦
- រស់ ទូច ៖ អតីតប្រធានក្រសួងវប្បធម៌ ..... ៣៩
- យ៉ុន យ៉ាង ៖ កងនេសាទ...................... ៤១


### ផ្នែកវេទិកាពិភាក្សាសាធារណៈ


- វេទិកាអប់រំសហគមន៍ស្ដីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) នៅវត្តពន្លៃ .. ៤៣
- យុវជនជំនាន់ក្រោយយល់ដឹងកាន់តែច្បាស់អំពីការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅរបស់ខ្មែរ...៤៧
- សិស្សវិទ្យាល័យមេសាង ចូលរួមបណ្ដុះបណ្ដាលកិច្ចការស្រាវជ្រាវអំពីប្រវត្តិសាស្ត្រកម្ពុជា ... ៥០


### ផ្នែកស្រាវជ្រាវរកគ្រួសារ


- បងស្រី ប្រាក់ អឿន និងប្ដីរួមទាំងកូនៗ .... ៥៨
- បងប្អូនខ្ញុំចំនួន៤នាក់ ដែលចូលធ្វើបដិវត្តន៍ខ្មែរក្រហមបានស្លាប់ និងបាត់ខ្លួន.............. ៦០



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ៣៧៥ព.មប្រក

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ ៖** ផេង ពង្សរ៉ាស៊ី, ដា៉រដ្ឋ មេត្តា, ដាត ចាន់សុនិតា, សោម ប៊ុនថន, ភា រស្មី, ថុន ស្រីពេជ្រ និង សេន ពន្លឺ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** មីន សាណាស់ **អ្នកបកប្រែ៖** លឹម អ៊ុភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដា៉រដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង



Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# ការបង្កើត និងការអនុវត្តសកម្មភាពការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

ផេង ពង្សរ៉ាស៊ី



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទស្សនកិច្ចនៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ស្ថិតនៅភូមិទី៣ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រជាជនកម្ពុជាយ៉ាងហោចណាស់១.៧ លាននាក់បានស្លាប់ និងជាច្រើននាក់ផ្សេងទៀត ទទួលរងការឈឺចាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យគ្រប់គ្រងដោយ ប៉ុល ពត។ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ខ្មែរក្រហមបានអនុវត្តរបបកុម្មុយនីស្តផ្តាច់ការ ដែលបានផ្លាស់ប្តូរសង្គមកម្ពុជាលើគ្រប់វិស័យ ទាំងការបំផ្លាញវប្បធម៌ ប្រពៃណី ភាសា សម្លាប់អ្នកចេះដឹង និងប្រែក្លាយប្រទេសឲ្យទៅជាប្រទេសសេដ្ឋកិច្ចកសិកម្មដ៏មហិមាមួយ។ បដិវត្តន៍បាននាំមកនូវការសម្លាប់ ធ្វើការហួសកម្លាំង អត់អាហារ កើតមានជំងឺដង្កាត់ និងការបែកបាក់គ្រួសារ។ ជនឧក្រិដ្ឋនៃអំពើប្រល័យពូជសាសន៍គឺជាកម្មាភិបាលជាន់ខ្ពស់ដូចជា ប៉ុល ពត និងអ្នកនយោបាយកំពូលៗដទៃទៀត ដែលបានអនុវត្តការដឹកនាំដ៏តឹងរ៉ឹងជាសម្ងាត់មួយ។ ខេត្តព្រៃវែង គឺជាខេត្តមួយដែលក្រុមកុម្មុយនីស្តខ្មែរក្រហមគ្រប់គ្រងមុនគេ។ ខេត្តនេះមានដង់ស៊ីតេប្រជាជនខ្ពស់ដែលទទួលរងការគាបសង្កត់ពីអំពើឃោរឃៅរបស់ខ្មែរក្រហម។ ការជាប់ទាក់ទងគ្នារវាងសង្គ្រាមអាមេរិកនិងវៀតណាម និងការលុកលុយផ្នែកយោធា បានបង្កឲ្យមានការឈឺចាប់យ៉ាងធ្ងន់ធ្ងរដល់ប្រជាជន។ ក្រៅពីការសម្លាប់ និងជម្លៀសដោយបង្ខំ សោ ភឹម គឺជាមេបញ្ជាការជាន់ខ្ពស់ក្នុងភូមិភាគបូព៌ា បានអនុវត្តផែនការកំណែទម្រង់កសិកម្មដែលបង្កឲ្យមានផលប៉ះ

ពាល់យ៉ាងខ្លាំងក្នុងអំឡុងឆ្នាំ១៩៧៧។ សោ ភឹម បានធ្វើអត្តឃាតនៅក្នុងឆ្នាំ១៩៧៨ នៅពេលដែលគាត់មានជម្លោះជាមួយអង្គការ។

## អំពីមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជានៅខែមករា ឆ្នាំ២០១៨ នៅក្នុងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តព្រៃវែង តាមសេចក្តីប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ២៧៣១ អយក.រប ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការអនុញ្ញាតិឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រើប្រាស់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៦ ធ្វើជាការិយាល័យធ្វើការ ដើម្បីគម្រោងសំណាងដែលមានឈ្មោះថា«ការទទួលបាន និងការចែករំលែកព័ត៌មានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងក្រុមគ្រួសារ។ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៧ កិច្ចពិភាក្សាផ្លូវការរវាងលោកជំទាវ ទន់ សាអ៊ឹម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា, លោក ប៊ួយ វុទ្ធី នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តព្រៃវែង និងតំណាងមជ្ឈមណ្ឌលឯកសារកម្ពុជា បានចាប់ផ្តើមពិភាក្សាពីដំណើរការកែលម្អអគារការិយាល័យ បំពាក់គ្រឿងសង្ហារឹម និងសម្ភារការិយាល័យ និងការរៀបចំផែនការគម្រោងដែលនឹងត្រូវអនុវត្តសម្រាប់ដំណើរ-ការរបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ ស្ថិតក្រោមជំនួយទ្រទ្រង់ពីសហភាពអឺរ៉ុប តាមរយៈការិយាល័យអង្គការសហប្រជាជាតិសម្រាប់សេវាគម្រោង និងទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ត្រូវបានដាក់សម្ពោធឲ្យប្រើប្រាស់ជាផ្លូវការក្រោមអធិបតីភាពលោកជំទាវ ទន់ សាអ៊ឹម តំណាងដ៏ខ្ពង់ខ្ពស់របស់ក្រសួងអប់រំ យុវជននិងកីឡា។ បច្ចុប្បន្នមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង មានទីតាំងស្ថិតនៅផ្ទះលេខ១៧១ ភូមិលេខ៣ សង្កាត់កំពង់លាវ ក្រុងព្រៃវែង និងខេត្តព្រៃវែង។

## បេសកកម្មរបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង គឺជាបណ្ណាល័យតម្កល់ឯកសារខ្មែរក្រហម កន្លែងស្រាវជ្រាវ និងតាំងពិព័រណ៌ពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងការចងចាំជារួមអំពីប្រវត្តិ-សាស្ត្រខ្មែរក្រហម តាមរយៈការអប់រំ និងផ្សព្វផ្សាយពីប្រវត្តិសាស្ត្រខ្មែរក្រហមដល់យុវជនជំនាន់ក្រោយ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅតាមសាលារៀន និងសហគមន៍។ ដូច្នេះ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង មានគោលបំណងថែរក្សា អប់រំ និងចែកចាយព័ត៌មានជាសាធារណៈអំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, លើកកម្ពស់ការផ្សះផ្សា និងការសន្ទនាអន្តរជំនាន់អំពីប្រវត្តិ-សាស្ត្រខ្មែរក្រហម, និងបង្កើនការស្រាវជ្រាវ និងចងក្រងឯកសារពីប្រវត្តិសាស្ត្រខ្មែរក្រហមដើម្បីការចងចាំ និងទប់ស្កាត់ការកកើតអំពើប្រល័យពូជសាសន៍នាពេលអនាគត។

## សកម្មភាពការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

ដើម្បីបម្រើដល់បេសកកម្ម និងគោលបំណងដែលបានកំណត់ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានបង្កើតគម្រោងមួយចំនួនទាក់ទងនឹងការអប់រំ ស្រាវជ្រាវ និងផ្សព្វផ្សាយជាសាធារណៈពីប្រវត្តិ-សាស្ត្រខ្មែរក្រហម ដូចជា៖ វេទិកាថ្នាក់រៀនជាមួយសិស្សានុសិស្សកម្រិតវិទ្យាល័យ, វេទិកាប្រវត្តិសាស្ត្រផ្ទាល់មាត់ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម, វេទិកាអប់រំសហគមន៍ជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងក្មេងជំនាន់ក្រោយ, តាំងពិព័រណ៌អចិន្ត្រៃយ៍ពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម, វគ្គបណ្តុះបណ្តាលគ្រូបង្រៀនពីប្រវត្តិសាស្ត្រខ្មែរក្រហម, ប្រវត្តិសាស្ត្រតាមភូមិ និងផ្សព្វផ្សាយពីប្រវត្តិសាស្ត្រខ្មែរក្រហមតាមវិទ្យុ ទូរទស្សន៍បណ្តាញសង្គម កាសែត ទស្សនាវដ្តី និងគេហទំព័រផ្សេងៗ។

## លទ្ធផលរំពឹងទុកពីការអនុវត្តសកម្មភាពគម្រោង

ជារៀងរាល់ឆ្នាំ មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងនឹងអនុវត្តសកម្មភាពគម្រោងទាំងអស់ដែលបានកំណត់នៅក្នុងផែនការការងាររបស់ខ្លួនមិនដែលអាក់ខានឡើយ ទោះបីជាស្ថិតនៅក្នុងអំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ១៩ក៏ដោយ។ ផែនការជាយុទ្ធសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងបានកំណត់ថា យ៉ាងហោចណាស់សិស្សានុសិស្សចំនួនពី៣៥០ទៅ៥០០នាក់ បានទទួលការអប់រំពីប្រវត្តិសាស្ត្រខ្មែរក្រហម ហើយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រមាណពី២០០ទៅ ៣០០នាក់ ត្រូវបានជួប និងសម្ភាសន៍ពីបទពិសោធន៍ឆ្លងកាត់របបខ្មែរក្រហមដោយបុគ្គលិក និងអ្នកស្ម័គ្រចិត្តរបស់មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ លើសពីនេះទៅទៀត យ៉ាងហោចណាស់មានអ្នករស់រានមានជីវិតឯទៀតចំនួនពី ១០០ ទៅ ១៥០នាក់ ត្រូវបានលើកទឹកចិត្តឲ្យនិយាយរឿងរ៉ាវជីវិតរបស់ខ្លួនឆ្លងកាត់របបខ្មែរក្រហម ប្រាប់ដល់សិស្សានុសិស្សដែលត្រូវជាចៅ ឬចៅទួតរបស់ខ្លួន នៅក្នុងកម្មវិធីស្តីពីការសន្ទនាអន្តរជំនាន់ដែលត្រូវបានរៀបចំឡើងនៅតាមសហគមន៍នីមួយៗ។



ក្រុមការងាររមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងរៀបចំវេទិកាអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងសុខភាពដល់ប្រជាជននៅតាមសហគមន៍ស្ថិតនៅក្នុងស្រុកកំចាយមារ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# គុយ យ៉ុន គណៈយោធាស្រុកត្រាំកក់

ជាវ៉ាវដ្ឋ មេត្តា



កងយោធាខ្មែរក្រហម។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំមានឈ្មោះដើម គុយ យ៉ុន និងឈ្មោះក្នុងជួរបដិវត្តន៍ គុយ សាវ៉ាន ភេទប្រុស អាយុ៣៦ឆ្នាំ (នៅឆ្នាំ១៩៧៦)។ ខ្ញុំមានស្រុកកំណើតនៅភូមិព្រៃស្នាំង ឃុំពញាលៀង ស្រុកព្រះស្តេច ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ គុយ យ៉ាន ស្លាប់នៅក្នុងឆ្នាំ១៩៦៨ និងម្តាយខ្ញុំឈ្មោះ ព្រំ ប៊ុ។ ខ្ញុំមានបងប្អូនបង្កើតទាំងអស់ចំនួន៨នាក់ និងបានចូលបម្រើបដិវត្តន៍ចំនួន៧នាក់។ បងទី១) គុយ យុន ក្រោយមកធ្វើជាលេខាឃុំរាធរ ស្រុកកោះដ័យ, ទី២) ខ្ញុំ (គុយ យ៉ុន) ទី៣) គុយ ឈុន គឺជាបុគ្គលិកវប្បធម៌, ទី៤) គុយ នៅ គឺជាពេទ្យឃុំពញាលៀង២, ៥) គុយ នាត នៅអង្គភាពឃុំរាធរ, ៦) គុយ ណា អង្គភាពវប្បធម៌, ៧) គុយ ហ៊ាន ពេទ្យតំបន់២៤ និង ទី៨) ប្អូនពៅរស់នៅជាមួយម្តាយ។

នៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៥ អង្គការបានរៀបចំឲ្យខ្ញុំមានប្រពន្ធឈ្មោះ ឡុង ខឿន អាយុ២៣ឆ្នាំ គឺប្រជាជននៅស្រុកកោះដ័យ ខេត្តព្រៃវែង។ ប្រពន្ធរបស់ខ្ញុំធ្វើការនៅក្នុងអង្គភាពសេដ្ឋកិច្ច ស្រុកត្រាំកក់ ផ្នែកកាត់ដេរ។

នៅពេលដែលខ្ញុំមានអាយុ៥ឆ្នាំ ឪពុកម្តាយខ្ញុំបានមករស់នៅក្នុងភូមិស្នាយព្រីមដែលជាស្រុកកំណើតខាងម្តាយ។ មូលហេតុដែលគ្រួសារខ្ញុំមករស់នៅភូមិស្នាយព្រីមវិញដោយសារមានវៀតណាមបះបោរកាប់សម្លាប់ ឆក់ប្លន់ប្រជាជននៅក្នុងភូមិ។ នៅពេលខ្ញុំអាយុ១១ឆ្នាំ គ្រួសារខ្ញុំត្រឡប់មករស់នៅក្នុងភូមិស្នាំងវិញ។ ពេលខ្ញុំមានអាយុ១៦ឆ្នាំ ឪពុកម្តាយខ្ញុំនាំខ្ញុំមកនៅវត្តថ្មីស្ថិតនៅឃុំពញាលៀង២។ ក្រោយមកខ្ញុំបួសជានេនបានរយៈពេល១ឆ្នាំ និងបួសជាភិក្ខុបានរយៈពេល២ឆ្នាំ។ នៅឆ្នាំ១៩៦៧ ខ្ញុំទៅប្រឡងយកសញ្ញាបត្រសាលាបាលីរង នៅក្នុងក្រុងព្រៃវែង ហើយខ្ញុំប្រឡងជាប់ និងទទួលបានសញ្ញាបត្រ។ បន្ទាប់ពីប្រឡងរួច ខ្ញុំបានមកស្នាក់នៅក្នុងវត្តថ្មីបានរយៈពេល១ខែ ទើបខ្ញុំមករស់នៅវត្តទួលសាំង ស្ថិតនៅក្នុងឃុំកោះរកា ស្រុកពាមជរ ខេត្តព្រៃវែង។

នៅក្នុងឆ្នាំ១៩៦៨ ខ្ញុំបានសឹកនិងមករស់នៅផ្ទះបានរយៈពេល២ខែ។ ដោយជីវភាពគ្រួសារមានការខ្វះខាត ខ្ញុំបានមករស់នៅជាមួយប្រជាជនដែលមានផ្ទះនៅក្បែរវត្តទួលសាំង។ គាត់ធ្លាប់រស់នៅជាមួយខ្ញុំកាលខ្ញុំបួសជាសង្ឃ។ ខ្ញុំបានរស់នៅជាមួយគាត់និងធ្វើស្រែចម្ការ ដាំសណ្តែក ល្ង ពោត ដោយមានការជួយពីអ្នកភូមិជិតខាង ដូចជា ផ្តល់ដីស្រែឲ្យធ្វើ ផ្តល់កម្លាំងសត្វគោ និងក្របីឲ្យភ្ជួររាស់។ ក្រោយមកឪពុកមាខ្ញុំឈ្មោះ គុយ សាន់ បានទិញមងខ្លាតតូចឲ្យខ្ញុំទុកនេសាទត្រី។ ក្នុងរយៈពេលដែលខ្ញុំប្រកបមុខរបរនេសាទត្រី ខ្ញុំទទួលបានការអប់រំជាបណ្តើរៗពីបងធុច គឺជាលេខាតំបន់២៣ និង បងភន បច្ចុប្បន្នគឺនៅអង្គភាពកសិកម្មតំបន់២៤ ដោយសារបងទាំងពីរនេះរស់នៅភូមិព្រៃស្វាំងជាមួយខ្ញុំ។

នៅខែកុម្ភៈ ឆ្នាំ១៩៦៩ ខ្ញុំចូលបដិវត្តន៍នៅភូមិព្រៃស្វាំង ដោយមានបងភនជាអ្នកនាំចូល និង បងធុច គឺជាអ្នកទទួលស្គាល់។ ក្រោយពីខ្ញុំចូលបដិវត្តន៍ ខ្ញុំក៏ចូលនៅក្នុងចលនាយុវជនយុវនារីពាភូមិ គឺភូមិក្រសាំងទង ភូមិព្រៃស្វាំង និងភូមិទឹកជូរ។ ខ្ញុំមានតួនាទីជាអនុប្រធានសាខាយុវជនឃុំពញាលៀង និងជាទីស្តីការភូមិព្រៃស្វាំង។ នៅខែកុម្ភៈ ឆ្នាំ១៩៧០ ខ្ញុំចូលអង្គការដោយក្លាយជាសមាជិកយុវកកដោយមានសមិត្ត ខាំ សុខ គឺជាអ្នកខទ្ទេនាម និងសមមិត្តម៉ុង គឺជាអ្នកទទួលស្គាល់។ ខ្ញុំចូលជាសមាជិកអង្គការបន្តទៀតគឺចូលបក្សនៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៧០ នៅអង្គភាពស្រុកត្របែក ដោយមានសមមិត្តសុខសានអ្នកខទ្ទេសនាមទី១, សមមិត្តចាន់ថនអ្នកខទ្ទសនាមទី២ និងសមមិត្តជ័យ សារិន គឺជាអ្នកទទួលស្គាល់។

រិន គឺជាលេខាស្រុកកំពង់ត្របែក អប់រំខ្ញុំចាប់តាំងពីឆ្នាំ១៩៧៣ និង១៩៧៤ ដោយមានវិធីពីរយ៉ាងគឺអប់រំស្របច្បាប់ គឺឲ្យខិតខំពង្រឹងកម្លាំងបក្សដើម្បីពង្រឹងការអប់រំដឹកនាំក្នុងអង្គភាព ប៉ុន្តែខ្លឹមសារមិនមែនផ្អែកលើមាគ៌ាវណ្ណៈរបស់បក្សដោយជ្រើសរើសយកសភាពមិនល្អ ដូចជា សមាសភាពសេរី ភ្ញើតភ្ញើនពាក់ព័ន្ធនិន្នាការនយោបាយខ្លាំង និងពាលាអាវ៉ាសែ។ មួយផ្នែកទៀតគឺអប់រំចំហ ដោយលើកឡើងថា នៅប្រទេសវៀតណាមគេមិនខ្វះអ្វីទេ ហើយសម្បូរសប្បាយមានតាំងពីបៀរ អាប៉ោង រហូតដល់វៀតណាមរំដោះ ហើយនៅតែមានល្បែងស៊ីសងស្រីស្រាពេញប្រទេសរបបនាយទុន និងឯកជនក៏មានដែរ។ ឯប្រទេសកម្ពុជាយើងខ្វះខាតច្រើនណាស់។ រិន អប់រំនិងមានវិធានការឲ្យខ្ញុំទៅ ទប់ទឹកទុករហូតធ្វើឲ្យលិចសន្ទូងរលួយសំណាប ដំណាំដាំដុះ លិចផ្ទះសម្បែងរបស់ប្រជាជនមូលដ្ឋាននៅក្នុងឆ្នាំ១៩៧៥។ រិនឲ្យខ្ញុំទៅបើកទឹកបង្ហូរចេញពីប្រឡាយធំឲ្យអស់ពីស្រែហើយគាត់នឹងបញ្ចូលទឹកថ្វាចូលវិញ ប៉ុន្តែមិនឃើញបញ្ចូលទេ ធ្វើឲ្យសន្ទូងខូចអស់។ រិនចាត់តាំងឲ្យខ្ញុំធ្វើការពិនិត្យតាមដានផ្ទៃក្នុងគណៈស្រុក ហើយរាយការណ៍ឲ្យគាត់វិញ ព្រោះគាត់ខ្លាចក្នុងគណៈស្រុកមានគោលបំណងអ្វីផ្សេងមិនល្អចំពោះគាត់។ រិន មានផែនការឲ្យខ្ញុំដាក់ឈ្លបតាមព្រំដែនរាយចម្រូងបន្តិចបន្តួចត្រង់កន្លែងណាដែលសំខាន់ប៉ុណ្ណោះ ហើយឲ្យខ្ញុំយកមីនចេញពីខ្សែបន្ទាត់ព្រំដែន។ ប្រសិនបើឃើញវៀតណាមចូលមកក្នុងទឹកដីខ្មែរឲ្យខ្ញុំបាញ់យ៉ាងណាធ្វើឲ្យខុសឲ្យខូចនយោបាយបដិវត្តន៍។ រិន ប្រាប់ខ្ញុំឲ្យបន្ថយរបបអាហារនៅក្នុងអង្គភាពដើម្បីសន្សំសំចៃត្រៀមទុកពេលខ្វះខាតទៅថ្ងៃមុខ។ ប៉ុន្តែគោលបំណងយុទ្ធសាស្ត្រគឺដើម្បីឲ្យយុទ្ធជនហូបមិនគ្រប់គ្រាន់ និងតឹងតែងលើបញ្ហាហូបចុក។ កន្លងមក លើការស្លៀកពាក់ក៏មានការកាត់បន្ថយដែរ គឺខ្ញុំមិនដែលបើកសម្លៀកបំពាក់បានគ្រប់មុងណាទេ រហូតដល់មានការលើកឡើងថា «ធ្វើបដិវត្តន៍ស្លៀកពាក់ដូចឈ្លើយសឹក» ហើយអនុញ្ញាតឲ្យមានគ្រួសារបង្កឲ្យមានភាពគគ្រឹកគគ្រេង រហូតដល់មានសភាពខុសសីលធម៌ទី៦ កើតមានឡើងនៅក្នុងអង្គភាព។ ក្រោយមក ខ្ញុំបានយកទៅអនុវត្តជាក់ស្តែងដោយបានយកទៅផ្សព្វផ្សាយដល់យុទ្ធជននិងកម្មាភិបាលថ្នាក់ក្រោម។ នៅពេលដែលខាងក្រោមអនុវត្តមិនបាន ខ្ញុំបញ្ចេញអាកប្បកិរិយាអាជ្ញាសម្តុត គំរាមកំហែង។ ចលនាក្បត់នេះមានឈ្មោះថា ចលនាសេរីនិយមដែលយកសមាសភាពជាប់

និន្នាការសង្គមចាស់ជាមេភូមិ មេកង ប៉ូលិស ទាហាន សមាសភាពពាលាអាវ៉ាសែ សម្ងំសុខធ្វើជាខ្នងបង្អែក។ ចលនាសេរីនិយមនេះបានកើតឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៥ នៅពេលដែលរិនបានអប់រំខ្ញុំហើយដើមកំណើតដំបូងខ្ញុំមិនបានដឹងពិតប្រាកដទេ។ ម្យ៉ាងទៀតចលនានេះមានការគាំទ្រពីប្រទេសសូវៀត និងប្រទេសវៀតណាម ទាំងផ្លូវចិត្ត និងសម្ភារ តាមរយៈគណៈទាក់ទងវៀតណាមឈ្មោះ ប៉ែម៉ាន ។ ជំនួយដែលវៀតណាមបានផ្តល់ឲ្យមកខ្ញុំមាន ដូចជា អាអ៊ែ ១៥ ចំនួន៧៥ដើម, សេកាសេ ចំនួន៤០ដើម, អឹម៣០ ចំនួន៤ដើម, កាំភ្លើងត្បាល់៦០មីលីម៉ែត្រ ចំនួន៣ដើម, បេ៤០ ចំនួន ២ដើម, អឹម៧៩ ចំនួន៦ដើម, កា៥៤ និងអាបេ ចំនួន១២ដើម, ថ្នាំពេទ្យ៣ធុង ដោយមានបណ្តោយកន្លះម៉ែត្រ ទទឹង៣តឹក និងកម្ពស់៤តឹក។ សម្ភារទាំងអស់នេះគឺយោធាស្រុកកំពង់ត្របែកជាអ្នកទទួលពី ប៉ែម៉ាន នៅផ្សារពាមបន្ទារ នៅខែតុលា ឆ្នាំ១៩៧៥ ហើយអាវុធនិងសម្ភារទាំងអស់នេះ យើងមិនទាន់បានយកមកប្រើប្រាស់ទេ។ ផែនការក្បត់នេះមានទិសដៅវាយរំលំរដ្ឋអំណាចដណ្តើមអំណាចមកគ្រប់គ្រង និងចាត់ចែងតាមសេរីនិយម។ ក្រោយមកខ្ញុំត្រូវអង្គការចាប់ខ្លួន និងយកមកសួរចម្លើយនៅថ្ងៃទី២ ខែតុលា ឆ្នាំ១៩៧៦។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីសេចក្តីកត់ហេតុសួរចម្លើយឯកសារ J00២៥៥។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខ ស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ គុយ យ៉ុន ពិតប្ុយ៉ាងណានោះទេ?**



យោធាខ្មែរក្រហមនៅសមរភូមិ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សួស ណាន ហៅ ទេព ណាន គណៈស្រុកពាមជរ

ផាត ចាន់សុនិតា



កងចល័តនារី នៅភូមិភាគបូព៌ាកំពុងប្រមូលចំបើងៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៧៦ ក្រសួងសន្តិសុខតំបន់២១រួមមានសមមិត្តភី (ប្រធានសួរចម្លើយ), សមមិត្តម៉ុន (អ្នកកត់ត្រា) និង សុភ័ន (កងការពារ) បានសួរចម្លើយទៅលើអ្នកទោសមកពីភូមិភាគបូព៌ាម្នាក់ឈ្មោះ សួស ណាន ដែលអង្គការចោទថាក្បត់ៗ នៅចំពោះមុខអ្នកសួរចម្លើយ សួស ណាន បានសារភាពដូចខាងក្រោម ៖

ខ្ញុំឈ្មោះ សួស ណាន ឈ្មោះបដិវត្តន៍ ទេព ណាន ភេទប្រុស អាយុ៣៣ឆ្នាំ (នៅឆ្នាំ១៩៧៦)។ ខ្ញុំមានស្រុកកំណើតនៅភូមិ ត្រាច ឃុំដូនសរ ស្រុកមានជ័យថ្មី តំបន់២៨។ ឪពុករបស់ខ្ញុំឈ្មោះ សួស ហង់ និងម្តាយឈ្មោះ ប៉ោក ទូច។ ខ្ញុំមានបងប្អូនបង្កើតចំនួន ៩នាក់ ស្រី៥នាក់ និងប្រុស៤នាក់ៗ ក្រុមគ្រួសាររបស់ខ្ញុំស្ថិតក្នុងវណ្ណៈកសិករថ្នាក់កណ្តាលប្រកបមុខរបរធ្វើស្រែ។ ខ្ញុំមានកម្រិតវប្បធម៌កាលពីសង្គមចាស់រៀនដល់ថ្នាក់ទី២។ ខ្ញុំបានចូលរៀនជាមួយបដិវត្តន៍ ចំនួន៧វគ្គ ដូចជារៀននៅសាលាយោធាភូមិភាគ និងរៀននៅសាលានយោបាយ។ តាំងពីដើមមក ខ្ញុំពុំដែលធ្វើជាទាហានប៉ូលិសទេ ប៉ុន្តែខ្ញុំធ្លាប់បានចូលនិន្នាការនយោបាយជាមួយសង្គមរាស្ត្រនិយម។

ខ្ញុំបានចូលបដិវត្តន៍នៅសាលាកម្ពុជបុត្រដែលមានទីតាំងស្ថិតនៅទួលគោក, រាជធានីភ្នំពេញ ក្នុងឆ្នាំ១៩៦២ តាមរយៈសមមិត្ត វង់ ឈ្មោះបដិវត្តន៍ ឈូក បច្ចុប្បន្នជាលេខាតំបន់២៤។ បន្ទាប់ពីចូលបដិវត្តន៍ខ្ញុំទទួលបានតំណែងជាបន្តបន្ទាប់។ នៅឆ្នាំ១៩៦២ ដដែល ខ្ញុំមានតួនាទីជាអ្នកដឹកនាំសិស្សនៅក្នុងសាលាកម្ពុជបុត្រ។ ក្រោយមក សមមិត្ត ឈូក បានខទ្ទេសនាមខ្ញុំចូលជាសមាជិកបក្សត្រៀមនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៦៩ និងក្លាយជាសមាជិកពេញសិទ្ធិនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧០។ បន្ទាប់ពីចូលបក្សជនពេញសិទ្ធិហើយ ខ្ញុំបានទៅនៅជាមួយសមមិត្ត គឹម ឡាក់ ធ្វើជាលេខាស្រុកព្រៃវែង។ ក្រោយមក សមមិត្ត ណាំ សានបានចាត់តាំងខ្ញុំឲ្យធ្វើជាលេខាយោធាតំបន់២៣។ នៅឆ្នាំ១៩៧១ ខ្ញុំធ្វើជាប្រធានសេនាធិការតំបន់២៤។ នៅឆ្នាំ១៩៧២ ខ្ញុំមានតួនាទីជាប្រធានយ២ តំបន់២៤។ រហូតដល់ឆ្នាំ១៩៧៣ អង្គការបានចាត់តាំងខ្ញុំឲ្យធ្វើជាអនុលេខាស្រុកពាមជរ។

ចំពោះសកម្មភាពគស៊ូរបស់ខ្ញុំក្នុងរយៈកាលកន្លងមកចាប់តាំងពីឆ្នាំ១៩៦២ ដល់ ឆ្នាំ១៩៧០ ខ្ញុំចូលបម្រើខ្លាំងមានភារកិច្ចជាអ្នកយាមសាលា, យាមក្រុង, ចាំចាប់ខ្មែរក្រហមបាចខិតប័ណ្ណ។ លុះដល់ក្រោយឆ្នាំ១៩៧០ ខ្ញុំបានចូលបម្រើក្នុងចលនាមួយឈ្មោះ ចលនាសេរីរី ក្រោមការដឹកនាំរបស់ឈ្មោះ ឈូក គឺជាអ្នកទទួលខុសត្រូវរួមក្នុងប្រទេសដែលមានឋានៈពាក់ផ្កាយ៣, ចក្រី គឺជាប្រធានយោធារួមក្នុងប្រទេស ដែលមានឋានៈពាក់ផ្កាយ២ និង សុផាន ពាក់ផ្កាយ១។ ខ្ញុំដឹងច្បាស់ថា ចលនានេះមានការលម្អៀងស្តាំជ្រើសយកជនកុម្មុយនីស្តកណ្តាល និងកុម្មុយនីស្តសេរីរីក្នុងប្រទេសធ្វើជាកម្លាំងយុទ្ធសាស្ត្រ និងជ្រើសយកមូលដ្ឋានបង្អែកមានសូវៀត, ឆេកូស្លូវ៉ាគី, ប៉ូឡូញ, គុយបា និងជាពិសេសវៀតណាម។ ចលនាសេរីរីមានទិសដៅយុទ្ធសាស្ត្រគឺ ទី១) ត្រូវកសាងកម្លាំងយកចិត្តទុកដាក់ក្នុងអង្គភាពក្រសួងមូលដ្ឋានដែលមានការទុកចិត្ត មានជំហរកណ្តាល និងជំហរសេរីរី។ ទី២) ត្រូវប្រមូលស្បៀង និងយកចិត្តទុកដាក់បង្កបង្កើនផលឲ្យបានច្រើនជាងគេ និងកសាងមូលដ្ឋានបង្អែកត្រៀមធ្វើសង្គ្រាមយូរអង្វែង។ ទី៣) ត្រូវប្រមូលអាវុធទុកហើយបញ្ជូនអាវុធមានវៀតណាមផ្តល់ជំនួយជាមូលដ្ឋាន។

ដើម្បីឈានទៅរកការសម្រេចទិសដៅជាយុទ្ធ-សាស្ត្ររបស់ចលនាសេរីរីមានការរៀបចំសកម្មភាពដូចជា៖ ខាងផ្នែកចាត់តាំងរួមមានសមមិត្ត ឈូក ទទួលបន្ទុកខាងក្នុងប្រទេស និង ទាក់ទងជាមួយវៀតណាម។ សមមិត្ត ចាន់ ចក្រី ទទួលបន្ទុកផ្នែកយោធាទូទាំងប្រទេស។ ចំណែកខាងផ្នែកនយោបាយមានខ្លឹមសារអប់រំចំនួនបីចំណុច គឺ៖ ១) កសាងកម្លាំងគ្រប់ផ្នែកឲ្យបានច្រើននៅក្នុងមូលដ្ឋាន និងអង្គភាពទាំងនយោបាយ និងសតិអារម្មណ៍។ ២) ត្រៀមលក្ខណៈសម្បត្តិដើម្បីតស៊ូយូរអង្វែង តាមរូបភាពសម្បូរបែបនិងឈ្លបៗ ៣) កសាងកម្លាំងបង្អែកសេដ្ឋកិច្ចឲ្យខ្លាំងក្លាបំផុត។ រីឯខាងផ្នែកសេដ្ឋ-កិច្ច គឺបំផុសមាគ៌ាសេដ្ឋកិច្ចរបស់បក្សឲ្យធ្វើឯកជន, បំផុសប្រជាជនឲ្យលួចគោក្របី, មាន់ទា, ជ្រូកលក់ឲ្យវៀតណាម។ ចំពោះផ្នែកវប្បធម៌ អូសទាញប្រជាជនឲ្យរៀបការតាមប្រពៃណីចាស់, ហាមមិនឲ្យប្រជាជនវាយរូបចម្លាក់អ្នកតា, លើកទឹកចិត្តប្រជាជនឲ្យស្លៀកសម្លៀកបំពាក់ស៊ីវិល័យ និងច្រៀងបទចម្រៀងឯកជនតាមបទពីដើមដោយមិនឲ្យច្រៀងអំពីសមូហភាព។

ខាងលើនេះគឺជាចម្លើយសារភាពរបស់ សួស ណាន ហៅ ទេព ណន ប្រាប់ទៅកាន់អ្នកសួរចម្លើយស្តីអំពីការរៀបចំសកម្មភាពក្បត់នឹងអង្គការ និងខ្សែបណ្តាញចលនាសេរីរីរបស់ ឈូក, ចក្រី និង សុផាន ដើម្បីបះបោរធ្វើសង្គ្រាមប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា។

**កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីសេចក្តីកត់ហេតុសួរចម្លើយឯកសារJ00៩២៤។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ សួស ណាន ហៅ ទេព ណន ពិតប្រាកដយ៉ាងណានោះទេ?**

# ឯកអគ្គរាជទូតអង់គ្លេស លោកស្រី ធីណា រ៉េដស ទស្សនាសំណង់ចេតិយសំណាងនិម្មិតរូប និង ផ្ទាំងពាក្យស្លោករំឭកពីការចងចាំប្រវត្តិសាស្ត្រខ្មែរក្រហម

ដេង ពង្សរ៉ាស៊ី



លោកស្រី ធីណា រ៉េដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា ថតរូបជុំគ្នាជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅចេតិយសំណាងនិម្មិតរូប «ទួលធាតុ» ស្ថិតនៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ជុន ស្រីពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

លោកស្រី ធីណា រ៉េដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា និងសហការីលោកស្រី គីរ៉ុទ្ធី សុកញ្ញា បានមកធ្វើទស្សនកិច្ចនៅទីតាំង «ទួលធាតុ» ស្ថិតនៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ជាកន្លែងដែលមជ្ឈមណ្ឌលឯកសារកម្ពុជាសាងសង់ចេតិយជាសំណាងសមូហភាពដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានសាច់ញាតិ បងប្អូន ស្លាប់ក្នុងរបបខ្មែរក្រហម និងសំណង់ផ្ទាំងពាក្យស្លោករំឭកពីការចងចាំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។

ដំណើរទស្សនកិច្ចរបស់លោកស្រី និងសហការី ត្រូវបានទទួលស្វាគមន៍ដោយលោកស្រី សូ ហ្វារីណា នាយិកាវងមជ្ឈមណ្ឌលឯកសារកម្ពុជា លោក ដេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និងបុគ្គលិក ព្រមទាំងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមប្រមាណ១០នាក់ នៅនឹងទីតាំងផ្ទាល់ នៅវេលាម៉ោង១០កន្លះ។ លោក ដេង ពង្សរ៉ាស៊ី បានជម្រាប



រូបដើរខាងមុខ លោកស្រី សូ ហ្វារីណា នាយករង មជ្ឈមណ្ឌលឯកសារកម្ពុជា និងលោកស្រី ធីណា វ៉េដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា ទៅទស្សនាសំណង់ចេតិយ សំណាងនិម្មិតរូប នៅទីតាំង «ទួលធាតុ» ស្ថិតនៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផុន ស្រីពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបទីមួយរាប់ពីឆ្វេង លោក ដេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា និង លោកស្រី ធីណា វ៉េដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា ទស្សនាសំណង់ចេតិយ សំណាងនិម្មិតរូប នៅទីតាំង «ទួលធាតុ» ស្ថិតនៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ (ផុន ស្រីពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ជូនលោកស្រីឯកអគ្គរាជទូត ពីការសាងសង់សំណង់ចេតិយ និងផ្ទាំងពាក្យស្លោក និងបុព្វហេតុដែលនាំឲ្យមានការសាងសង់សំណង់រឹងមាំទាំងពីរ ថាជាការស្នើសុំរបស់អាជ្ញាធរមូលដ្ឋានបន្ទាប់ពីមានការឯកភាពគ្នាជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលកំពុងរស់នៅក្នុងភូមិនានានៃឃុំចាម ស្រុកកំពង់ត្របែក សម្រាប់សំណាងនិម្មិតរូបក្រោយការបិទបញ្ចប់ដំណើរការរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម។ លោកស្រី សូ ហ្វារីណា បានប្រាប់ពីគម្រោងសំខាន់ៗមួយចំនួនដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបាន និងកំពុងអនុវត្តនៅក្នុងភូមិសាស្ត្រខេត្តព្រៃវែង ជាពិសេសនៅក្នុងស្រុកកំពង់ត្របែក រួមទាំងគម្រោងស្តីពីការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផង។

លោកស្រីឯកអគ្គរាជទូតបានជួបសំណេះសំណាលជាមួយអ្នកភូមិដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាអ្នកដែលបានយកអដ្ឋិធាតុសាច់ញាតិបងប្អូនដែលបានស្លាប់ក្នុងរបបខ្មែរក្រហម មកដាក់តម្កល់នៅក្នុងចេតិយ នៅក្រោមដើមត្នោតបីបួនដើម ស្ថិតនៅលើទីតាំងទួលធាតុ ក្បែរសំណង់ចេតិយ និងផ្ទាំងពាក្យស្លោក ដោយក្តីសោមនស្សរីករាយ និងភាពស្និទ្ធស្នាល។ ជាដំបូង លោកស្រីបានថ្លែងអំណរគុណចំពោះវត្តមានរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានចំណាយពេលវេលាមកទទួលស្វាគមន៍លោកស្រី។ លោកស្រី ក៏បានរំឭកដល់អ្នករស់រានមានជីវិតទាំងអស់ពីសារសំខាន់នៃការសាងសង់ចេតិយ និងផ្ទាំងពាក្យស្លោកនេះថា វាពិតជាបានបង្កើននូវការចងចាំ និងការផ្សះផ្សាជារួមមួយក្រោយតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ព្រមទាំងជាកន្លែងបង្រៀនយុវជនជំនាន់ក្រោយពីប្រវត្តិសាស្ត្រនេះទៀតផង តាមរយៈការប្រើប្រាស់ទីតាំង និង





លោកស្រី ធីណា វ៉ែងស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា ជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅចេតិយសំណាងនិម្មិតរូប «ទូលធាតុ» ស្ថិតនៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
(ផ្ទុំន ស្រីពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

សំណង់នេះជាថ្នាក់រៀន។ លោកស្រីមានប្រសាសន៍ដូច្នេះថា «ខ្ញុំសប្បាយចិត្តណាស់ដែលឃើញបងប្អូនពូមីងបានមកចូលរួមនៅទីនេះ។ ខ្ញុំមកថ្ងៃនេះ គឺចង់មកមើលចេតិយ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាទើបតែសាងសង់រួចរាល់កាលពីខែមេសា កន្លងទៅនេះ។ ដោយយល់ឃើញថា បងប្អូនពូមីងដែលជាជនរងគ្រោះ មានសាច់ញាតិបងប្អូនស្លាប់នៅក្នុងរបបខ្មែរក្រហម ទើបមានការសាងសង់សំណង់ចេតិយនេះឡើងនៅទីនេះ ដើម្បីគោរពវិញ្ញាណក្ខន្ធដល់ពួកគាត់ដែលបានស្លាប់ទៅ។ ទីតាំងនេះ ក៏ជាកន្លែងសម្រាប់បង្រៀនដល់ក្មេងជំនាន់ក្រោយឲ្យចងចាំពីរបបខ្មែរក្រហម និងទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឲ្យវិលត្រឡប់មកវិញសារជាថ្មីម្តងទៀត»។ ជាចុងក្រោយ លោកស្រីបានសួរទៅកាន់អ្នករស់រានមានជីវិតទាំងអស់ពីអាយុ ការរស់នៅប្រចាំថ្ងៃ និងបញ្ហាសុខភាព។ មុនដំបូង លោកស្រីបានបង្ហាញពីអារម្មណ៍របស់លោកស្រីតាមរយៈការមើលឃើញផ្ទាល់ភ្នែកថា អ្នករស់រានមានជីវិតទាំងអស់ពិតជាមានសុខភាពល្អ និងរឹងមាំណាស់។ ប៉ុន្តែនៅពេលដែលលោកស្រីសួរនាំដល់បញ្ហាសុខភាពអ្នករស់រានមានជីវិតភាគច្រើន ជាពិសេសអ្នកដែលមានអាយុលើស៦០ឆ្នាំ សុទ្ធតែមានជំងឺទឹកនោមផ្អែម ជំងឺសន្លាក់ និងជំងឺលើសឈាម។ លោកស្រីមានប្រសាសន៍ដូច្នេះថា «...មួយវិញទៀតខ្ញុំបានដឹងថា មជ្ឈមណ្ឌលឯកសារកម្ពុជា គឺមានគម្រោងមួយពាក់ព័ន្ធនឹងការគាំពារសុខភាពអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ ខ្ញុំកោតសរសើរអ៊ំពូមីង ដែលមើលទៅឃើញថាអ៊ំពូមីងមានវ័យចាស់ និងមានសុខភាពរឹងមាំ ក៏ប៉ុន្តែតាមរយៈការសំណេះសំណាលរបស់ខ្ញុំជាមួយបងប្អូនពូមីងទើបខ្ញុំដឹងថា អ៊ំពូមីងភាគច្រើន សុទ្ធតែមានជំងឺប្រចាំកាយ ដូចជាលើសឈាម ទឹកនោមផ្អែម ក្រពះ វិលមុខ ស្ពឹកស្រពន់ជាដើម»។ ចុងបញ្ចប់ លោកស្រីបានផ្តាំផ្ញើឲ្យអ្នករស់រានទាំងអស់ថែរក្សាសុខភាព និងបន្តចែករំលែកបទពិសោធន៍របស់ខ្លួនដល់ក្មេងៗជំនាន់ក្រោយទៀត ដើម្បីថែរក្សាការចងចាំពីប្រវត្តិសាស្ត្រខ្មែរ

ក្រហម និងចូលរួមទប់ស្កាត់ការកកើតឡើងវិញនៃរបបនេះ នាពេលអនាគត។

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលមានវត្តមាននៅឯសំណង់ចេតិយសហគមន៍បានថ្លែងអំណរគុណដល់លោកស្រី ធីណា វ៉ែដស ដែលបានយកចិត្តទុកដាក់និងចុះមកសួរសុខទុក្ខអ្នករស់រានមានជីវិតដោយផ្ទាល់នាថ្ងៃនេះ។ នេះគឺជាកាយវិការមួយដែលបង្ហាញថា រឿងរ៉ាវរបស់គាត់មិនត្រូវបានបំភ្លេច។

អ្នករស់រានមានជីវិតទាំងអស់បានសំណូមលោកស្រីឲ្យជួយកែលម្អបរិវេណចេតិយ ជាពិសេសឈូសឆាយផ្លូវចូលមកកាន់ចេតិយឲ្យកាន់តែប្រសើរជាងនេះ ដើម្បីឲ្យគាត់ទាំងអស់គ្នាអាចមកប្រារព្ធកម្មវិធីផ្សេងៗ ដូចជាទិវាចងចាំ និងវេទិកាពិភាក្សាអំពីរឿងរ៉ាវពីសម័យខ្មែរក្រហមដល់ក្មេងជំនាន់ក្រោយនៅទីនេះបានកាន់តែប្រសើរ។

សូមបញ្ជាក់ថា កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ លោកស្រី ធីណា វ៉ែដស បានមកធ្វើទស្សនកិច្ចនៅព្រះរាជបណ្ណាល័យ ហ្វូងម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជាម្តងរួចហើយ ដើម្បីឈ្វេងយល់ពីដំណើរការនៃបណ្ណាល័យនេះ និងកិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។



លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា និង លោកស្រី ធីណា វ៉ែដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា ទស្សនាសំណង់ចេតិយសំណាងនិម្មិតរូប នៅ ទីតាំង «ទួលធាតុ» ស្ថិតនៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។
(ថុន ស្រីពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ជួបលោកស្រី ធីណា វ៉ែដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅកម្ពុជា នៅចេតិយសំណាងនិម្មិតរូប «ទួលធាតុ»។
(ថុន ស្រីពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# រមណីយដ្ឋានសត្វស្លាបធម្មជាតិទួលព័ន្ធតាឡី

**ផេង ពង្សរ៉ាស៊ី**



ទេសភាពផ្ទៃទឹកនៅរមណីយដ្ឋានសត្វស្លាបធម្មជាតិទួលព័ន្ធតាឡី ស្ថិតនៅភូមិទ័ពស្តេច ឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

**រមណីយដ្ឋានសត្វស្លាបធម្មជាតិទួលព័ន្ធតាឡី៖** ជារមណីយដ្ឋានសត្វស្លាបធម្មជាតិដ៏កម្រមួយមានទំហំ ៨៦ហិកតា ដែលមានប្រភេទសត្វស្លាបជិតផុតពូជ និងទទួលរងការគំរាមកំហែងជាច្រើនប្រភេទកំពុងរស់នៅរាប់ម៉ឺនក្បាល ដូចជាស្មោញ ទងប្រផេះ ប្រភេទសត្វត្រយ៉ង ត្រដក់ ននៀល ខ្យង កុក ខ្វែក ក្អែកទឹក ទងក្រសារ និងសត្វស្លាបប្រមាណជិត៥០ប្រភេទផ្សេងៗទៀត។ រមណីយដ្ឋាននេះ ស្ថិតនៅភូមិទ័ពស្តេច ឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង មានចម្ងាយប្រមាណ៨០គីឡូម៉ែត្រពីទីក្រុងភ្នំពេញ និងប្រមាណ ១៥ គីឡូម៉ែត្រពីទីរួមខេត្តព្រៃវែង។

ស្ថិតនៅចំកណ្តាលផ្ទៃទឹកដ៏ធំល្វឹងល្វើយ រមណីយដ្ឋាននេះអាចទទួលភ្ញៀវទេសចរណ៍បានគ្រប់រដូវ។ នៅរដូវប្រាំង ភ្ញៀវទេសចរណ៍នានាអាចធ្វើដំណើរដោយខ្លួនឯងតាមរថយន្ត ទោចក្រយានយន្ត និងថ្មើរជើងទៅកាន់ទីតាំងនេះ។ ចំណែកនៅរដូវវស្សាវិញ ភ្ញៀវទេសចរណ៍អាចធ្វើដំណើរតាមទូក និងកាណូតតែប្រមាណពីរគីឡូម៉ែត្រពីភូមិអ្នកស្រុក ទៅកាន់ទី



មានសត្វស្លាបរាប់ម៉ឺនក្បាលប្រមាណ៥០ប្រភេទ រស់នៅរមណីយដ្ឋានសត្វស្លាបធម្មជាតិទួលព័ន្ធតាឡី។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ទួលដើម្បីទស្សនាហ្វូងសត្វស្លាប និងព្រៃឈើដែលដុះប្រជ្រៀតគ្នានៅលើទីទួលព័ន្ធតាឡី។ តាមការឲ្យដឹងពីប្រជាជនរស់នៅជុំវិញបរិវេណទីទួលនេះថា ហ្វូងសត្វស្លាបទាំងអស់ លើកលែងតែសត្វក្រាបពងបានចាកចេញពីសំបុក និងទីទួលព័ន្ធតាឡីនៅវេលាព្រឹកដើម្បីចេញទៅរកស៊ីនៅកន្លែងឆ្ងាយៗពីទួល ហើយបានវិលត្រឡប់មកវិញនៅវេលាល្ងាចចាប់ពីម៉ោង ៥ រហូតដល់ពេលជិតយប់ងងឹត។ ភ្ញៀវទេសចរណ៍នានាច្រើននាំគ្នាទៅទស្សនាហ្វូងសត្វស្លាបទាំងនេះ ចាប់ពីវេលាម៉ោងបី ឬម៉ោងបួនតទៅ ដើម្បីបានមើលឃើញដំណើរវិលត្រឡប់របស់ហ្វូងសត្វស្លាប។

នៅជុំវិញទីទួលព័ន្ធតាឡី យើងសង្កេតឃើញមានរោងធ្វើពីឈើគ្មានដំបូល ឬមានដំបូលធ្នះធ្លាយចំនួនបួនប្រាំ និងរោងធ្វើអំពីថ្មចំនួនមួយ ត្រូវបានសាងសង់ឡើងនៅជុំវិញបរិវេណព្រៃព័ន្ធតាឡី ដើម្បីធ្វើជាកន្លែងទទួលស្វាគមន៍ភ្ញៀវទេសចរណ៍ទាំងឡាយដែលមកទស្សនានៅទីនេះ។ ក្រុមការងាររបស់យើងបានទៅកាន់រោងធ្វើពីឈើចាស់ទ្រុឌទ្រោមមួយស្ថិតនៅភាគខាងកើតទីទួល និងបានឡើងលើរោងនោះដើម្បីទស្សនាហ្វូងសត្វស្លាបឲ្យបានជិតបន្តិច។ នៅលើរោងដំបូលធ្នះធ្លាយនេះ យើងពុំសូវចាប់អារម្មណ៍ខ្លាំងឡើយពីសុវត្ថិភាពផ្ទាល់ខ្លួន ប៉ុន្តែយើងបែរជាចាប់អារម្មណ៍ខ្លាំងបំផុតពីទេសភាពផ្ទៃទឹកមើលពីលើ និងទិដ្ឋភាពហ្វូងសត្វស្លាបដែលហើរផ្លែលចុះផ្លែលឡើងនៅជុំវិញខ្លួន។ ម្នាក់ៗបានទាញទូរសព្ទដៃមកថតយករូបភាពដដែលគ្នា ថតគ្នាទៅវិញទៅមក និងទស្សនាទេសភាពកណ្ដាលផ្ទៃទឹក និងអ្វីៗដែលអាចមើលឃើញនៅជុំវិញខ្លួនជាពិសេសទិដ្ឋភាពព្រះអាទិត្យហៀបនឹងអស្តង្គតបញ្ចេញពណ៌ក្រហមព្រឿងៗ លម្អដោយហ្វូងសត្វស្លាបហើរផ្លែលចុះឡើងៗពីដើមឈើមួយទៅដើមឈើមួយ។

ទីតាំងរមណីយដ្ឋានទួលព័ន្ធតាឡី ទទួលបានការចាប់អារម្មណ៍ខ្លាំងពីអ្នកទស្សនានៅឆ្នាំ២០១៩ និង

២០២០ បន្ទាប់ពីសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ខេត្តមួយត្រូវបានរៀបចំធ្វើឡើងនៅចុងឆ្នាំ២០១៩ ដើម្បីពិភាក្សាពីការដាក់បញ្ចូលតំបន់នេះ ឬដែលអ្នកស្រុកនិយមហៅថា ទីតាំង «ដីសើមបឹងស្នេហ៍» ទៅជាតំបន់ការពារធនធានធម្មជាតិ។ ដីសើមបឹងស្នេហ៍ ជាទីតាំងដីព្រៃលិចទឹកមួយកន្លែងដែលធ្លាប់ទទួលបានជំនួយក្នុងការបង្កាត់ពូជ និងអភិរក្សសត្វស្លាប ព្រមទាំងធនធានធម្មជាតិ កាលពីប៉ុន្មានឆ្នាំមុនៗ ប្រាក់ ផល្លី ជាអ្នកអភិរក្សសត្វស្លាបនៅរមណីយដ្ឋានទួលព័ន្ធតាឡី ឬដីសើមបឹងស្នេហ៍ បានឲ្យដឹងថា ហ្វូងសត្វស្លាបទាំងអស់បានមកស្នាក់នៅបណ្តោះអាសន្ននៅលើទីទួលនេះ តែក្នុងរដូវវស្សា ឬរដូវទឹកឡើងប៉ុណ្ណោះនៅមុនឆ្នាំ២០១៨។ លុះចាប់តាំងពីឆ្នាំ២០១៩មក ការតាំងទីលំនៅនៃសត្វទាំងនេះ គឺលែងមានការផ្លាស់ទីទៀតហើយ។ «នៅឆ្នាំ២០១៧-២០១៨ សត្វទាំងអស់នេះគឺជាសត្វរដូវកាល។ ដល់ពេលខែទឹកឡើងបានគេ (សត្វ)មក ហើយដល់ខែទឹកសម្រក គេទៅវិញបាត់។ តែចាប់ផ្តើមពីឆ្នាំ២០១៨-២០១៩ ហើយជាពិសេសនៅដើមឆ្នាំ២០២០ គឺគេចាប់ផ្តើមបោះទីតាំងនៅជាអចិន្ត្រៃយ៍តែម្តង។»

នៅពាក់កណ្តាលឆ្នាំ២០២១កន្លងទៅនេះ សត្វស្លាបរាប់ពាន់ក្បាលបានងាប់ជាបន្តបន្ទាប់។ ម្ចាស់ទូកចម្លង (មិនស្គាល់ឈ្មោះ) ម្នាក់បានប្រាប់ថា មូលហេតុដែលនាំឲ្យសត្វស្លាបទាំងនោះងាប់ គឺដោយសារក្តៅខ្លាំង និងចំហាយអាចម៍សត្វទាំងនោះជះខ្លាំងពេកដែលធ្វើឲ្យសត្វទាំងនោះពិបាកដកដង្ហើម។ តាមការឲ្យដឹងពីម្ចាស់ទូកចម្លងដដែលថា នៅចុងខែមករា ឆ្នាំ២០២២នេះ កំណើតសត្វស្លាបទាំងនេះបានកើនឡើងច្រើនលើសមុន ហើយនឹងអាចច្រើនជាងមុនក្នុងពេលដ៏ខ្លី ព្រោះថាសត្វទាំងនោះកំពុងក្រាបពង ស្របពេលដែលទឹកដែលព័ទ្ធជុំវិញទីទួលនេះនៅមិនទាន់ស្រកអស់នៅឡើយ។

នៅតាមវាលស្រែប្រសងខាងផ្លូវជាតិនានានៃខេត្តព្រៃវែងដែលយើងបានធ្វើដំណើរ យើងតែងក្រឡេកមើលឃើញហ្វូងសត្វស្លាបជាច្រើនប្រភេទហើរ



ទេសភាពថ្ងៃហៀបនឹងលិចនៅរមណីយដ្ឋានសត្វស្លាបធម្មជាតិទួលព័ន្ធតាឡី។
(ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ភ្ញៀវទេសចរណ៍ជិះទូកកម្សាន្តនៅរមណីយដ្ឋានសត្វស្លាបធម្មជាតិទួលព័ន្ធតាឡី។
(ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

និងស្វែងរកស៊ីចំណីទាំងនៅតាមវាលស្រែដែលទើបនឹងភ្ជួររាស់ ទាំងវាលស្រែដែលទើបនឹងស្ទូងរួច និងតាមវាលស្រែដែលហៀបនឹងទទួលបានផលរបស់អ្នកស្រុក។ នៅពេលដែលយើងធ្វើដំណើរវិលត្រឡប់មកពីប្រកបការងារវិញនៅម៉ោងប្រមាណជាង ៥រសៀល យើងសង្កេតឃើញសត្វស្លាបទាំងហ្វូងៗ ហើរសំដៅទៅកាន់ទីជម្រកនៅទីទួលព័ន្ធតាឡី ឬតំបន់ដីសើមបឹងស្នេហ៍។

# វត្តពោងដំរី

សោម ប៊ុនថន



វត្តពោងដំរី ស្ថិតនៅក្នុងសង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





អំឡុងពេលចុះធ្វើការងារនៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ក្រុមការងារបានយកទស្សនាវដ្តីស្វែងរកការពិតដែលបានបោះពុម្ពផ្សាយអំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទៅប្រគេនព្រះអង្គ យាង ភាល័គ ព្រះចៅអធិការវត្តពោងដំរី ស្ថិតនៅក្នុងសង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង ដែលមានចម្ងាយប្រមាណ ២គីឡូម៉ែត្រពីមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ ព្រះតេជគុណ យាង ភាល័គ មានសង្ឃដីកាថា កាលពីសម័យដើម វត្តពោងដំរី មានព្រះអង្គធ្វើពីសំរិទ្ធសុទ្ធមួយអង្គដែលបានដាក់តម្កល់ទុកនៅព្រះវិហារ។ ក្រោយមកនៅអំឡុងសម័យសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជាក៏

មានការទម្លាក់គ្រាប់បែកយ៉ាងច្រើននៅជុំវិញវត្តពោងដំរី និងលើព្រះវិហារវត្តពោងដំរីនេះ ប៉ុន្តែគ្រាប់បែកដែលទម្លាក់មកទាំងនោះមិនផ្ទុះ និងពុំដែលចំព្រះវិហារឡើយ ព្រោះនៅក្នុងព្រះវិហារមានព្រះអង្គធ្វើពីសំរិទ្ធសុទ្ធដែលតាមវិទ្យាសាស្ត្រសំរិទ្ធគឺមានសារធាតុដែលមិនអាចឲ្យគ្រាប់បែកផ្ទុះ ហើយម្យ៉ាងទៀតដោយសារមានជំនឿថាវត្តនេះមានបារមីស័ក្តិសិទ្ធិ។

មកដល់របបខ្មែរក្រហម កម្មាភិបាលខ្មែរក្រហមបានយកកុដិព្រះសង្ឃដែលសង់អំពីថ្មធ្វើជាមន្ទីរពេទ្យព្យាបាលអ្នកជំងឺ និងយកព្រះវិហារធ្វើជាកន្លែងចិញ្ចឹមជ្រូក ហើយទីតាំងធម្មសាលា ខ្មែរក្រហមប្រើប្រាស់សម្រាប់ការងារប្រចាំថ្ងៃ។ ចំណែកព្រះអង្គសំរិទ្ធិគឺរក្សាទុកនៅព្រះវិហារដដែល។ ព្រះអង្គមានសង្ឃដីកាបន្តថា ក្រោយពីរបបខ្មែរក្រហមដួលរលំ លោកយាយ លោកតា និងពុទ្ធបរិស័ទបាននាំគ្នាបោសសម្អាតព្រះវិហារដែលបន្សល់ទុកសុទ្ធតែលាមកជ្រូក និងទីធ្លាវត្តដើម្បីរៀបចំប្រើប្រាស់ជាកន្លែងគោរពបូជាឡើងវិញ។ ដោយសារព្រួយបារម្ភពីការបាត់បង់ព្រះអង្គសំរិទ្ធ ពុទ្ធបរិស័ទបាននាំគ្នាសែងព្រះអង្គសំរិទ្ធពីបល្ល័ង្កមករក្សាទុកនៅកុដិព្រះសង្ឃវិញ ប៉ុន្តែមិនអាចរំកិលព្រះអង្គសំរិទ្ធបានឡើយ។ ក្រោយមកទើបអាចារ្យ និងពុទ្ធបរិស័ទលេងភ្លេងពិណពាទ្យចំនួន៧បទថ្វាយ និងបន់ស្រន់ទើបអាចរំកិលព្រះអង្គសំរិទ្ធចេញពីបល្ល័ង្កបាន។ នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ព្រះអង្គសំរិទ្ធនោះត្រូវបានចោរចូលមកយកនៅវេលាម៉ោង ៣ ទៀបភ្លឺ ទោះបីពេលនោះព្រះសង្ឃ និងអាចារ្យវត្តដឹងក៏ដោយក៏មិនអាចធ្វើការទប់ស្កាត់បានដែរ ព្រោះក្រុមចោរបានប្រើកាំភ្លើងដើម្បីគំរាម។ ចាប់តាំងពីពេលនោះមក គឺនៅសល់តែបល្ល័ង្កព្រះអង្គសំរិទ្ធតែប៉ុណ្ណោះ។

បច្ចុប្បន្ន នៅក្នុងបរិវេណវត្តពោងដំរីនេះនៅមានសេសសល់សំណង់ចេតិយដែលមានអាយុយ៉ាងតិច៦០ឆ្នាំជាច្រើន, កុដិ និងធម្មសាលាមានអាយុកាលច្រើនឆ្នាំ ត្រូវបានថែរក្សាទុកបានយ៉ាងល្អ។ ចំណែកផ្នែកខ្លះនៃព្រះវិហារត្រូវបានកែលម្អដោយដាក់ពិដាន និងមានការគូរគំនូរ ហើយដំបូលត្រូវបានជំនួសដោយគ្រឿងថ្មី ក្រៅពីនោះគឺនៅរក្សាទម្រង់ដើមដដែល ដូចជា ផ្ទោង ផ្ដាន ធ្នឹម ហោជាង ទ្វា បង្អួច ដែលសាងសង់ពីឈើ ចំណែកជញ្ជាំងសង់ពីឥដ្ឋលាយបាយអរ។ តាមសង្ឃដីការបស់ព្រះចៅអធិការវត្ត សសរទាំងអស់នៅព្រះវិហារនេះគឺសង់អំពីឈើទាំងអស់ ដែលដឹកតាមកប៉ាល់មកពីខេត្តក្រចេះនៅមុនសម័យបារាំងទៅទៀត។ សសរឈើទាំងនេះនៅរឹងមាំ និងទ្រទ្រង់ព្រះវិហារបាននៅឡើយ ដោយគ្រាន់តែមានការលាបថ្នាំ និងគូរគំនូរពីលើ។ ដោយសារវត្តពោងដំរីមានអាយុកាលច្រើនឆ្នាំ និងមានសំណង់ ព្រមទាំងចេតិយបុរាណច្រើនទើបមានពុទ្ធបរិស័ទ និងក្រុមការងារព្រះបរមរាជវាំងមកធ្វើបុណ្យជាញឹកញាប់។









វត្តពោងដំរី ស្ថិតនៅក្នុងសង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ស្រី សំអាង៖ អតីតពេទ្យយោធាតំបន់២០

**ភា វស្នី**



ស្រី សំអាង អាយុ៦៩ឆ្នាំ សព្វថ្ងៃរស់នៅភូមិពន្ទៃ ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ (ដេង ពងរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ស្រី សំអាង អាយុ៦៩ឆ្នាំ កើតនៅភូមិពន្ទៃ ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានប្រពន្ធឈ្មោះ រ៉ា សុណ្ណារ៉ា និងមានកូនចំនួន៣នាក់ គឺប្រុស២នាក់ និងស្រីម្នាក់។ នៅអាយុ១៣ឆ្នាំ ខ្ញុំបានចូលរៀនជាមួយព្រះសង្ឃនៅក្នុងវត្តពន្ទៃ។ ក្រោយមកខ្ញុំចូលរៀនបន្តនៅសាលាបឋមសិក្សាអង្គរស រហូតដល់ថ្នាក់ទី៩។

នៅឆ្នាំ១៩៦៩ បន្ទាប់ពីឈប់រៀន ខ្ញុំសម្រេចចិត្តចូលបួសជាព្រះសង្ឃនៅក្នុងវត្តពន្ទៃ។ រហូតដល់ឆ្នាំ១៩៧០ ខ្ញុំបានសឹកហើយត្រឡប់មកជួយធ្វើស្រែឪពុកម្តាយវិញ។ នៅខែមីនា ឆ្នាំ១៩៧១ ឈ្មោះ ប៉ុន គឺជាប្រធានភូមិពន្ទៃបានមកហៅខ្ញុំឲ្យទៅរៀនពេទ្យជាមួយក្រុមរណសិរ្សស្ថិតនៅម្តុំឃុំព្រៃទទឹង។ ខ្ញុំសម្រេចចិត្តទៅរៀន ព្រោះខ្ញុំចង់ធ្វើជាគ្រូពេទ្យ។ ខ្ញុំរៀនពេទ្យរយៈពេល៣ខែ ជាមួយប្រជាជនចំនួន១៥នាក់ទៀតនៅក្នុងឃុំអង្គរស។ គ្រូបង្រៀនខ្ញុំមានឈ្មោះ ឈិត និង ខុង ដែលគ្រូទាំងពីរនាក់នេះធ្លាប់បានទៅរៀនពេទ្យនៅប្រទេសវៀតណាមរយៈពេល៦ខែ។

បន្ទាប់ពីខ្ញុំរៀនពេទ្យចប់ ខ្ញុំចេញមកព្យាបាលអ្នកជំងឺនៅភូមិពន្ទៃ។ ពេលមកដល់ភូមិ ខ្ញុំបានជ្រើសរើសជំនួយការពេទ្យម្នាក់ និងបង្រៀនឲ្យចេះព្យាបាលជំងឺបន្តពីខ្ញុំ។ ចំណែកកម្មាភិបាលគ្រប់គ្រងនៅក្នុងស្រុកមេសាងពេលនោះ មានឈ្មោះ សំ ហ៊ាន គឺជាគណៈស្រុក, ឈ្មោះ ស័ក គឺជាមេឃុំអង្គរស និងឈ្មោះ ប៉ុន មានស្រុកកំណើតនៅភូមិស្រះតាអឹម គឺជាមេភូមិពន្ទៃ។ រយៈពេល៦ខែក្រោយមក ប៉ុន បញ្ជូនខ្ញុំឲ្យទៅធ្វើពេទ្យនៅតំបន់២០បន្តទៀត តាមរយៈការស្នើរបស់កម្មាភិបាលថ្នាក់លើ។ ទីតាំងមន្ទីរពេទ្យដែលខ្ញុំទៅធ្វើការគឺស្ថិតនៅក្នុងព្រៃជាប់ព្រំប្រទល់រវាងស្រុកមេសាង និងស្រុកកំចាយមារ ក្នុងខេត្តព្រៃវែង។

នៅតំបន់២០ ខ្ញុំមានតួនាទីជាអនុប្រធានពេទ្យយោធានៅក្នុងវរសេនាធំ (ប្តូហៅថា យ) ដែលមានយោធា៣វរសេនាតូច (ប្តូហៅថា គ) ចំណុះ។ ក្នុងមួយសប្តាហ៍ ខ្ញុំចុះទៅពិនិត្យ និងព្យាបាលជំងឺឲ្យទៅយោធាទាំង៣គ ។ ក្រៅពីព្យាបាល ក្រុមរបស់ខ្ញុំចំនួន៣នាក់បានផលិតថ្នាំគ្រាប់សម្រាប់ព្យាបាលជំងឺ ដោយក្នុងមួយថ្ងៃក្រុមរបស់ខ្ញុំផលិតបានថ្នាំចំនួន១០០០គ្រាប់។

នៅពេលនោះ ខ្ញុំក៏បានខិតខំស្វះស្វែងរកបុសឈើផ្សេងៗដើម្បីយកមកផ្សំធ្វើថ្នាំដែរ។ នៅពេលចេញទៅរកថ្នាំម្ដងៗ ខ្ញុំតែងតែលួចមកលេងផ្ទះ។ នៅពេលខ្ញុំមកដល់ផ្ទះ ប្រជាជននៅសហករណ៍ទទួលរាក់ទាក់ខ្ញុំខ្លាំងណាស់។ កាលនោះប្រធានពេទ្យប្រចាំភូមិភាគបូព៌ាមានឈ្មោះ ភឹម ស៊ីណាត គឺជាកូនរបស់ សោ ភឹម ចំណែកប្រធានពេទ្យនៅស្រុកមេសាងឈ្មោះ ឈឿន។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅក្នុងបន្ទាយកងទ័ពតំបន់២០ មានការរៀបចំពិធីអបអរសាទរជ័យជម្នះរបស់កងទ័ពបដិវត្តន៍ខ្មែរក្រហម។ អង្គភាពទ័ព និងមន្ទីរបានកាប់គោ ជ្រូកដើម្បីធ្វើម្ហូបជប់លៀងឲ្យសមាជិកនៅក្នុងតំបន់២០ហូបជុំគ្នា។ បន្ទាប់មកអង្គការតម្រូវឲ្យយោធា និងពេទ្យទាំងអស់ចុះទៅធ្វើការនៅតាមការដ្ឋានការងារដូចជា ធ្វើស្រែវស្សា ធ្វើស្រែប្រាំង លើកទំនប់ និងជីកប្រឡាយ។ ក្រុមពេទ្យរបស់ខ្ញុំ និងយោធាផ្សេងទៀត ចាប់ផ្ដើមធ្វើការងារធ្ងន់ជារៀងរាល់ថ្ងៃ ចំណែកការហូបចុកមិនគ្រប់គ្រាន់ដូចមុនទេ។

នៅខែមិថុនា ឆ្នាំ១៩៧៧ ប៉ុល ពត បានចុះមកតំបន់២០ ដើម្បីប្រជុំជាមួយ សោ ភឹម និងគណៈគ្រប់គ្រងធំៗផ្សេងទៀតនៅក្នុងតំបន់ និងភូមិភាគបូព៌ា។ នៅក្នុងការប្រជុំ ប៉ុល ពត បានបញ្ជាឲ្យរៀបចំយោធាឡើងវិញដើម្បីវាយតទល់ជាមួយកងទ័ពវៀតណាម។ ក្រោយពីបញ្ចប់ការប្រជុំ យោធាខ្មែរក្រហម និងពេទ្យទាំងអស់ត្រៀមខ្លួនចេញទៅកាន់ព្រំដែនកម្ពុជា-វៀតណាម។

នៅចុងឆ្នាំ១៩៧៧ អង្គការបានបញ្ជូនយោធាមកពីភូមិភាគនិរតី មកចាប់មេដឹកនាំនៅភូមិភាគបូព៌ា។ ពេលនោះមេដឹកនាំធំៗនៅក្នុងភូមិភាគបូព៌ាមួយចំនួនបានលួចរត់ចូលទៅប្រទេសវៀតណាម និងខ្លះទៀតត្រូវបានចាប់យកទៅសម្លាប់។ នៅពេលយោធាខាងភូមិភាគនិរតីចូលមកដល់ ក្រុមពេទ្យរបស់ខ្ញុំត្រូវបានរំសាយ ហើយខ្ញុំក៏ត្រឡប់មកធ្វើការនៅក្នុងភូមិពន្លៃវិញ។ នៅពេលនោះគណៈគ្រប់គ្រងសហករណ៍មកបញ្ចុះបញ្ចូលខ្ញុំឲ្យទៅរស់នៅតំបន់ដីខ្វាញ់ ប៉ុន្តែខ្ញុំបានបដិសេធ។ ខ្ញុំចាប់ផ្ដើមធ្វើស្រែជាមួយប្រជាជននៅភូមិពន្លៃ ព្រោះអង្គការឈប់ឲ្យខ្ញុំធ្វើពេទ្យទៀតហើយ។

នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៧៨ ខ្ញុំស្នើទៅថ្នាក់លើដើម្បីរៀបការជាមួយកូនស្រីរបស់អ្នកភូមិពន្លៃ។ ទីតាំងរៀបការរបស់ខ្ញុំ គឺស្ថិតនៅក្នុងស្នាក់ការឃុំអង្គរស ដែលថ្ងៃនោះមានប្រជាជន១៣គូផ្សេងទៀតរៀបការដំណាលខ្ញុំដែរ។ បន្ទាប់ពីរៀបការរួច ខ្ញុំរស់នៅនិងធ្វើស្រែក្នុងភូមិពន្លៃ រហូតដល់កងទ័ពស្ម័គ្រចិត្តវៀតណាមវាយចូលមក នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ជំនួយការវៀតណាមបានជ្រើសរើសខ្ញុំឲ្យចូលធ្វើទាហាន និងបញ្ជូនខ្ញុំឲ្យទៅធ្វើការនៅសមរភូមិអន្លង់វែង បាត់ដំបង និងពោធិ៍សាត់។ ខ្ញុំធ្វើពេទ្យទាហានបានរយៈពេល៥ខែ ក៏ត្រឡប់មកស្រុកកំណើតវិញ។ ពេលមកដល់ភូមិវិញ ជំនាញការវៀតណាមជ្រើសរើសខ្ញុំឲ្យធ្វើជាប្រធានពេទ្យឃុំ និងឲ្យឡើងទៅរៀនពេទ្យបន្តនៅទីរួមខេត្តព្រៃវែង។ ក្រោយមកទៀត ខាងស្រុកបញ្ជូនខ្ញុំឲ្យទៅរៀនពេទ្យនៅប្រទេសវៀតណាមបន្តទៀត ប៉ុន្តែខ្ញុំបានស្នើសុំទៅខាងស្រុកឲ្យបញ្ជូនក្មួយរបស់ខ្ញុំទៅរៀននៅវៀតណាមជំនួសខ្ញុំវិញ។ ចំណែកខ្ញុំនៅធ្វើជាប្រធានពេទ្យឃុំអង្គរសរហូតដល់ចូលនិវត្តន៍ កាលពីឆ្នាំ២០១១។



ស្រី សំអាង ផ្ដល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ក្រុមការងារមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សុខ រី ៖ ប្រធានក្រុមដឹកនាំប្រជាជនក្នុងភូមិ ធ្វើការនៅក្នុងរបបខ្មែរក្រហម

*ភា រស្មី*



សុខ រី អាយុ៧៦ឆ្នាំ រស់នៅភូមិចាន់ ឃុំព្រែកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សុខ រី ភេទប្រុស អាយុ៧៦ឆ្នាំ កើតនៅភូមិចាន់ ឃុំព្រែកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ សព្វថ្ងៃខ្ញុំរស់នៅភូមិឃុំដដែល។ ខ្ញុំមានឪពុកឈ្មោះ សុខ ឈួន និងម្តាយឈ្មោះ ឡុង សុំ ព្រម ទាំងមានបងប្អូន៥នាក់ គឺស្រី២នាក់ និងប្រុស៣នាក់ ប៉ុន្តែសព្វថ្ងៃបងប្អូនរបស់ខ្ញុំ នៅរស់តែ៣នាក់ តែប៉ុណ្ណោះ។ កាលពីសង្គមចាស់គ្រួសាររបស់ខ្ញុំមានជីវភាពមធ្យម និងមានអាហារហូបគ្រប់គ្រាន់ ព្រោះមានដីសម្រាប់ធ្វើស្រែ ប៉ុន្តែឪពុកម្តាយរបស់ខ្ញុំមិនមានប្រាក់បញ្ជូនកូនឲ្យរៀនបានខ្ពង់ខ្ពស់ឡើយ។

ខ្ញុំចាប់ផ្តើមចូលរៀនដំបូងនៅថ្នាក់ទី១២ សង្គមចាស់ជាមួយព្រះសង្ឃនៅក្នុងវត្តពោធិ៍សិរី ហៅវត្តភូមិចាន់។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០ ក៏ឈប់រៀន ហើយទៅជួយធ្វើស្រែឪពុកម្តាយវិញ។ នៅឆ្នាំ១៩៦៦ ខ្ញុំបានរៀបការជាមួយប្រពន្ធទី១ របស់ខ្ញុំ នៅភូមិតាធាវ ឃុំបឹងព្រះ ស្រុកបាភ្នំ ខេត្តព្រៃវែង។ ពេលរស់នៅភូមិតាធាវ គ្រួសាររបស់ខ្ញុំប្រកបរបរធ្វើស្រែដើម្បីចិញ្ចឹមជីវិត ប៉ុន្តែជីវភាពគ្រួសាររបស់ខ្ញុំនៅតែមានការខ្វះខាតដដែល។ ទន្ទឹមនឹងនោះ ក៏មានយន្តហោះមកទម្លាក់គ្រាប់បែកណាប៉ាល់នៅក្នុងភូមិ ព្រោះសង្ស័យថា មានកងទ័ពរំដោះខ្មែរក្រហមលាក់ខ្លួន។

ខ្ញុំចាំបានថា ថ្ងៃមួយនៅពេលដែលខ្ញុំនៅវាលស្រែ ស្រាប់តែមានយន្តហោះមកទម្លាក់គ្រាប់ណាប៉ាល់បណ្តាលឲ្យឆេះ។ ឃើញស្ថានភាពមិនស្រួល ខ្ញុំបានរត់ចូលក្នុងត្រង់សេក្បែរនោះ ប៉ុន្តែឈ្មោះ ឆែម ដែលលាក់ខ្លួនក្នុងត្រង់សេ ស្ថិតនៅចម្ងាយប្រមាណ១០០ម៉ែត្រពីខ្ញុំ ត្រូវបានសាំងក្នុងគ្រាប់ណាប៉ាល់ហូរចូលក្នុងត្រង់សេបណ្តាលឲ្យឆេះស្លាប់។ ក្រោយហេតុការណ៍នោះ គ្រួសាររបស់ខ្ញុំបានភៀសខ្លួនទៅរស់នៅទ័ពស្តេច ស្ថិតនៅក្នុងឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង ដើម្បីគេចពីសមរភូមិប្រយុទ្ធ។ តួនាទីរបស់ខ្ញុំពេលទៅនៅទ័ពស្តេច គឺធ្វើជាប្រធានក្រុមដឹកនាំប្រជាជនធ្វើការ ហើយជាញឹកញាប់ក្រុមរបស់ខ្ញុំបានជួយសែងកងទ័ពរំដោះខ្មែរក្រហមដែលរងរបួស ឬស្លាប់ពេលប្រយុទ្ធគ្នានៅសមរភូមិពាមរក៍ យកទៅដាក់នៅភូមិក្បែរនោះ។ នៅពេលនោះ ប្រពន្ធរបស់ខ្ញុំតែង

តែដាំបាយ ប្រកស្លុកស្លឹកត្នោត ឬយកស្រូវអង្ករ ដែលធ្វើបានទៅចែកឲ្យកងទ័ពរំដោះខ្មែរក្រហមនៅសមរភូមិ។

នៅឆ្នាំ១៩៧៥ ខ្ញុំបានសុំអង្គការមករស់នៅក្នុងភូមិចាន់វិញ ប៉ុន្តែពេលមកដល់ បងប្រុសរបស់ខ្ញុំដែលជាប្រធានសហករណ៍មិនឲ្យខ្ញុំនៅឡើយ ព្រោះខ្ញុំដឹកនាំក្រុមគ្រួសារផ្សេងទៀតមកច្រើនពេក។ ដូច្នេះក្រុមរបស់ខ្ញុំ ដែលមានសមាជិកប្រមាណ៣០គ្រួសារ បានទៅរស់នៅភូមិដូង ឃុំបាបោង ស្រុកពាមរក៍ ខេត្តព្រៃវែង។ នៅភូមិដូងខ្ញុំបន្តធ្វើជាប្រធានក្រុមដដែល ដើម្បីដឹកនាំប្រជាជនធ្វើស្រែ ហើយភាគច្រើន គឺធ្វើស្រែប្រាំង។ ពេលខ្ញុំធ្វើជាប្រធានកង ខ្ញុំត្រូវបានថ្នាក់លើធ្វើការទិតៀនច្រើនដង ដោយសារខ្ញុំប្រាប់ប្រជាជនឲ្យកុហកអង្គការពេលធ្វើប្រវត្តិរូប ដោយដាក់ថា មិនមានសមាជិកគ្រួសារធ្វើទាហាន ឬគ្រូបង្រៀនឡើយ ជាពិសេសឲ្យប្រជាជនលាក់មាសទុកនៅពេលដែលអង្គការសួររក។ សំណាងល្អ ខ្ញុំមានទំនាក់ទំនងល្អជាមួយប្រធានកងធំឈ្មោះ ឆុន ហៅ ស្រាំង ទើបខ្ញុំបានរួចខ្លួនពីការទិតៀន។ នៅក្នុងសម័យខ្មែរក្រហម ខ្ញុំធ្លាប់ឈឺគ្រុនញាក់ពីរដង និងបានទៅសម្រាកនៅពេទ្យភូមិស្ដៅ ដែលជាពេទ្យតំបន់២៨។ អំឡុងពេលព្យាបាល ខ្ញុំបានជួបឈ្មោះ ពីង ដែលជាប្រធានពេទ្យ ទើបខ្ញុំទទួលបានថ្នាំចាក់ល្អៗ និងឆាប់បានជាសះស្បើយត្រឡប់មកផ្ទះវិញ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំភ្លាមៗ នៅឆ្នាំ១៩៧៩ ខ្ញុំបានបបួលអ្នកភូមិ៥នាក់ ទៅរកដំឡូងនៅទួលជ្រៃ។ មូលហេតុដែលខ្ញុំដឹងថានៅទួលជ្រៃមានដំឡូង ពីព្រោះខ្ញុំធ្លាប់ទៅទីនោះ និងឃើញមានដំឡូងច្រើន។ ពេលទៅដល់ ស្រាប់តែខ្ញុំឃើញមានឈាមនៅមាត់រណ្ដៅ ហើយដើមឈើដែលដុះក្បែររណ្ដៅក៏សឹកសម្បកអស់ដែរ ព្រោះឈ្លបខ្មែរក្រហមចោកមនុស្សខ្ទប់នឹងដើមឈើនោះ។ ពេលឃើញទិដ្ឋភាពបែបនោះ យើងនាំគ្នាត្រឡប់មកផ្ទះវិញ ហើយខ្ញុំលែងហ៊ានទៅទីនោះ។ មួយថ្ងៃក្រោយមក ខ្ញុំបានត្រឡប់មកភូមិចាន់ដើម្បីពឹងពាក់បងប្អូននៅក្នុងភូមិឲ្យយករទេះចំនួន៣គ្រឿងទៅដឹកផ្ទះរបស់ខ្ញុំ។ ចាប់តាំងពីពេលនោះមក ខ្ញុំបានត្រឡប់មករស់នៅភូមិចាន់វិញ រហូតដល់បច្ចុប្បន្ន។ បន្ទាប់ពីប្រទេសកម្ពុជា ត្រូវបានរំដោះបានរយៈពេល៨ឆ្នាំ ប្រពន្ធរបស់ខ្ញុំក៏ស្លាប់ ហើយក្រោយមកខ្ញុំបានរៀបការជាមួយប្រពន្ធមួយទៀតឈ្មោះ ទូច យ៉ា ប៉ុន្តែមិនមានកូនទេ។



ផ្លូវនៅក្នុងឃុំព្រៃកណ្ដៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ប៉ុល ខន ៖ ជាងសាងសង់ផ្ទះ

ថុន ស្រីពេជ្រ



ប៉ុល ខន អាយុ៧៩ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិអង្គ្រង ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប៉ុល ខន អាយុ៧៩ឆ្នាំ គឺជាប្រជាពលរដ្ឋរស់នៅភូមិអង្គ្រង ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ ដោយសារតែរបបខ្មែរក្រហមកើតឡើងរយៈពេលជាង៤០ឆ្នាំកន្លងមកហើយ ហើយដោយសារគាត់មានវ័យកាន់តែជរា ដូច្នេះគាត់បានភ្លេចនូវរឿងរ៉ាវរបស់គាត់មួយចំនួននៅក្នុងរបបនោះ។ ខន បានដំណាលអំពីប្រវត្តិរឿងរ៉ាវរបស់គាត់ប្រាប់បុគ្គលិកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងដូចខាងក្រោម៖

ខ្ញុំឈ្មោះ ប៉ុល ខន កើតនៅភូមិអង្គ្រង ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ ប៉ុល ខាន់ និងម្តាយឈ្មោះ ប៉ែន នឹម។ ខ្ញុំគឺជាកូនទោលនៅក្នុងគ្រួសារ។ ឪពុកម្តាយរបស់ខ្ញុំបានបញ្ជូនខ្ញុំឲ្យទៅសិក្សារៀនសូត្រនៅសាលាបឋមសិក្សាបូសព្រីង។ នៅអាយុ១៥ឆ្នាំ ខ្ញុំរៀនត្រឹមថ្នាក់ទី ១០ ពីសង្គមចាស់។ ពេលនោះខ្ញុំក៏សម្រេចចិត្តឈប់រៀន ហើយមកបួសរៀននៅវត្តប្រាសាទ ស្ថិតនៅឃុំស្វាយយា ស្រុកស្វាយជ្រំ។ បួសបាន៣វស្សា ខ្ញុំបានសឹក ហើយត្រឡប់មកធ្វើស្រែចម្ការវិញ។ នៅអាយុ១៩ឆ្នាំ ខ្ញុំបានរៀបការជាមួយនឹងប្រពន្ធរបស់ខ្ញុំ។ បន្ទាប់ពីរៀបការហើយ ខ្ញុំមានកូនស្រីម្នាក់ ខណៈនោះមានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេចព្រះនរោត្តម សីហនុ ពីប្រមុខរដ្ឋ។ ដោយសារតែបានឮការអំពាវនាវរបស់សម្តេចពីទីក្រុងប៉េកាំងមកឲ្យកូនចៅដែលមានភក្តីភាពជាមួយព្រះអង្គរត់ចូលព្រៃម៉ាគី ដើម្បីតស៊ូប្រយុទ្ធ និងទាមទារយកអំណាចមកថ្វាយព្រះអង្គវិញ ដូច្នេះខ្ញុំពុំរួញរាឡើយ គឺខ្ញុំសម្រេចចិត្តចូលទៅក្នុងព្រៃម៉ាគី ដើម្បីតស៊ូជាមួយប្រជាជន។ គ្រួសាររបស់ខ្ញុំក៏សប្បាយចិត្ត និងជំរុញឲ្យខ្ញុំទៅតស៊ូដែរ។ ខ្ញុំធ្វើដំណើរអស់រយៈពេល ២ថ្ងៃ ទើបទៅដល់ឃុំកំពង់ត្រាច (ព្រៃម៉ាគី) ស្រុករមាសហែក និងបានស្នាក់នៅទឹកវិល។ កន្លះខែក្រោយមក ខ្ញុំបានត្រឡប់មកផ្ទះវិញដោយសារជួបការលំបាក និងពុំទាន់បានហ្វឹកហាត់យោធា។

ក្រោយថ្ងៃកងទ័ពខ្មែរក្រហម ទទួលជ័យជម្នះលើរបប លន់ នល់ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានអង្គការដាក់បញ្ចូលទៅក្នុងក្រុមជាងសង់ផ្ទះដែលមានសមាជិកចំនួន១២នាក់។ ជារឿយៗសមាជិក

ក្រុមរបស់ខ្ញុំ បានសង់ផ្ទះ សង់ខ្ទមឲ្យប្រជាជននៅក្នុងភូមិ។ ក្រៅពីសង់ផ្ទះ និងខ្ទម ខ្ញុំបានសង់មន្ទីរពេទ្យចំនួន ១០ខ្នង និងរោងបាយចំនួន៣នៅក្នុងភូមិរបស់ខ្ញុំ និងអារឈើសម្រាប់សង់សំណង់ផ្សេងៗទៀត។ បើនិយាយអំពីអាហារហូបចុក ពេលនោះខ្ញុំមានបាយហូបគ្រប់គ្រាន់ដោយសារតែខ្ញុំមានមិត្តភក្តិ និងបងធំដែលកាន់តួនាទីធំៗ ដូចជាឈ្មោះ ស័ក គឺជាគណៈឃុំ និង អ៊ុន គឺជាសន្តិសុខស្រុកទួលដើងចាប។ ស័ក និង អ៊ុន ត្រូវបានអង្គការចាប់ខ្លួន និងយកទៅសម្លាប់ នៅឆ្នាំ១៩៧៨ ក្រោយ សោ ភឹម ត្រូវបានចោទប្រកាន់ថា ប្រឆាំងនឹងបដិវត្តន៍។ ខ្ញុំពុំបានដឹងថា ឈ្លបខ្មែរក្រហមយកមិត្តភក្តិ និងបងធំរបស់ខ្ញុំទៅសម្លាប់ឯណាឡើយ ប៉ុន្តែខ្ញុំដឹងថា ទីតាំងសម្លាប់ដែលខ្ញុំស្គាល់មានចំនួន ៣ កន្លែងគឺ វាលតាប្រុញ, វត្តបឹងរ៉ៃ និងទួលដើងចាប។ ពេលដឹងថាមិត្តភក្តិ និងបងធំត្រូវបានឈ្លបចាប់ខ្លួនយកទៅសម្លាប់បែបនេះ ខ្ញុំភិតភ័យខ្លាំងណាស់ ព្រោះខ្លាចឈ្លបខ្មែរក្រហមចោទប្រកាន់ខ្ញុំ និងយកខ្ញុំទៅសម្លាប់បន្តទៀត។

នៅដើមខែមករា ឆ្នាំ១៩៧៩ ប្រជាជននៅក្នុងភូមិរបស់ខ្ញុំ បាននាំគ្នារត់ចាកចេញពីផ្ទះស្ទើរតែអស់រលីង ព្រោះបានឮដំណឹងតៗគ្នាថា កងកម្លាំងវៀតណាម នឹងចូលមកក្នុងភូមិ ហើយសម្លាប់ប្រជាជនចោលនាពេលបន្តិចទៀត។ ខ្ញុំរត់គេចខ្លួនបានបន្តិច ក៏បានជួបជាមួយកងទ័ពវៀតណាម ហើយកងទ័ពវៀតណាមប្រាប់ខ្ញុំឲ្យត្រឡប់មកក្រោយវិញ។

ក្រោយរបបខ្មែរក្រហមដួលរលំ មិនបានប៉ុន្មានខែផង ស្រាប់តែមានក្រុមជាតិនិយមមួយក្រុមទៀតដែលខ្ញុំមិនចាំឈ្មោះ បានចាប់ខ្ញុំយកទៅឃុំឃាំង និងសួរចម្លើយ។ ក្រុមជាតិនិយមនោះបានចោទប្រកាន់ខ្ញុំថា គឺជាក្រុមជីវសក្អកខៀវ ដែលបានចូលដៃចូលជើងជាមួយវៀតណាមខាងត្បូង។ ខ្ញុំទទួលរងការឈឺចាប់ និងរងទារុណកម្មរាល់ការសួរចម្លើយអស់រយៈពេល ២ខែ នៅក្នុងគុកមួយក្នុងខេត្តស្វាយរៀង។ ក្រោយពីការសួរចម្លើយ និងស្រាវជ្រាវដឹងថា ខ្ញុំមិនជាប់ពាក់ព័ន្ធជាមួយកងទ័ពវៀតណាមខាងត្បូង ក្រុមជាតិនិយមនោះក៏បានដោះលែងឲ្យ ខ្ញុំមានសេរីភាព និងបានវិលត្រឡប់មកស្រុកកំណើតវិញ។ ក្រោយមកខ្ញុំក៏បានចូលបម្រើកងទ័ពនៅក្នុងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជារហូតដល់ចូលនិវត្តន៍។



ផ្ទះរបស់អ្នកភូមិស្ថិតនៅក្នុងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ៊ុច ហាំ ៖ ប្រជាជនក្នុងភូមិរើសអើង ព្រោះខ្ញុំមានប្តីធ្វើជាទាហាន លន់ នល់

ភា រស្មី



អ៊ុច ហាំ អាយុ៧២ឆ្នាំ សព្វថ្ងៃរស់នៅភូមិព្រៃអង្គុញ ឃុំព្រែកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អ៊ុច ហាំ ភេទស្រី អាយុ៧២ឆ្នាំ សព្វថ្ងៃរស់នៅភូមិព្រៃអង្គុញ ឃុំព្រែកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ ហែម អ៊ុច និងម្តាយឈ្មោះ លឹម ហម ព្រម ទាំងមានបងប្អូនចំនួន៦នាក់ គឺស្រី៣នាក់ និងប្រុស៣នាក់។ ឪពុកម្តាយរបស់ខ្ញុំបានស្លាប់ចោលខ្ញុំតាំងពីខ្ញុំនៅក្មេង ហើយខ្ញុំត្រូវរស់នៅជាមួយបងស្រីរបស់ខ្ញុំម្នាក់ទៀត ដោយប្រកបរបរធ្វើស្រែ។ នៅអាយុ១៥ឆ្នាំ ខ្ញុំបានចូលរៀនថ្នាក់អក្ខរកម្មនៅផ្ទះម្តាយមីង រហូតចេះអានអក្សរបានបន្តិចបន្តួច។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ពេលមានរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ពីតំណែងប្រមុខរដ្ឋ ហើយរដ្ឋាភិបាលថ្មីចាប់ផ្តើមជ្រើសរើស និងប្រមូលកម្លាំងយុវជននៅក្នុងភូមិរបស់ខ្ញុំ ដើម្បីហ្វឹកហាត់ក្បួនទ័ព។ អំឡុងពេលនោះ ខ្ញុំមាននាទីជាប្រធានខ គ្រប់គ្រងមនុស្ស២០នាក់។ ក្រុមរបស់ខ្ញុំបានហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រយោធា ដូចជា ហាត់ចោលកាំបិត វាយដោយដៃ បោកចំបាប់ បាញ់លូនក្រាប ហើយគ្រូបង្វឹកគឺជាជនជាតិវៀតណាម និងមានជនជាតិខ្មែរចាំបកប្រែ។

នៅឆ្នាំ១៩៧១ បងស្រីរបស់ខ្ញុំបានរៀបការឲ្យខ្ញុំជាមួយបងប្អូនសាច់ញាតិឆ្ងាយម្នាក់ឈ្មោះ ប៉ុល ម៉ែន ធ្វើទាហាននៅខេត្តរតនគិរី។ ជិតដល់ថ្ងៃរៀបការ ឪពុកក្មេករបស់ខ្ញុំបានទៅតាមកូនប្រុសរបស់គាត់ឲ្យមករៀបការ ប៉ុន្តែ ម៉ែន មិននៅបន្ទាយទេ ព្រោះត្រូវបានអង្គភាពបញ្ជូនទៅប្រទេសវៀតណាម។ ថ្ងៃរៀបការរបស់ខ្ញុំគឺមិនមានកូនកម្លោះទេ ដូច្នេះយើងបានកាត់កម្មវិធីមួយចំនួនចេញ គឺយកតែកម្មវិធីទទួលភ្ញៀវប៉ុណ្ណោះ។ ញាតិនៅក្នុងភូមិបាននិយាយចំអកដាក់ខ្ញុំថា ខ្ញុំរៀបការជាមួយស្បែកជើង ប៉ុន្តែខ្ញុំមិនខឹងអ្នកទាំងនោះទេ។ ជាច្រើនខែក្រោយមក ទើបប្តីរបស់ខ្ញុំបានត្រឡប់មកផ្ទះវិញ ហើយឪពុកម្តាយរបស់ខ្ញុំបានរៀបចំសែនឲ្យខ្ញុំ និង ប្តី ម្តងទៀត

ដើម្បីកុំឲ្យខុសមេបា។

បន្ទាប់ពីសែនព្រេនបានមួយថ្ងៃ ខ្ញុំនិងប្តីរបស់ខ្ញុំបានចេញទៅខេត្តកំពង់ធំជាប្រញាប់ ព្រោះភូមិដែលខ្ញុំរស់នៅមានក្រុមយុវជនរត់ចូលព្រៃទៅចូលជាមួយចលនាបដិវត្តន៍ខ្មែរក្រហម ហើយបងប្អូនប្តីរបស់ខ្ញុំជាច្រើននាក់ក៏បានទៅចូលរួមជាមួយបដិវត្តន៍ដែរ។ ខ្ញុំបានធ្វើដំណើរតាមប្តីរបស់ខ្ញុំពីកន្លែងមួយទៅកន្លែងមួយទៀត រួមជាមួយប្រពន្ធទាហានផ្សេងទៀត។ ខ្ញុំត្រូវដេកនៅតាមវត្តអារាម ក្នុងព្រៃ រោងម៉ាស៊ីន និងពេលខ្លះសុំផ្ទះអ្នកភូមិដើម្បីស្នាក់នៅ។ ខ្ញុំនៅចាំកន្លែងដែលខ្ញុំរស់នៅជាមួយប្តីរបស់ខ្ញុំមួយចំនួនដូចជា នៅរោងម៉ាស៊ីនតាំងគោក វត្តពពេជ្រស្ថិតនៅក្នុងភូមិពពេជ្រ ភូមិបឹង និងនៅវត្តតាំងក្រសាំង។ ក្រោយមក ដោយសារកងទ័ពលន់នល់វាយចាញ់កងទ័ពបដិវត្តន៍ខ្មែរក្រហមជាបន្តបន្ទាប់ ទើបឈ្មោះសារី ពាក់ស័ក្តិ២ បានជូនប្រពន្ធៗទាហានទាំងអស់មកទីក្រុងភ្នំពេញតាមខទ្មាគចក្រវិញ។ ខ្ញុំស្នាក់នៅភ្នំពេញបានរយៈពេល៨ថ្ងៃ ក៏ធ្វើដំណើរត្រឡប់មកផ្ទះនៅស្រុកកំណើតនៅខេត្តព្រៃវែងវិញ។ ចាប់តាំងពីពេលនោះមក ខ្ញុំបែកពីប្តីរហូត។

ពេលមកដល់ផ្ទះ ទើបខ្ញុំដឹងថាខ្ញុំមានទម្ងន់៣ខែហើយ។ ពេលនោះ ខ្ញុំបានមករស់នៅជាមួយបងស្រីរបស់ខ្ញុំ។ ពេលដែលខ្ញុំរស់នៅជាមួយបងស្រីរបស់ខ្ញុំដំបូង ញាតិជិតខាងតែងតែនិយាយបញ្ចិតបញ្ចៀងថាខ្ញុំមានសាហាយជាមួយបងថ្លៃរបស់ខ្ញុំ ព្រោះឃើញខ្ញុំត្រឡប់មកផ្ទះតែម្នាក់ឯង។ ការរស់នៅរបស់ខ្ញុំមិនសូវទទួលបានការស្វាគមន៍ពីអ្នកភូមិប៉ុន្មានទេ ព្រោះខ្ញុំគឺជាប្រពន្ធរបស់ទាហានលន់នល់។ ប្រជាជនមូលដ្ឋានជាច្រើននាក់បានរើសអើងខ្ញុំ ហើយពេលបែករបបស្រូវ ក៏ខ្ញុំទទួលបានតិចជាងប្រជាជនផ្សេងដែរ។ ខ្ញុំខិតខំធ្វើការខ្លាំងណាស់ ព្រោះខ្លាចអង្គការយកខ្ញុំទៅសម្លាប់ចោល។ អង្គការមានគម្រោងយកខ្ញុំទៅរៀនសូត្រចំនួន៣លើក ប៉ុន្តែសំណាងល្អខ្ញុំបានរួចខ្លួន។ ការងារដែលខ្ញុំធ្វើនៅក្នុងសម័យខ្មែរក្រហម រួមមានស្ទូង ដក ប្រូតស្រូវ លើកប្រព័ន្ធប្រឡាយ ប្រព័ន្ធភ្លឺស្រែ ធ្វើប្រហុក កាប់ព្រៃដាំពោត និងកាច់ផ្លែពោត។ ការងារដែលលំបាកជាងគេសម្រាប់ខ្ញុំ គឺលើកប្រឡាយនៅកោះជ័យ។ ការងារនេះធ្វើឲ្យខ្ញុំឈឺស្បូន ដោយសារធ្វើការងារធ្ងន់ធ្ងរបន្ទាប់ពីខ្ញុំឆ្លងទន្លេរួច។ ខ្ញុំបានឲ្យគ្រូខ្មែរអុជពោះរបស់ខ្ញុំ ដើម្បីកាត់បន្ថយការឈឺចាប់។

នៅចុងឆ្នាំ១៩៧៩ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ខ្ញុំបានរៀបការម្តងទៀតជាមួយឈ្មោះរ៉ា ពិន និងសព្វថ្ងៃមានកូនចំនួន៦នាក់ គឺស្រី៤នាក់ និងប្រុស២នាក់។ នៅពេលដែលខ្ញុំសម្រាលកូនម្តងៗ ខ្ញុំត្រូវអុចពោះរបស់ខ្ញុំ ដែលជាហេតុធ្វើឲ្យមានស្នាមរហូតមក។ សព្វថ្ងៃនេះ ខ្ញុំរស់នៅជាមួយកូនប្រុសរបស់ខ្ញុំដែលកើតនៅក្នុងរបបខ្មែរក្រហម។ ប្តីទីមួយរបស់ខ្ញុំបានបាត់ដំណឹង បន្ទាប់ពីខ្ញុំបែកពីគាត់ពេលនៅខេត្តកំពង់ធំ ចំណែកប្តីទីពីររបស់ខ្ញុំបានស្លាប់ចោលខ្ញុំជាង១០ឆ្នាំហើយ។



គោយន្តនៅផ្ទះរបស់ អ៊ិច ហាំ នៅភូមិព្រៃអង្គុញ ឃុំព្រៃកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យ៉ាន់ វ៉ាន់ ៖ អ្នកគ្រប់គ្រងកន្លែងធ្វើប្រហុក

ថុន ស្រីពេជ្រ



យ៉ាន់ វ៉ាន់ រស់នៅភូមិបុស្សីសាញ់ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ យ៉ាន់ វ៉ាន់ ផ្ដល់បទសម្ភាសន៍អំពីរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម ដល់បុគ្គលិកមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង នៅអំឡុងពេលចូលរួមវេទិកាប្រវត្តិសាស្ត្រគ្រួសារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ យ៉ាន់ វ៉ាន់ អាយុ៦៦ឆ្នាំ រស់នៅភូមិបុស្សីសាញ់ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ ឪពុកខ្ញុំឈ្មោះ កៅ យ៉ាន់ ធ្លាប់ធ្វើជាជំទប់ទី១ នៅក្នុងសម័យសង្គមរាស្ត្រនិយម និងម្ដាយឈ្មោះ ជា យឿន គឺជាកសិករ។ ម្ដាយរបស់ខ្ញុំស្លាប់នៅក្នុងរបបខ្មែរក្រហម ដោយសារមិនមានអាហារហូបចុកគ្រប់គ្រាន់ និងមិនមានថ្នាំសង្កូវសម្រាប់ព្យាបាល។ ខ្ញុំមានបងប្អូនចំនួន១១នាក់ ក្នុងនោះស្រីចំនួន៦នាក់ ហើយសព្វថ្ងៃបងប្អូនរបស់ខ្ញុំនៅរស់រានមានជីវិតតែ៣នាក់ប៉ុណ្ណោះ។

ខ្ញុំចូលរៀនដំបូងនៅអាយុ១៨ឆ្នាំ ជាមួយព្រះសង្ឃនៅវត្តសំរោងវត្ត។ ខ្ញុំរៀនជាមួយក្មេងៗឯទៀតអំពីអក្សរសាស្ត្រខ្មែរ លេខនព្វន្ត បូកដក គុណចែក រួមទាំងចំណោទ។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១០។ មកដល់របប លន់ នល់ ខ្ញុំលែងបានរៀនតទៅទៀត ដោយសារនៅក្នុងភូមិចាប់ផ្ដើមមានការទម្លាក់គ្រាប់បែក។ ប្រជាជនតែងនាំគ្នារត់ចូលពួនក្នុងលេណដ្ឋាន ដើម្បីគេចពីការទម្លាក់គ្រាប់បែក។ ផ្ទះសម្បែង សត្វពាហនៈ និងមនុស្សមួយចំនួនបានស្លាប់។ នៅឆ្នាំ១៩៧៥ ពេលខ្មែរក្រហមទទួលជ័យជម្នះទៅលើរបប លន់នល់ ទាំងស្រុង ខ្ញុំត្រូវបានអង្គការបញ្ជូនចូលទៅក្នុងកងពិសេស ដើម្បីធ្វើការងារជីកប្រឡាយ។ ខ្ញុំជីកព្រែក និងប្រឡាយពីឈើទាលដល់បឹងខ្វិ។ ក្រោយពីនេះ ខ្ញុំបានជីកប្រឡាយនៅស្រុកកំចាយមារ។

នៅឆ្នាំ១៩៧៦ ពេលខ្ញុំត្រឡប់មកដល់ភូមិវិញ អង្គការបានផ្សំផ្គុំ និងរៀបការប្រពន្ធឲ្យខ្ញុំ។ ពិធីរៀបការខ្ញុំរៀបចំធ្វើនៅវត្តជីផុច រួមជាមួយគូផ្សេងទៀតសរុបទាំងអស់ចំនួន១៧០គូ មកពីភូមិទាំង១៨ ក្នុងឃុំជីផុច។ ពិធីរៀបការនេះថ្វីត្បិតតែមានច្រើនគូពិតមែន ប៉ុន្តែខ្ញុំសង្កេតឃើញថា មានមនុស្សមិនតិចទេ មិនពេញចិត្តទៅនឹងការផ្សំផ្គុំរបស់អង្គការ ព្រោះពុំបានស្រឡាញ់គ្នា និងពុំដែលធ្លាប់ជួបគ្នាពីមុនមក។ អ្នកខ្លះនៅពេលរៀបការរួចក៏រត់ទៅសម្លាប់ខ្លួន រីឯអ្នកខ្លះទៀតទៅពួនយំមិនឲ្យអង្គការដឹងឡើយ។ នៅក្នុងពិធីរៀបការរបស់ខ្ញុំមិនមានខោអាវថ្មីសម្រាប់ស្លៀកពាក់ទេ។ ខោអាវដែលខ្ញុំស្លៀកក្នុងថ្ងៃរៀបការ គឺខោអាវប្រឡាក់

សុទ្ធតែភក់ៗ ខ្ញុំនិងភរិយាបានប្ដេជ្ញាចំពោះអង្គការថាយើងនឹងស្រឡាញ់គ្នាអស់មួយជីវិត។ បន្ទាប់ពីរៀបការរួចបានរយៈពេល៣ថ្ងៃ ខ្ញុំត្រូវបានកម្មាភិបាលខ្មែរក្រហមហៅឲ្យទៅរៀនវគ្គនយោបាយ និងត្រៀមចូលបម្រើយោធា។ ការរៀនសូត្រនោះខ្មែរក្រហមបណ្ដុះស្មារតីឲ្យក្រុមយោធាមានភាពស្វាហាប់ រឹងមាំក្លាហាន និងមិនខ្លាចក្នុងការចូលប្រយុទ្ធនៅសមរភូមិមុខ បើទោះបីជាមានគ្នាតែ៣នាក់ ក៏មិនរាថយដែរ។ ខ្ញុំត្រៀមខ្លួនរួចជាស្រេច ប៉ុន្តែខ្ញុំមិនដែលបានចូលប្រយុទ្ធនៅក្នុងសមរភូមិឡើយ ព្រោះខ្ញុំត្រូវផ្លាស់មកនៅជិតក្រុងព្រៃវែងដើម្បីមកមើលការខុសត្រូវកន្លែងធ្វើត្រីប្រហុក។ ការមកធ្វើការនៅជិតក្រុងព្រៃវែងនេះ ខ្ញុំមិនដែលមានទំនាស់ជាមួយសមាជិកនៅក្នុងកងឡើយ ខ្ញុំរួសរាយ ខ្ញុំដាក់ខ្លួន និងខិតខំប្រឹងប្រែងធ្វើការងារ។ លើសពីនេះ ខ្ញុំក៏បំពេញចិត្តគណៈស្រុកពាមរក៍ដែលគ្រប់គ្រងនៅទីនោះដែរ។ ជារៀងរាល់ថ្ងៃ ខ្ញុំយកត្រីធំៗបានពីខាងនេសាទ និងបាយដំណើបទៅជូនគណៈស្រុក។

នៅដើមខែមករា ឆ្នាំ១៩៧៩ គណៈស្រុកពាមរក៍ឲ្យខ្ញុំជិះកប៉ាល់ឆ្ពោះទៅកាន់តំបន់ភាគខាងលិច។ កាលនោះខ្ញុំមិនចង់ទៅទេព្រោះខ្ញុំដឹងថានៅទីនោះមានការលំបាកទាំងការងារ ការហូបចុក និងការស្នាក់នៅ ជាពិសេសបើធ្វើការងារមិនល្អនឹងត្រូវនាំខ្លួនយកទៅសម្លាប់ចោល ដូច្នេះខ្ញុំក៏សុំអនុញ្ញាតពីអង្គការត្រឡប់មកផ្ទះវិញ។ នៅពេលមកដល់ឃុំព្រៃឃ្នេស ស្រុកមេសាង ខ្ញុំបានជួបប្រពន្ធរបស់ខ្ញុំ បន្ទាប់មកយើងនាំគ្នាវិលត្រឡប់មកផ្ទះវិញ។ កាលនោះប្រសិនបើខ្ញុំទៅភាគខាងលិច ប្រហែលជាខ្ញុំស្លាប់បាត់ទៅហើយ ព្រោះប្រជាជនភាគច្រើនដែលទៅរស់នៅតំបន់នោះមិនមានជីវិតរស់នៅច្រើនទេ។ ជាក់ស្ដែង ប្រជាជននៅក្នុងភូមិរបស់ខ្ញុំចំនួន៥គ្រួសារ ត្រូវបានខ្មែរក្រហមជម្លៀសទៅតំបន់ភាគខាងលិចបានស្លាប់ស្ទើរទាំងអស់ គឺមានតែម្នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិត ដោយសារតែគាត់ធ្វើពុតជាស្លាប់ នៅពេលកម្មាភិបាលខ្មែរក្រហមបានអារករបស់គាត់ទម្លាក់ចូលទៅក្នុងរណ្ដៅនៅពេលយប់។

ក្រោយមក ខ្ញុំត្រូវបានជ្រើសរើសឲ្យធ្វើជាមេភូមិបុស្សស្រីសាញ់ ហើយខ្ញុំតែងតែចែករំលែករឿងរ៉ាវដែលខ្ញុំឆ្លងកាត់ទៅក្មេងជំនាន់ក្រោយឲ្យបានដឹង និងយកទៅគិតពិចារណា បើទោះជាក្មេងៗទាំងនោះជឿឬពុំជឿក៏ដោយ។ ខ្ញុំចង់ឲ្យយុវជនជំនាន់ក្រោយចេះស្រឡាញ់គ្នា និងកុំយកគំរូតាមការដឹកនាំរបស់ខ្មែរក្រហម ដែលនាំឲ្យមានការកាប់សម្លាប់ និងធ្វើឲ្យបាត់បង់ធនធានមនុស្ស។



យ៉ាន់ រ៉ាន់ ទទួលកញ្ចប់អនុស្សាវរីយ៍ពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# រស់ សៀត ៖ អតីតយុទ្ធនារីខ្មែរក្រហម

គា រស្មី



រស់ សៀត នៅផ្ទះរបស់គាត់ស្ថិតនៅភូមិបុស្សីសាញ់ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ រស់ សៀត ហៅ ហ៊ួយ ភេទស្រី អាយុ៧០ឆ្នាំ សព្វថ្ងៃខ្ញុំរស់នៅ ភូមិបុស្សីសាញ់ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូនសរុបចំនួន៩ នាក់ និងបានចូលបដិវត្តន៍ជាមួយខ្មែរក្រហមចំនួន៤នាក់ នៅក្នុងឆ្នាំ១៩៧០។ បងប្អូនរបស់ខ្ញុំចូលធ្វើបដិវត្តន៍តាមការឃោសនារបស់ តាចង្កូម គឺជាអ្នកមកពីភូមិបឹង ឃុំអំពិលទោល ស្រុកមេសាង។ តាចង្កូម ចូលមកធ្វើទំនាក់ទំនងជាមួយប្រធានសហករណ៍ភូមិបុស្សីសាញ់ឈ្មោះ ឥដ្ឋ និង សាន ដើម្បីស្វែងរកប្រជាជនឲ្យចូលធ្វើបដិវត្តន៍ជាមួយខ្មែរក្រហម។ កន្លែងដែល តាចង្កូម មកឃោសនាគឺនៅផ្ទះមេភូមិ និងនៅវត្ត ហើយពេលខ្លះនៅតាមផ្ទះប្រជាជន។ ប្រជាជននៅក្នុងភូមិខ្ញុំជាច្រើននាក់រួមទាំងបងប្អូនរបស់ខ្ញុំបានចូលរួមដែរ ប៉ុន្តែកាលនោះមិនទាន់ឃើញមានធ្វើសកម្មភាពអ្វីទេ។

នៅចុងឆ្នាំ១៩៧៤ មេឃុំជីផុច ឈ្មោះ មន ប្រាប់ទៅមេភូមិគ្រប់ភូមិប្រកាសស្នើសុំបាយដាក់ស្បោងពីប្រជាជនដោយក្នុងមួយគ្រួសារផ្តល់បាយមួយស្បោងក្នុងមួយថ្ងៃ។ ប្រជាជននៅក្នុងឃុំជីផុច ផ្លាស់វេនគ្នាផ្តល់អាហារឲ្យយោធាខ្មែរក្រហម ដោយធ្វើការផ្លាស់វេនក្នុងមួយថ្ងៃមួយភូមិ រហូតដល់គ្រប់ភូមិទាំងអស់នៅក្នុងឃុំ។ នៅពេលនោះប្អូនរបស់ខ្ញុំ ២ នាក់ស្លាប់នៅពេលដែលចូលធ្វើជាកងទ័ពខ្មែរក្រហម។ បន្ទាប់ពីទទួលបានជ័យជម្នះ នៅឆ្នាំ១៩៧៥ ប្រធានសហករណ៍បញ្ជូនក្រុមរបស់ខ្ញុំឲ្យទៅកាប់ខសយកមកដាក់ក្នុងសហករណ៍។ បន្ទាប់ពីកាប់ខសរួច ប្រធានកងចល័តប្រើក្រុមរបស់ខ្ញុំឲ្យទៅជីកប្រឡាយនៅក្បាលខ្វែកបន្តទៀត។ នៅក្បាលខ្វែក ខ្ញុំនិងមិត្តរបស់ខ្ញុំចំនួន៣នាក់នាំគ្នាលួចរត់មកលេងផ្ទះព្រោះក្រុមរបស់ខ្ញុំនឹកផ្ទះខ្លាំងពេក ប៉ុន្តែត្រូវប្រធានកងចល័តដឹង ហើយជិះកង់តាមចាប់យើងទាំងយប់។ ក្រុមរបស់ខ្ញុំរត់មកដល់ផ្ទះ និងត្រូវក្រោកត្រឡប់ទៅវិញនៅម៉ោង១យប់ដើម្បីឲ្យទាន់ការងារពេលព្រឹក។ លុះម៉ោង១រសៀល ឈ្មោះ ថន គឺជាប្រធានយ ហៅក្រុមរបស់ខ្ញុំទាំង៤នាក់ទៅណែនាំដើម្បីកុំឲ្យខ្ញុំធ្វើបែបនេះទៀត។ ក្រោយពីបញ្ចប់ការងារនៅ ក្បាលខ្វែក អង្គការបញ្ជូនក្រុមកងចល័តនារីរបស់ខ្ញុំទាំងអស់ឲ្យទៅលើកប្រឡាយនៅខាងជើងពានភ្លើង (ស្រុកកំចាយមារ) បន្តរហូតដល់ដើមឆ្នាំ១៩៧៦ ទើបត្រឡប់មកសហករណ៍វិញ។

នៅឆ្នាំ១៩៧៦បន្ទាប់ពីខ្ញុំធ្វើការនៅក្នុងសហករណ៍ភូមិមិនបានប៉ុន្មាន អង្គការបញ្ជូនក្រុមរបស់ខ្ញុំឲ្យទៅធ្វើការនៅពោធិ៍រោង។ កងចល័តរបស់ខ្ញុំបញ្ចប់ការងារនៅពោធិ៍រោងហើយ ក៏ទៅធ្វើការស្រឡូងស្រឡី ហើយចេញពីស្រឡូងស្រឡីទៅលើកព្រែកនៅសំរោងរហូតដល់ខែសីហា ឆ្នាំ១៩៧៦ដដែល ទើបត្រឡប់មកភូមិឫស្សីសាញ់វិញ។ ពេលមកដល់ភូមិប្រធានសហករណ៍បញ្ជូនក្រុមកងចល័តឲ្យទៅជួយស្ទូងស្រូវនៅភូមិស្វាយអណ្ដូង រួចក៏បន្តទៅភូមិត្រពាំងស្គន់ទើបត្រឡប់មកធ្វើការទប់ទឹកនៅជិតភូមិវិញ។ នៅក្នុងភូមិឫស្សីសាញ់ អង្គការប្រើក្រុមខ្ញុំដែលមានសមាជិកចំនួន៨នាក់ ទៅស្ទូងស្រូវ១ហិកតាឲ្យរួចក្នុងមួយថ្ងៃ បើមិនទាន់រួចរាល់ គឺមិនបានអាហារហូបឡើយ។

នៅដើមឆ្នាំ១៩៧៧ អង្គការប្រើកងចល័តនារីទាំងអស់ ឲ្យទៅលើកប្រព័ន្ធភ្លឺស្រែមួយថ្ងៃឲ្យបាន២០ម៉ែត្រ គឺពេលព្រឹក១០ម៉ែត្រ និងពេលរសៀល១០ម៉ែត្រ។ ក្រុមរបស់ខ្ញុំខិតខំធ្វើការដើម្បីឲ្យគ្រប់ផែនការ។ នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៧ ប្រធានសហករណ៍ជ្រើសរើសឈ្មោះរបស់ខ្ញុំឲ្យទៅធ្វើជាទាហាន និងទៅបើកសម្លៀកបំពាក់នៅវត្តចំបក់។ ចេញពីវត្តចំបក់ខ្ញុំនិងមិត្តនារីផ្សេងទៀតបានទៅហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រយោធានៅក្នុងវត្តស្វាយចំនួន៣ខែទៀត។ បន្ទាប់ពីបញ្ចប់ការហ្វឹកហាត់អង្គការបញ្ជូនក្រុមខ្ញុំឲ្យទៅត្រៀមនៅកៅទៃដងក្ដោង ហើយក្រោយមកបញ្ជូនទៅវត្តព្រៃមូល។ ចេញពីវត្តព្រៃមូលអង្គការបញ្ជូនខ្ញុំឲ្យទៅត្រៀមនៅតំបន់២០។ នៅក្នុងតំបន់២០ មានឈ្មោះតា ឆាំ បានបង្ហឹកក្រុមរបស់ខ្ញុំឲ្យបេះគប់គ្រាប់បែក និងគេចខ្លួនពីគ្រាប់បែក រហូតដល់បេះសព្វគ្រប់ទើបបញ្ជូនទៅខាងត្បូងត្រពាំងផ្លុងក្នុងស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។ ខ្ញុំនៅក្នុងកងពលលេខ១៦ ដែលមានទីតាំងឈរជើងនៅទួលសង្កែក្បាលដំរី ជិតច្រកព្រំដែនរំដេង ព្រំប្រទល់កម្ពុជា-វៀតណាម។ តួនាទីរបស់ខ្ញុំនៅព្រំដែន គឺចាំសែងយោធាខ្មែរក្រហមដែលរងរបួសនៅពេលវាយប្រយុទ្ធជាមួយកងទ័ពវៀតណាម។ ខ្ញុំនៅធ្វើការក្នុងកងពលលេខ១៦រហូតដល់ខែមិថុនា ឆ្នាំ១៩៧៨ ទើបមានឈ្មោះ អៀង និងឈ្មោះ លៃ នាំខ្ញុំរត់ត្រឡប់មកវិញ។ នៅតាមផ្លូវត្រឡប់មកវិញ ខ្ញុំត្រូវដើរកាត់ព្រៃ កាត់ភ្នំពីកន្លែងមួយទៅកន្លែងមួយដោយសម្ងាត់បំផុត និងមានយោធាខ្មែរក្រហមនៅខាងស្រុកពញាក្រែកទៅទទួលទៀតផង។ បន្ទាប់មកទៀតខ្ញុំធ្វើដំណើរមកស្រុកមេសាងវិញ។ នៅទីនោះ ប្រធានសហករណ៍បញ្ជូនខ្ញុំឲ្យទៅនៅខាងស្រុកបាភ្នំវិញ ព្រោះប្រជាជននៅក្នុងភូមិឫស្សីសាញ់មិនពេញចិត្តខ្ញុំនិងតាមសម្លាប់ខ្ញុំចោល។ អ្នកដែលបញ្ជូនខ្ញុំទៅបាភ្នំមានឈ្មោះថា ហ៊ាន់, ញ៉ និងឈ្មោះ សេង ហើយអ្នកទាំងនោះត្រូវបានប្រជាជនតាមសម្លាប់បាននៅឃុំបឹងព្រះ ស្រុកបាភ្នំ នៅពេលដែលអ្នកទាំងនោះទៅដល់ឃុំបឹងព្រះបានប្រមាណ៨ថ្ងៃ។ នៅពេលខ្ញុំរស់នៅបាភ្នំក្នុងតំបន់ ២៤ មេទ័ពតំបន់ឈ្មោះ ខិន និង ខិតបានឲ្យខ្ញុំបន្លំខ្លួនធ្វើជាប្រជាជន និងជួយស្ទូងដកអ្នកភូមិក្នុងតំបន់នោះសិនរហូតដល់ស្ថានភាពនៅក្នុងភូមិឫស្សីសាញ់ធម្មតាវិញ។

នៅចុងឆ្នាំ១៩៧៨ ខ្ញុំត្រឡប់ទៅរស់នៅក្នុងភូមិឫស្សីសាញ់វិញ ប៉ុន្តែនៅពេលទៅដល់ផ្ទះ ឈ្មោះ ជន គឺជាប្រធានតំបន់២០ថ្មីហៅខ្ញុំទៅសាកសួរ អំពីមូលហេតុដែលខ្ញុំត្រឡប់មកវិញ រួចហើយបញ្ជូនខ្ញុំឲ្យទៅនៅមន្ទីរពោធិ៍តាមុំ។ នៅមន្ទីរពោធិ៍តាមុំ ខ្ញុំធ្វើការដូចអ្នកទោស ហើយអ្នកគ្រប់គ្រងនៅទីនោះមានឈ្មោះថា ប៊ិច។ ខ្ញុំធ្វើការនៅពោធិ៍តាមុំមិនបានប៉ុន្មានផង ក៏កងទ័ពវៀតណាមវាយចូលមករំដោះប្រជាជន។ នៅពេលមានភាពចលាចល ខ្ញុំលួចរត់ចេញពីមន្ទីរមកផ្ទះវិញ ហើយនាំគ្រួសារភៀសខ្លួនចេញទៅនៅជិតៗភូមិ រហូតដល់ស្ថានភាពធម្មតាទើបនាំគ្នាចូលមកក្នុងភូមិវិញ។ នៅដើមឆ្នាំ១៩៧៩ បន្ទាប់ពីខ្មែរក្រហមដួលរលំ បងប្អូនរបស់ខ្ញុំប្រកបរបរធ្វើស្រែដើម្បីចិញ្ចឹមជីវិត។ សព្វថ្ងៃនេះខ្ញុំរស់នៅជាមួយបងស្រីរបស់ខ្ញុំ ព្រោះយើងទាំងពីរនាក់មិនមានគ្រួសារដូចគ្នា។ ខ្ញុំប្រកបរបរធ្វើស្រែ ដាំដំណាំ និងចិញ្ចឹមសត្វ ប៉ុន្តែទោះបីយ៉ាងណាជីវភាពគ្រួសាររបស់ខ្ញុំក៏មិនសូវជាធូរធារប៉ុន្មានដែរ។

# ប្រជាជនភូមិសំរោងវត្តរួចផុតគ្រប់គ្រាន់ ដោយសារប្រធានសហករណ៍ចិត្តល្អ

**ភា រស្មី**



នី ធុច រស់នៅភូមិសំរោងវត្ត ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ នី ធុច កើតនៅឆ្នាំ១៩៥០ នៅក្នុងភូមិសំរោងវត្ត ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ នី អឹម និងម្តាយឈ្មោះ កែវ ទួន។ ខ្ញុំមានបងប្អូនសរុបទាំងអស់៧ នាក់ ក្នុងនោះមានស្រី៣នាក់ ហើយបច្ចុប្បន្ននៅរស់តែ៤នាក់ប៉ុណ្ណោះ។ នៅក្នុងសម័យសង្គមរាស្ត្រនិយម ឪពុកម្តាយរបស់ខ្ញុំប្រកបរបរធ្វើស្រែ និងធ្វើនំលក់ដើម្បីផ្គត់ផ្គង់ជីវភាព។

នៅអាយុ១២ឆ្នាំ ខ្ញុំចូលរៀននៅសាលាក្នុងវត្តសំរោងវត្ត ជាមួយលោកគ្រូឈ្មោះ អោក ដែលជាព្រះសង្ឃ។ ក្រោយមកទៀត ខ្ញុំបន្តការសិក្សានៅអនុវិទ្យាល័យវត្តថ្មី ស្ថិតនៅម្តុំផ្សាររស្មេហ៍ រហូតដល់ប្រឡងជាប់ចូលរៀននៅវិទ្យាល័យ។ ក្រោយមកដោយសារតែឪពុកម្តាយក្រីក្រគ្មានលទ្ធភាពបង់ថ្លៃសាលា ខ្ញុំបានឈប់រៀនរួចហើយត្រឡប់មកផ្ទះជួយរកស៊ីឪពុកម្តាយវិញ។ នៅក្នុងភូមិសំរោងវត្តខ្ញុំជួយបង្រៀនអក្ខរកម្មចាស់ៗនៅក្នុងភូមិដែលមិនចេះអក្សរ និងធ្វើស្រែ។ នៅសម័យ លន់ នល់ នៅក្នុងភូមិសំរោងវត្តមានការទម្លាក់គ្រាប់បែកចំនួនពីរលើកគឺលើកទី១) ទម្លាក់នៅផ្ទះរបស់លោកគ្រូ អោក អំឡុងពេលដែលចាស់ៗកំពុងរៀនអក្សរបណ្តាលឲ្យមនុស្សស្លាប់ចំនួន២នាក់ និងខូចខាតទ្រព្យសម្បត្តិរបស់ប្រជាជនជាច្រើន។ លើកទី២) ទម្លាក់នៅទួលប្រាសាទជិតភូមិសំរោងវត្ត ប៉ុន្តែមិនមានមនុស្សស្លាប់ទេ។

នៅដើមឆ្នាំ១៩៧៥ ខ្ញុំបានរៀបការជាមួយនារីម្នាក់នៅក្នុងភូមិដែលមានឈ្មោះថា មុជ ហេង។ ការរៀបការរបស់យើងគឺធ្វើឡើងតាមប្រពៃណីជាធម្មតា ព្រោះកាលនោះនៅមានប្រពៃណីនិងសាសនាសម្រាប់គោរពប្រតិបត្តិ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីយោធាខ្មែរក្រហមទទួលបានជ័យជម្នះ ខ្មែរក្រហមបានបញ្ជូនកងចល័តនារី និងកងចល័តបុរស រួមទាំងរូបខ្ញុំឲ្យទៅលើកប្រព័ន្ធភ្លឺស្រែចាប់ពីស្រុកកំចាយមាររហូតមកដល់ស្រុកមេសាង ខេត្តព្រៃវែង។ ក្រោយបញ្ចប់ការលើកប្រព័ន្ធភ្លឺស្រែ ខ្ញុំបានត្រឡប់មករស់នៅជាមួយក្រុមគ្រួសារវិញ ហើយចាប់ផ្តើមចូលធ្វើការក្នុងក្រុមជាងឈើ និងឡើងត្នោត។

នៅចុងឆ្នាំ១៩៧៥ អង្គការបានចាត់តាំងឲ្យក្រុមរបស់ខ្ញុំអារឈើធ្វើតុ ធ្វើកៅអី និងសង់រោងបាយសម្រាប់ហូបអាហាររួមគ្នា។

ចាប់តាំងពីចុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៦ ការងាររបស់ខ្ញុំគឺ ឡើងត្នោត ដាំងឈើ និងធ្វើស្រែបន្តិចបន្តួចប៉ុណ្ណោះ។ នៅឆ្នាំ១៩៧៦ ប្រជាជននៅក្នុងភូមិសំរោងវត្តចាប់ផ្តើមហូបបាយរួមគ្នា ដោយខ្មែរក្រហមបានបែងចែកប្រជាជនឲ្យទៅហូបអាហារតាមរោងបាយចំនួន ៤។ នៅក្នុងភូមិសំរោងវត្តមិនសូវលំបាកក្នុងការហូបចុកប៉ុន្មានទេ ព្រោះប្រធានសហករណ៍ឈ្មោះ រស់ មី តែងតែឲ្យប្រជាជនហូបបាយមួយឆ្អែត។ នៅក្រោមការគ្រប់គ្រងរបស់ មី គឺមិនបានធ្វើបាបប្រជាជនទេ ហើយប្រជាជននៅក្នុងភូមិជាច្រើននាក់គោរពស្រឡាញ់គាត់។ នៅអំឡុងពេលមានព្រឹត្តិការណ៍តាមចាប់ សោ ភីម ប្រធានសហករណ៍នៅតាមភូមិផ្សេងៗមានការផ្លាស់ប្តូរ លើកលែងតែនៅភូមិសំរោងវត្តគឺនៅដដែល។ ចំណែកឯការបញ្ជូនប្រជាជនទៅខេត្តពោធិ៍សាត់ ដែលជាតំបន់ដីខ្លាញ់ គឺមានតែ៣គ្រួសារប៉ុណ្ណោះដែលត្រូវបានខ្មែរក្រហមជម្លៀសពីភូមិសំរោងវត្តទៅរស់នៅទីនោះ។

នៅដើមខែមករា ឆ្នាំ១៩៧៩ ពេលដែលកងទ័ពវៀតណាមវាយចូលមក គ្រួសាររបស់ខ្ញុំរួមជាមួយប្រជាជននៅក្នុងភូមិសំរោងវត្តបានធ្វើដំណើររហូតដល់ភូមិព្រៃឃ្មេស។ គ្រួសាររបស់ខ្ញុំបានស្នាក់នៅភូមិព្រៃឃ្មេសរយៈពេល៣ថ្ងៃ ទើបត្រឡប់មកផ្ទះវិញ ព្រោះខ្ញុំឮដំណឹងថាមានការផ្ទុះអាវុធនៅអ្នកលឿង ហើយប្រទេសក៏ត្រូវបានរំដោះដែរ។ ក្រោយរបបខ្មែរក្រហមដួលរលំភ្លាម គ្រួសាររបស់ខ្ញុំចាប់ផ្តើមធ្វើស្រែ។ បន្ទាប់មក ខ្ញុំយកប្រាក់ដែលសន្សំបានទៅទិញម៉ូតូដើម្បីរត់ឌុប និងដឹកអីវ៉ាន់ពីផ្សារអ្នកលឿងយកមកលក់នៅក្នុងភូមិ។ សព្វថ្ងៃនេះ ខ្ញុំមានកូនសរុបទាំងអស់៦នាក់ ស្លាប់ម្នាក់ ហើយប្រពន្ធរបស់ខ្ញុំក៏ស្លាប់ចោលខ្ញុំដែរ។



សិស្សថ្នាក់បឋមសិក្សានៅក្នុងស្រុកមេសាងចេញពីរៀន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សម្រេចចិត្តចូលបម្រើកងទ័ពព្រោះមិនចង់ឱ្យឪពុកម្ដាយនៅក្នុងភូមិជួបការលំបាក

ថុន ស្រីពេជ្រ



ឡាយ មឿន សព្វថ្ងៃរស់នៅភូមិពន្លៃ ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។
(ដេង ពង្សរ៉ាស៊ី / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឡាយ មឿន អាយុ៧០ឆ្នាំ បច្ចុប្បន្នរស់នៅភូមិពន្លៃ ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូនបង្កើតចំនួន៤នាក់ ប៉ុន្តែបានស្លាប់អស់ចំនួន២នាក់ដោយសារជំងឺ។ កាលពីកុមារ ខ្ញុំមិនបានរៀនសូត្រទេដោយសារជីវភាពខ្វះខាត។ ខ្ញុំនៅផ្ទះជួយធ្វើការងារឪពុកម្ដាយ ឡើងត្នោត និងឃ្វាលគោ ក្របី។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ កងទ័ពរំដោះខ្មែរក្រហមចូលមកឃោសនា និងបានស្នើខ្ញុំឱ្យទៅលើកប្រព័ន្ធភ្លឺស្រែនៅតាមការដ្ឋានក្នុងភូមិ។ រហូតមកដល់ខែវស្សា ឆ្នាំ១៩៧៤ ខ្មែរក្រហមចាប់ផ្ដើមជ្រើសរើសយុវជននៅក្នុងភូមិឲ្យចូលបម្រើកងទ័ព ហើយមេភូមិបានជ្រើសរើសខ្ញុំ។ ខ្ញុំបានយល់ព្រមចូលបម្រើកងទ័ពព្រោះមិនចង់ឲ្យគ្រួសាររបស់ខ្ញុំជាពិសេសឪពុកម្ដាយរបស់ខ្ញុំជួបការលំបាក។ កាលនោះគ្រួសារខ្ញុំត្រូវបានខ្មែរក្រហមចោទថាជាប់និន្នាការ និងសន្តិសម្ព័ន្ធជាមួយខ្មាំង ព្រោះឪពុកម្ដាយខ្ញុំបានរអ៊ូរទាំដាក់អង្គការដែលយកគោ-ក្របីរបស់គាត់ទៅភ្ជួរស្រែរួចហើយមិនឲ្យស៊ីស្មៅ ធ្វើឲ្យគោ-ក្របីរបស់គាត់ស្គមៗ ក្រោយមកបានឮដល់អង្គការ ហើយអង្គការបានយកឪពុកខ្ញុំទៅអប់រំ ឃើញដូច្នេះទើបខ្ញុំសម្រេចចិត្តថា មានតែចូលបម្រើក្នុងជួរកងទ័ពទេ ទើបក្រុមគ្រួសាររបស់ខ្ញុំបានរួចពីការចោទប្រកាន់ និងមិនមានកម្មាភិបាលខ្មែរក្រហមមកធ្វើបាប។

ពេលខ្ញុំចូលបម្រើកងទ័ពដំបូង ខ្ញុំនៅក្នុងអង្គភាពង-៥៩ និងមានស្នាក់ការនៅឃុំសន្លុង ក្នុងស្រុកពញាក្រែក ខេត្តកំពង់ចាម។ នៅទីនោះ ខ្ញុំហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រយោធាផង និងការពារតាមព្រំដែនផង។ ខ្ញុំឈរជើងនៅទីនោះគឺមានគ្រោះថ្នាក់ខ្លាំងណាស់ដោយសារតែនៅជាប់ជាមួយនឹងព្រំដែនប្រទេសវៀតណាម ដែលជាសត្រូវរបស់ខ្មែរក្រហម និងមានការប៉ះទង្គិចគ្នាកើតឡើងជាញឹកញាប់ ហើយការប្រយុទ្ធគ្នាខ្លាំងកើតឡើងនៅចន្លោះពីឆ្នាំ១៩៧៧ ដល់ដើមឆ្នាំ១៩៧៩។ នៅពេលនោះ កងទ័ពខ្មែរក្រហម ខាងភូមិភាគបូព៌ាបានប្រើនូវក្បួនយុទ្ធសាស្ត្រ ដោយបញ្ឆោតឲ្យកងទ័ពវៀតណាមវាយសម្រុកចូលមកដល់ទឹកដីសួងរួចហើយ ប៉ុល ពត បានឲ្យ ខៀវ សំផន ប្រកាសថាវៀតណាមឈ្លានពាន

ទឹកដី បន្ទាប់មកកងទ័ពខាងភូមិភាគបូព៌ាចាប់ផ្តើមបិទច្រក និងវាយកងទ័ពវៀតណាមតែម្តង។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏កងទ័ពភូមិភាគបូព៌ាបានស្លាប់ច្រើននាក់ដែរ។

ខ្ញុំបានរងរបួសនៅពេលចេញប្រយុទ្ធតទល់នឹងកងទ័ពវៀតណាមនៅសមរភូមិ ហើយត្រូវកងទ័ពវៀតណាមបាញ់ត្រូវចំក និងភ្លៅ។ ខ្ញុំសម្រាកព្យាបាលនៅមន្ទីរពេទ្យរយៈពេល១ខែ ទើបបានធូរស្រាល។ ខ្ញុំព្រមទាំងកងទ័ពភូមិភាគបូព៌ាត្រូវបានរំសាយ និងវិលត្រឡប់មកផ្ទះវិញ បន្ទាប់ពីលេខាតំបន់ និងភូមិភាគបូព៌ា ត្រូវបានថ្នាក់លើចោទប្រកាន់ថា ចូលដៃចូលជើងជាមួយវៀតណាម និងបើកផ្លូវឲ្យកងទ័ពវៀតណាមវាយចូលមកប្រទេសកម្ពុជាដែលក្បត់នឹងអង្គការ។ នៅពេលនោះខ្ញុំភិតភ័យខ្លាំងណាស់ ព្រោះមេបញ្ជាការធំៗដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ សោ ភឹម ត្រូវបានអង្គការចាប់យកទៅសម្លាប់ចោលទាំងអស់ ប៉ុន្តែសំណាងល្អ ខ្ញុំមិនត្រូវបានខ្មែរក្រហមចាប់ខ្លួនប្រហារទៅរៀនសូត្រទេ។ នៅពេលខ្ញុំត្រឡប់មកដល់ភូមិពន្លៃវិញ ខ្មែរក្រហមបានរៀបចំពិធីមង្គលការឲ្យខ្ញុំជាមួយនឹងប្រពន្ធរបស់ខ្ញុំឈ្មោះ កែប សាម៉ែន ហើយដំណាលគ្នាដែរ ខ្មែរក្រហមក៏រៀបចំការឲ្យប្រជាជនដទៃទៀតសរុបទាំងខ្ញុំ មានចំនួន៣៦គូ។

បន្ទាប់ពីខ្ញុំរៀបការបានរយៈពេលមួយសប្តាហ៍ នៅខែវិច្ឆិកា ឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសប្រជាជននៅក្នុងភូមិពន្លៃ ព្រមទាំងក្រុមគ្រួសាររបស់ខ្ញុំឲ្យទៅរស់នៅភូមិភាគពាយ័ព្យ។ ខ្ញុំនិងអ្នកឯទៀតបានធ្វើដំណើរដោយថ្មើរជើងទៅអ្នកលឿង រួចឡើងជិះកប៉ាល់ដែលមានលេខសម្គាល់៤២។ កប៉ាល់បានបើកទៅឈប់នៅច្រាំងបាក់ ស្ថិតនៅក្នុងសង្កាត់ច្បារអំពៅ ក្រុងភ្នំពេញ។ ពេលទៅដល់ទីនោះ ខ្មែរក្រហមឲ្យប្រជាជនឈប់សម្រាកហូបបាយ បន្ទាប់មកនៅវេលាម៉ោង៩យប់ ក៏ឲ្យប្រជាជនឡើងជិះរថភ្លើងបន្តទៀត។ នៅក្នុងទូរថភ្លើងនោះមានប្រជាជនជម្លៀសប្រមាណ២០០នាក់ ប៉ុន្តែគ្មាននរណាម្នាក់ហ៊ានមាត់ឡូឡា ប្តូរដែកគ្នាឡើយ។ ខ្ញុំធ្វើដំណើរតាមរថភ្លើងមួយយប់ ហើយនៅថ្ងៃបន្ទាប់ទើបទៅដល់ស្រុកមោងឫស្សី ខេត្តបាត់ដំបង។ ប្រជាជនជួបការលំបាកដោយសារមិនមានបាយហូប។ នៅទីនោះ ប្រពន្ធរបស់ខ្ញុំត្រូវបានអង្គការស្នើឲ្យច្រូតស្រូវ ចំណែកខ្ញុំត្រូវទៅធ្វើការនៅក្នុងកងចល័ត ធ្វើស្រូវច្រាំង និងឃ្វាលគោក្របី។

ខ្ញុំនៅធ្វើការនៅស្រុកមោងឫស្សីរហូតដល់របបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ទើបខ្ញុំសុំរថយន្តកងទ័ពវៀតណាមជិះមកដល់អ្នកលឿង រួចហើយខ្ញុំដើរត្រឡប់មកផ្ទះនៅភូមិពន្លៃវិញ។ ក្រោយមក ខ្ញុំត្រូវបានជ្រើសរើសឲ្យធ្វើជាប្រធានក្រុមប្រវាស់ដៃ និងដឹកនាំប្រជាជនចំនួន១២នាក់ធ្វើស្រែ។ សព្វថ្ងៃ ខ្ញុំនិងប្រពន្ធមានកូនប្រុសស្រីចំនួន១០នាក់ និងរស់នៅដោយសុភមង្គលជាមួយជីវភាពសមរម្យ។



ផ្លូវលំនៅក្នុងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ (ដេង ពងរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# យ៉ាន់ យួន ៖ កងសែងយុទ្ធជនខ្មែរក្រហមដែលរងរបួស

ភា រស្មី



យ៉ាន់ យួន អាយុ៦៧ឆ្នាំ សព្វថ្ងៃរស់នៅឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

យ៉ាន់ យួន ភេទស្រី អាយុ៦៧ឆ្នាំ បានរៀបរាប់ថា ខ្ញុំកើតនៅភូមិស្វាយយា ឃុំស្វាយយា ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ ខ្ញុំមានឪពុកឈ្មោះ សៅ យ៉ាន់ និងម្ដាយឈ្មោះ ង្លួន ផាង ព្រមទាំងមានបងប្អូន៩នាក់ ក្នុងនោះប្រុស២នាក់។ នៅអាយុ១៣ឆ្នាំ ខ្ញុំបានចូលរៀនថ្នាក់អក្ខរកម្មនៅវត្តស្វាយយា ជាមួយព្រះសង្ឃ។ បន្ទាប់ពីឈប់រៀន ខ្ញុំបានជួយឃ្វាលគោក្របី និងធ្វើស្រែចម្ការឪពុកម្ដាយរបស់ខ្ញុំ។ នៅឆ្នាំ១៩៧១ ពេលខ្ញុំអាយុ១៧ឆ្នាំ ខ្ញុំបានរៀបការជាមួយប្ដីឈ្មោះ មាស ហាត់ និងបានផ្លាស់ទៅរស់នៅជាមួយប្ដីនៅភូមិអង្គ្រង ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែងវិញ។ ប្ដីរបស់ខ្ញុំកាលនោះធ្វើជាសេនាជននៅក្នុងភូមិអង្គ្រង ហើយពេលទំនេរគាត់ធ្វើស្រែចម្ការដើម្បីចិញ្ចឹមគ្រួសារ។

នៅចុងឆ្នាំ១៩៧២ ខ្ញុំបានសម្រាលកូនទីមួយរបស់ខ្ញុំនៅផ្ទះ។ បន្ទាប់ពីឆ្លងទន្លេបានប្រមាណ ២ខែ ប្រធានភូមិបានស្នើសុំឲ្យក្រុមមីងៗទៅជួយសែងកងទ័ពរំដោះខ្មែរក្រហមរងរបួសនៅពេលឡើងទៅវាយជាមួយកងទ័ពរដ្ឋការ លន់ នល់ នៅសមរភូមិព្រៃទប់ និងស្ពានត្រាំក្នុងខេត្តស្វាយរៀងយកទៅព្យាបាលនៅមន្ទីរពេទ្យដែលមានទីតាំងស្ថិតនៅក្នុងវត្តបន្ទាយ។ ចន្លោះឆ្នាំ១៩៧២ដល់ឆ្នាំ១៩៧៣ មានការប្រយុទ្ធគ្នាយ៉ាងខ្លាំងរវាងកងទ័ពរដ្ឋការ ជាមួយកងទ័ពរំដោះខ្មែរក្រហម។ កាលនោះ ក្រុមសែងកងទ័ពរងរបួស

របស់ខ្ញុំមានគ្នា១០នាក់ ស្រីចំនួន៥នាក់ និងប្រុសចំនួន៥នាក់ៗ ក្រុមរបស់ខ្ញុំ បានទៅទទួលកងទ័ពរងរបួសពីភូមិសូ យកមកឲ្យប្រជាជននៅក្នុងភូមិក្ដីស្លា ដើម្បីសែងបន្តទៀតៗ ការសែងអ្នករបួសនេះបញ្ចប់ទៅនៅត្រឹមឆ្នាំ១៩៧៤ ព្រោះកងទ័ព លន់ នល់ បានចាញ់សង្គ្រាមនៅខេត្តស្វាយរៀងៗ ចាប់ពីឆ្នាំ១៩៧៤ នៅក្នុងភូមិអង្គ្រងចាប់ផ្ដើមធ្វើស្រែប្រវាស់ដៃ និងចាប់ផ្ដើមប្រមូលរបស់របរប្រជាជនដាក់ជារបស់រួមៗ

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញជាច្រើននាក់ ត្រូវបានខ្មែរក្រហមជម្លៀសមករស់នៅក្នុងភូមិអង្គ្រងៗ ប្រជាជន ១៧ មេសា មួយចំនួនដែលមានចំណេះដឹងត្រូវបានអង្គការយកទៅរៀនសូត្រ ហើយអ្នកដែលនៅសេសសល់មួយចំនួនត្រូវបានអង្គការតាមដានបន្តទៀតៗ ខ្ញុំចាំបានថា ដំបូងអង្គការបានជ្រើសរើសប្រជាជនដែលទើបជម្លៀសមកពីទីក្រុងភ្នំពេញឲ្យបង្រៀនអក្សរដល់ប្រជាជននៅក្នុងភូមិ ទាំងចាស់ ទាំងក្មេង ហើយខ្ញុំក៏បានចូលរៀនដែរៗ សាលារៀននៅពេលនោះមាន៣កម្រិតគឺ ថ្នាក់រៀនសម្រាប់កុមារ គឺគ្រូបង្រៀននៅពេលព្រឹក, ថ្នាក់រៀនសម្រាប់យុវជន-យុវនារី គឺគ្រូបង្រៀននៅពេលថ្ងៃ និងថ្នាក់រៀនសម្រាប់មីងៗនិងពូៗ គឺគ្រូបង្រៀននៅពេលថ្ងៃដូចគ្នាៗ ខ្ញុំរៀនបានប្រមាណ៣ទៅ៤ខែ អង្គការក៏បញ្ជូនលោកគ្រូអ្នកគ្រូទាំងអស់នោះទៅរៀនសូត្រអស់ៗ ខ្ញុំរៀនបណ្ដើរ និងធ្វើការងារបុកស្រូវបណ្ដើរដើម្បីយកអង្ករដាក់ក្នុងរោងបាយ ព្រោះនៅក្នុងភូមិអង្គ្រងប្រជាជនចាប់ផ្ដើមហូបបាយរួមៗ ខ្ញុំត្រូវបុកស្រូវក្នុងមួយថ្ងៃឲ្យបាន ៥តៅ ដើម្បីយកអង្ករដាក់ក្នុងរោងបាយរួមៗ អ្នកបុកស្រូវក្នុងរោងបាយរួមមួយមានសមាជិកចំនួន៣នាក់ៗ ខ្ញុំបានធ្វើការនេះរហូតដល់ខ្ញុំឆ្លងទន្លេកូនទី២របស់ខ្ញុំ នៅឆ្នាំ១៩៧៦ៗ

បន្ទាប់ពីឆ្លងទន្លេរួច អង្គការបានអនុញ្ញាតឲ្យខ្ញុំឈប់សម្រាកចំនួន១ខែ ដើម្បីឲ្យខ្ញុំមានសុខភាពរឹងមាំ មុនពេលចុះទៅច្រូតស្រូវបន្តនៅក្បែរៗភូមិៗ នៅពេលច្រូតស្រូវ ខ្ញុំអាចឡើងមកបំបៅដោះកូនរបស់ខ្ញុំបាននៅពេលដែលកូនរបស់ខ្ញុំឃ្លានខ្លាំងៗ នៅពេលដែលផុតរដូវច្រូតកាត់ អង្គការបានឲ្យក្រុមមីងៗនិងខ្ញុំ ទៅដងទឹកយកមកស្រោចដំណាំរបស់ប្រជាជនដែលដាំនៅតាមផ្ទះៗ

នៅចុងឆ្នាំ១៩៧៨ អង្គការបានកត់ឈ្មោះគ្រួសាររបស់ខ្ញុំដើម្បីជម្លៀសទៅខេត្តពោធិ៍សាត់ ប៉ុន្តែដោយសារតែខ្ញុំឈឺពោះឆ្លងទន្លេកូនទី៣ របស់ខ្ញុំ ទើបខ្ញុំសុំពន្យារពេលមួយរយៈ និងចាំទៅលើកក្រោយៗ ខ្ញុំឆ្លងទន្លេបានរយៈពេល២ខែ ស្រាប់តែអង្គការឲ្យប្រជាជនទាំងអស់ជម្លៀសទៅខេត្តភាគខាងលិច ហើយខ្ញុំនិងគ្រួសារបានធ្វើដំណើរទៅដល់ភ្នំឈើកាច់ៗ

នៅដើមខែមករា ឆ្នាំ១៩៧៩ គ្រួសាររបស់ខ្ញុំបានត្រឡប់មកភូមិស្រុកវិញ និងបានប្រកបរបរធ្វើស្រែចម្ការបន្តទៀតដើម្បីចិញ្ចឹមជីវិតៗ ក្រោយមកនៅឆ្នាំ២០១១ ប្ដីរបស់ខ្ញុំបានស្លាប់ដោយសារជំងឺបេះដូងៗ ខ្ញុំរស់នៅជាមួយកូនៗចំនួន៧ នាក់ ក្នុងនោះមានកូនស្រី១នាក់ៗ សព្វថ្ងៃ ខ្ញុំរស់នៅជាមួយកូនប្រុសពៅរបស់ខ្ញុំ ចំណែកកូនផ្សេងទៀតបានរៀបការ និងមានគ្រួសារបែកផ្ទះរៀងៗខ្លួនអស់ហើយៗ



ផ្លូវលំក្នុងស្រុកមេសាង ខេត្តព្រៃវែងៗ
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឈា សុខឿន៖ នារីពេទ្យឃុំសម័យខ្មែរក្រហម

*ភា រស្មី*



*ឈា សុខឿន នៅផ្ទះរបស់គាត់ ស្ថិតនៅភូមិកែវស្នា ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ (ភា រស្មី/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅឆ្នាំនេះ ឈា សុខឿនមានអាយុជិត៧០ឆ្នាំហើយ។ គាត់មិនសូវមានពេល ទំនេរនៅផ្ទះ ឡើយ ព្រោះគាត់មានភារកិច្ចសំខាន់មួយចំនួនដែលកំពុងអនុវត្តនៅក្នុងភូមិ ឃុំ របស់គាត់។ សុខឿន ក្រៅពីជួយរៀបចំម្ហូបអាហារសម្រាប់ចង្ហាន់ប្រគេនព្រះសង្ឃនៅក្នុងវត្តគាត់គឺជាជំនួយការរបស់ក្រុមគ្រូពេទ្យឃុំ។ សុខឿន បានអប់រំអ្នកភូមិឲ្យយល់ដឹងអំពីសារសំខាន់នៃការប្រើប្រាស់មន្ទីរពេទ្យសម្រាប់ថែរក្សាសុខភាពផ្ទាល់ខ្លួន។ សុខឿនមានសុខភាពល្អ និងរឹងប៉ឹងដូចពេលដែលគាត់ស្ថិតក្នុងវ័យក្មេងអញ្ចឹង។ កាលពីទសវត្សរ៍ឆ្នាំ១៩៧០ សុខឿន គឺជាកម្មាភិបាលនារីភូមិកែវស្នា គឺជាកម្មាភិបាលពេទ្យឃុំព្រៃឃ្នេស និងជាអ្នកដែលអង្គការចាត់តាំងជាខ្មែររំដោះប្រចាំឃុំព្រៃឃ្នេសដែលទុកចិត្តក្នុងការសម្រេចបញ្ជូនយុវជន និងយុវនារី នៃឃុំព្រៃឃ្នេសឲ្យចូលបម្រើបដិវត្តន៍។ សុខឿនបានត្អូញត្អែរថាគាត់សោកស្តាយចំពោះការចំណាយពេលវេលាចូលបម្រើបដិវត្តន៍របស់គាត់នាពេលកន្លងមក។ ខាងក្រោមនេះ គឺជាសម្តីរបស់ សុខឿន ដែលបាននិយាយប្រាប់ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង អំពីបទពិសោធន៍របស់គាត់៖

«ខ្ញុំឈ្មោះ ឈា សុខឿនអាយុ៦៧ឆ្នាំ។ សព្វថ្ងៃ ខ្ញុំរស់នៅភូមិកែវស្នា ឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។ នៅក្នុងឆ្នាំ១៩៧០ បន្ទាប់ពីមានរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ខ្ញុំសម្រេចចិត្តចូលធ្វើជាកងឈ្លបនៅក្នុងភូមិកំណើតរបស់ខ្ញុំ ដើម្បី

ទាមទារឲ្យសម្ដេចឪ ឡើងគ្រប់គ្រងអំណាចវិញ និងដើម្បីការពារប្រជាជននៅក្នុងភូមិ។ ក្រុមរបស់ខ្ញុំមានសមាជិកចំនួន១២នាក់។ ម៉ន និង សារ៉ាត គឺជាអ្នកគ្រប់គ្រងក្រុមកងឈ្លប។ ពួកយើងគឺជាកម្លាំងជួរមុខដែលត្រៀមខ្លួនគ្រប់ពេលសម្រាប់ការស្ម័គ្រចិត្តចូលធ្វើជាយោធា។ ក្រុមកងឈ្លបទាំងអស់ត្រូវឲ្យចូលរៀនវគ្គនយោបាយនៅពេលយប់ ដូចប្រជាជនឯទៀតដែរ។ យើងរៀនអំពី«គោលមាគ៌ាសង្គ្រាមប្រជាជន»។ ក្រោយពីរៀនសូត្រវគ្គនយោបាយ តួនាទីរបស់យើងជាកងឈ្លប គឺដើរមើល យាមកាម និងស៊ើបយកការណ៍ពីប្រជាជននៅក្នុងភូមិអំពីសកម្មភាពធ្វើទំនាក់ទំនងក្បត់ ប្លន់ស្រូវអង្ករ និងសត្វចិញ្ចឹមផ្សេងៗទៅឲ្យខាង លន់ នល់ យកទៅរាយការណ៍ឲ្យប្រធានសហករណ៍បានដឹង។ នៅឆ្នាំ១៩៧២ ម៉ន និងសារ៉ាត បានបញ្ជូនសមាជិកក្រុមរបស់ខ្ញុំមួយចំនួន ឲ្យចូលបម្រើជាយោធា ដើម្បីប្រយុទ្ធជាមួយ ទាហាន លន់ នល់។ ចំណែកខ្ញុំ ត្រូវបានផ្លាស់ប្ដូរឲ្យទៅគ្រប់គ្រងកងយុវនារីភូមិជំនួសវិញ។ ខ្ញុំមានតួនាទីជាអនុប្រធានកងនារី មានភារកិច្ចគ្រប់គ្រង និងមើលការខុសត្រូវនារីៗនៅក្នុងភូមិកែវស្នា ការការពារសន្តិសុខរបស់ប្រជាជននៅក្នុងភូមិ និងជ្រើសរើសនារីៗឲ្យចូលបម្រើជាយោធា។ ក្នុងពេលដែលខ្ញុំធ្វើជាអនុប្រធានកងនារីភូមិ ខ្ញុំនិងមិត្តនារីពីរនាក់ទៀត ត្រូវថ្នាក់លើចាត់តាំងឲ្យចូលរៀនវិជ្ជាពេទ្យ ដើម្បីចូលបម្រើការជាកម្មាភិបាលពេទ្យនៅមន្ទីរពេទ្យភូមិស្វាយជោរ ឃុំព្រៃឈ្នេស។ ខ្ញុំរៀនពេទ្យអស់រយៈពេលបីខែជាមួយគ្រូពេទ្យជំនាញនៅក្នុងឃុំព្រៃឈ្នេស។ នៅខែដំបូង ខ្ញុំរៀនផ្សំថ្នាំ រៀនចំណាំឈ្មោះថ្នាំ និងរៀនចាក់ថ្នាំលើខ្មើយ។ នៅខែទីពីរនិងទីបី ខ្ញុំចេញទៅព្យាបាល និងចាក់ថ្នាំឲ្យប្រជាជននៅក្នុងឃុំជាមួយគ្រូពេទ្យជំនាញប្រចាំឃុំព្រៃឈ្នេស។ ខ្ញុំសប្បាយចិត្តក្នុងការធ្វើការងារនេះខ្លាំងណាស់ ព្រោះខ្ញុំគិតថា ខ្ញុំធ្វើឲ្យប្រទេសជាតិមានសុខសន្តិភាព និងប្រជាជនមានសុខភាពល្អ។

នៅឆ្នាំ១៩៧៣ រហូតដល់ថ្ងៃជ័យជម្នះ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំចូលបម្រើការជាកម្មាភិបាលពេទ្យប្រចាំព្រៃឈ្នេសពេញលេញ។ តួនាទីរបស់ខ្ញុំគឺព្យាបាលប្រជាជនក្នុងឃុំ។ មុនដំបូង ការព្យាបាលគឺប្រើប្រាស់ថ្នាំពេទ្យដែលបានមកពីការរៃអង្គាសលុយពីអ្នកភូមិយកទៅ ទិញថ្នាំពីស្រុកមេសាង។ បន្ទាប់មក ការព្យាបាលគឺប្រើប្រាស់ថ្នាំបុរាណ ថ្នាំឫសឈើជំនួសវិញ។

បន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥មក ខ្ញុំនៅតែធ្វើជាកម្មាភិបាលពេទ្យប្រចាំការនៅក្នុងឃុំព្រៃឈ្នេសដដែល។ ការហូបចុកនៅពេលនោះ គឺខ្វះខាតខ្លាំងណាស់។ របបអាហារតិចទៅៗ។ ម្នាក់ៗទទួលបានអង្ករតែពីរខាំកន្ទះប៉ុណ្ណោះក្នុងមួយថ្ងៃ។ ប្រជាជនចាប់ផ្ដើមខ្វះខាតស្បៀងអាហារក្នុងការហូបចុក ហើយក៏មានជំងឺរាតត្បាតច្រើនទៀត ដូចជាជំងឺគ្រុនចាញ់ រាកមូល និងក្ដៅខ្លួនជាដើម។ ខ្ញុំនៅព្យាបាលជំងឺអ្នកទាំងនោះគ្មានពេលទំនេរឡើយ។

នៅឆ្នាំ១៩៧៧ ខ្ញុំសុំប្រធានសហករណ៍ចុះទៅធ្វើការនៅតាមការដ្ឋានវិញម្ដង ព្រោះខ្ញុំគិតថាខ្ញុំអាចស្គាល់កន្លែងផ្សេងៗ និងអាចទទួលបានរបបអាហារគ្រាន់បើជាងនៅក្នុងសហករណ៍។ អង្គការបានយល់ព្រម និងបានបញ្ជូនខ្ញុំទៅកាន់មូលដ្ឋានកៅទែក្នុងតួនាទីជាអ្នកព្យាបាលជំងឺឲ្យក្រុមកងចល័តដែលបំពេញភារកិច្ចលើកសណ្ដូរទឹក (ទំនប់ទឹក) និងមើលការខុសត្រូវពីសុខភាពកងចល័តនារីៗ។ ក្រោយមក អង្គការបញ្ជូនខ្ញុំឲ្យទៅធ្វើការនៅក្នុងមូលដ្ឋានស្រែជម្រៅបន្តទៀត ក្នុងតួនាទីដដែល។ នៅស្រែជម្រៅ ខ្ញុំត្រូវរបួសភ្នែក ដោយគ្រាប់កាំភ្លើងរបស់កងទ័ពវៀតណាម។ ខ្ញុំដឹងរឿងរ៉ាវជាច្រើនទាក់ទងនឹងការប្រយុទ្ធគ្នា និងផែនការគប់គ្រាប់បែកសម្លាប់កងចល័តក្នុងពេលបំពេញការងារនៅកន្លែងលើកទំនប់ទឹកនៅស្រែជម្រៅ។ ផែនការនេះ បានបែកការណ៍ ហើយពុំមាននរណាម្នាក់ចូលក្នុងការដ្ឋានលើកសណ្ដូរនេះទៀតទេ។

ដោយសារខ្ញុំត្រូវរបួស អង្គការបានបញ្ជូនខ្ញុំឲ្យមកព្យាបាលខ្លួននៅក្នុងភូមិវិញនៅឆ្នាំ១៩៧៨។ ពេលមកដល់សហករណ៍ ខ្ញុំឃើញយោធាខ្មែរក្រហមមកពីភូមិភាគនិរតី កំពុងបញ្ជូនឲ្យប្រជាជនជីករណ្ដៅ

ជាច្រើននៅភូមិកែវស្នា ដោយមិនប្រាប់ពីមូលហេតុនៃការជីកឡើយ។ ខ្ញុំបានឮដំណឹងមិនច្បាស់ការថា ការជីករណ្ដៅទាំងនេះគឺសម្រាប់ត្រៀមទុកសម្លាប់ប្រជាជន។ គ្រាន់តែឮដំណឹងនេះ ខ្ញុំនិងមិត្តនារីពេទ្យផ្សេងទៀតបានត្រៀមថ្នាំទុកសម្រាប់សម្លាប់ខ្លួនឯងរួចជាស្រេច ប៉ុន្តែក្រោយមក យើងមិនបានលេបថ្នាំសម្លាប់ខ្លួនឡើយ។

នៅដើមខែមករា ឆ្នាំ១៩៧៩ ខ្ញុំធ្វើដំណើរចេញពីភូមិទាំងជើងនៅឈើ ព្រោះកងទ័ពវៀតណាមជិតចូលមកដល់ឃុំព្រៃឃ្នេស។ ខ្ញុំធ្វើដំណើរទៅដល់ឃុំបារាជ រៀបនឹងធ្វើក្បូនឆ្លងទឹកទៅបន្តទៀត ក៏ត្រូវកងទ័ពវៀតណាមតាមទាន់ ហើយកងទ័ពវៀតណាមទាំងនោះបានប្រាប់ខ្ញុំឲ្យវិលត្រឡប់មកភូមិកំណើតវិញ។

បន្ទាប់ពីខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំក៏បានចូលធ្វើការស្ម័គ្រចិត្តនៅក្នុងឃុំព្រៃឃ្នេសបន្តទៀត គឺនៅក្នុងក្រុមទ្រទ្រង់សុខភាព ដើម្បីណែនាំប្រជាជនឲ្យមកព្យាបាលជំងឺនៅមណ្ឌលសុខភាព រួមទាំងការឆ្លងទន្លេ។ ក្នុងឆ្នាំ១៩៨២ ខ្ញុំរៀបការជាមួយបុរសម្នាក់នៅក្នុងភូមិ និងបានរស់នៅជាមួយគ្នារហូតមានកូន៥នាក់។ ប៉ុន្តែ ឥឡូវកូនរបស់ខ្ញុំស្លាប់អស់៣នាក់ហើយ។ ជាចុងក្រោយខ្ញុំមានការសោកស្ដាយខ្លាំងណាស់ដែលបានចូលបម្រើការងារឲ្យខ្មែរក្រហម ព្រោះខ្ញុំចង់ឲ្យប្រទេសមានសន្តិភាព និងយុត្តិធម៌ ប៉ុន្តែអង្គការធ្វើឲ្យប្រទេសធ្លាក់ក្នុងសង្គ្រាម និងកាប់សម្លាប់ជីវិតមនុស្សអស់ជាច្រើននាក់»។



ទេសភាពវាលស្រែ ស្ថិតនៅឃុំព្រៃឃ្នេស ស្រុកមេសាង ខេត្តព្រៃវែង។
(ដេង ពង្សរ៉ាស៊ី/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# រស់ ទូច ៖ អតីតប្រធានក្រសួងវប្បធម៌

## ភូមិភាគបូព៌ាដែលបានចូលរួមប្រជុំជាមួយ សោ ភឹម

ថុន ស្រីពេជ្រ



រស់ ទូច កើតនៅឆ្នាំ១៩៤១ សព្វថ្ងៃរស់នៅ ភូមិបុស្សសាញ់ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស្ថិតនៅក្រោមផ្ទះដែលមានដំបូលប្រក់ក្បឿងតូចល្មម ក្នុងសម្លៀកបំពាក់អាវដៃខ្លីពណ៌ស និងខោសាច់ក្រណាត់ពណ៌ក្រម៉ៅ រស់ ទូច ភេទប្រុស កើតនៅឆ្នាំ១៩៤១ រស់នៅភូមិបុស្សសាញ់ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង បានផ្តល់បទសម្ភាសន៍មកកាន់ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ថា នៅឆ្នាំ១៩៧៦ មុនពេលអង្គការ (ខ្មែរក្រហម) ចាប់ផ្តើមបង្កើតសហករណ៍កម្រិតខ្ពស់ អង្គការស្នើខ្ញុំឲ្យទៅរៀនអំពីសហករណ៍កម្រិតខ្ពស់អស់រយៈពេល ៣ខែ មុននឹងផែនការទាំងនោះត្រូវបានដាក់ចេញមកអនុវត្តនៅតាមភូមិស្រុក។ ក្រោយរៀនចប់ អង្គការឃើញថា ខ្ញុំគឺជាមនុស្សដែលមានចំណេះដឹង និងអាចទុកចិត្តបានក៏ចាត់តាំងឲ្យខ្ញុំធ្វើជាប្រធានក្រសួងវប្បធម៌នៅឆ្នាំ១៩៧៦។

នៅឆ្នាំ១៩៧៨ ខ្ញុំនិងកម្មាភិបាលគ្រប់ជាន់ថ្នាក់ ព្រមទាំងគណៈស្រុកជាច្រើនមកពីតំបន់និងភូមិភាគបូព៌ាទាំងមូល បានទៅចូលរួមការប្រជុំដ៏ធំមួយតាមការកោះហៅរបស់ សោ ភឹម លេខាភូមិភាគបូព៌ា ដែលមានទីតាំងស្ថិតនៅភូមិស្វាយរមាស ក្រុងព្រៃវែង ជាមួយនឹងសម្លៀកបំពាក់ថ្មី និងក្រមាបង់កថ្មី ដែលអង្គការបានចែកឲ្យខ្ញុំ និងគាត់ ដែលជាចៅហ្វាយស្រុកមេសាង។ ខ្ញុំបានធ្វើដំណើរមកប្រជុំដោយជិះរទេះសេះ រីឯ សោ ភឹម បានជិះឡានអាកាត់សង់ត្រេដើម្បីមកប្រជុំ។ ឡានរបស់ សោ ភឹម បានបញ្ចេះចោលរហូត ព្រោះគាត់ដឹងថាការមកប្រជុំនេះនឹងមានសភាពការណ៍មិនល្អឡើយ។ ប៉ុន្តែទោះយ៉ាងណា ការប្រជុំនេះគឺបានធ្វើឡើងដោយបើកចំហព្រមទាំងនិយាយវាយប្រហារដល់របបដឹកនាំរបស់ ប៉ុល ពត ថែមទៀត។

នៅក្នុងអង្គប្រជុំ សោ ភឹម បានលើកឡើងថា ការអនុវត្តនូវរបបសព្វថ្ងៃនេះ គឺពុំត្រឹមត្រូវនិងពុំដូចអ្វីដែលគាត់ចង់បានឡើយ។ ប្រជាជនទទួលបានរបបអាហារមិនគ្រប់គ្រាន់ ធ្វើការច្រើន ប៉ុន្តែបានហូបតិច ពេលឈឺមិនមានថ្នាំសង្កូវដើម្បីព្យាបាល រីឯសម្លៀកបំពាក់ក៏មិនមានគ្រប់គ្រាន់។ ដូច្នេះរបបនេះមិនល្អទេ ហើយមានប្រជាជនច្រើនណាស់ដែលបានស្លាប់។ យើងម្នាក់ៗ ត្រូវមានវិចារណញ្ញាណ គិតឲ្យបានវែងឆ្ងាយ។ បន្ទាប់មក សោ ភឹម ក៏បានស្រែកនូវសុភាសិតដៀមដាមទៅកាន់របបដឹកនាំរបស់ ប៉ុល ពត នូវសុភាសិតមួយឃ្លាថា «ដំរីយោ មហារុងរឿង រុះផ្ទះ

ក្បឿង ធ្វើផ្ទះស្លឹក ជ័យោ មហាសន្ទឹក រុះផ្ទះស្លឹកធ្វើទ្រុងជ្រូក ជ័យោ មហាទុក្ខសោក រុះទ្រុងជ្រូកធ្វើឈ្នាងនង្គ័ល ជ័យោ មហាដោះទាល់ យកឈ្នាងនង្គ័លទៅដុតនឹងចង្ក្រាន»។ សុភាសិតត្រូវបានស្រែកដំណាលគ្នាពេញទាំងសាលប្រជុំ។ ការប្រជុំនេះអាចថា ជាការប្រជុំលើកចុងក្រោយរបស់ សោ ភឹម។ មុននឹងមកប្រជុំនេះ សោ ភឹម បានត្រៀមកម្លាំងទុករួចជាស្រេច ប្រសិនបើកើតសភាពការណ៍មិនស្រួល។

ពេលចប់ប្រជុំ សោ ភឹម ក៏បានចាប់ដៃចៅហ្វាយស្រុកនានា ហើយនិយាយពាក្យផ្តាំផ្ញើបន្តិចបន្តួច រួចគាត់ក៏ត្រឡប់ទៅវិញ។ ខ្ញុំគិតថាសភាពការណ៍ដូចជាមិនសូវស្រួល ចំពោះការប្រជុំដោយបើកចំហបែបនេះ ហើយ ៣ថ្ងៃ ក្រោយមក អង្គការបានតាមចាប់ខ្លួន សោ ភឹម ដែលធ្វើឲ្យស្ថានការណ៍កាន់តែយ៉ាប់យ៉ឺន។

អ្នកដែលមានវត្តមាននៅក្នុងកម្មវិធីប្រជុំទាំងប៉ុន្មាន ភាគច្រើនត្រូវអង្គការហៅទៅរៀនសូត្រជាបន្តបន្ទាប់ ហើយមិនដែលឃើញត្រឡប់មកវិញទេ។ អ្នកដែលខ្ញុំស្គាល់មាន តាហ៊ាន, តាម៉ន គឺជាមេឃុំ, តាជ្រង គឺជាគណៈឃុំ ត្រូវអង្គការយកទៅសម្លាប់ទាំងអស់ នៅរស់តែ សឿន ដែលកាន់ខាងក្រសួងកសិកម្ម។ បន្ទាប់ពីប្រធានតំបន់ត្រូវចាប់ខ្លួនសួរចម្លើយនិងសម្លាប់ និងការស្លាប់របស់ សោ ភឹម នៅក្នុងភូមិឃុំស្រុកខេត្តព្រៃវែងទាំងមូលត្រូវផ្លាស់មេដឹកនាំថ្មី ហើយជំនួសដោយកម្មាភិបាលនិងយោធាមកពីភូមិភាគនិរតី។ កម្មាភិបាលនិងយោធាមកពីភូមិភាគនិរតីបានគំរាមឲ្យអ្នកដែលនៅក្រោមបង្គាប់ សោ ភឹម ទាំងអស់ទម្លាក់អាវុធចុះហើយព្រមប្រគល់ខ្លួនឲ្យអង្គការ ដោយមិនមានសិទ្ធិតវ៉ា ឬបញ្ចេញមតិទាំងអស់។ ចំណែកខ្ញុំ ត្រូវបានខ្មែរក្រហមចោទប្រកាន់ថា គឺជា ក.ស.ប ក្បត់នឹងអង្គការ។ ជាសំណាងរបស់ខ្ញុំពេលនោះ ខ្ញុំមិនត្រូវខ្មែរក្រហមយកទៅសម្លាប់ ហើយអាចរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃ។

ខ្ញុំមិនពេញចិត្តរបប ប៉ុល ពត ដែលបានប្រព្រឹត្តមកលើប្រជាជនទេ។ របបនេះមិនឲ្យប្រជាជនហូបឆ្អែត មិនមានសម្លៀកបំពាក់ បិទសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ រឿងរ៉ាវទាំងអស់នេះក្មេងជំនាន់ក្រោយគួរចងចាំឲ្យច្បាស់ និងគិតពិចារណាទៅលើរបបនេះ តើសង្គមមួយណាល្អ និងសង្គមមួយណាមិនល្អ ជាពិសេសសូមកុំយកគំរូតាមរបបដឹកនាំខ្មែរក្រហម។ ខ្ញុំមិនចង់ឲ្យរបបនេះ វិលត្រឡប់មកវិញទេ។



រស់ ទូច ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់ ដេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យ៉ុន យ៉ាង ៖ កងនេសាទ

ថុន ស្រីពេជ្រ



យ៉ុន យ៉ាង រស់នៅឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ យ៉ុន យ៉ាង អាយុ៦៥ឆ្នាំ បច្ចុប្បន្នគឺជាកសិករ រស់នៅឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ ពេលអាយុ១២ឆ្នាំ ខ្ញុំចូលរៀននៅវត្តសំរោង ប៉ុន្តែខ្ញុំរៀនសូត្រមិនបានជ្រៅជ្រះទេ ដោយសារតែមានសង្គ្រាមកើតឡើងនៅជិនាន់លន់នល់។ នៅគ្រានោះមានការទម្លាក់គ្រាប់បែកជាច្រើនកន្លែង នៅខាងលិចវត្តជីផុច បណ្តាលឲ្យមនុស្សចំនួន២នាក់ស្លាប់ភ្លាមៗ។

នៅចុងឆ្នាំ១៩៧០ ខ្ញុំស្ម័គ្រចិត្តចូលធ្វើជាកងឈ្លបខ្មែរក្រហម ដោយមានប្រធានកងផលិតឈ្មោះ នី សារ៉ុម គឺជាអ្នកកត់ត្រាឈ្មោះ និងទទួលស្គាល់ខ្ញុំ។ ខ្ញុំត្រូវដើរមើលការខុសត្រូវប្រជាជននៅតាមភូមិ និងត្រូវរាយការណ៍អំពីសកម្មភាពរបស់ប្រជាជននៅក្នុងភូមិទៅកាន់ថ្នាក់លើ។ ក្រោយមកខ្ញុំត្រូវបានឈ្មោះ នី សារ៉ុម ប្រធានផលិតដកខ្ញុំចេញដោយសារតែខ្ញុំមិនបានរាយការណ៍អំពីសកម្មភាពលួចដាំបបររបស់ម្តាយខ្ញុំប្រាប់ទៅកាន់ថ្នាក់លើ។

ក្រោយពីឈប់ពីការងារកងឈ្លប ខ្ញុំត្រូវបានបញ្ជូនឲ្យទៅធ្វើនីរសាររបស់តំបន់វិញ ដោយខ្ញុំធ្វើការងារចែកសំបុត្រនៅក្នុងភូមិ។ ជារៀងរាល់ថ្ងៃ ខ្ញុំជិះសេះពីភូមិមួយទៅភូមិមួយដើម្បីយកសំបុត្រទៅប្រគល់ឲ្យឃុំ និងយកសំបុត្រពីឃុំមកកាន់ភូមិវិញ។ ក្រៅពីជិះសេះរត់សំបុត្រតាមភូមិ ខ្ញុំត្រូវដើរមើលប្រជាជនដែលកំពុងតែធ្វើការងារ រួចរាយការណ៍អំពីសកម្មភាពទាំងអស់នោះប្រាប់ទៅកាន់ថ្នាក់លើឃុំ។

ក្រោយថ្ងៃយោធាខ្មែរក្រហមទទួលជ័យជម្នះ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានផ្លាស់ទៅធ្វើការខាងផ្នែកនេសាទ នៅអ្នកលឿង។ ខ្ញុំមិនសូវបានសម្រាកភ្នែកទេ ដោយសារតែត្រូវងើបមើលត្រីជាប់សំណាញ់ជាញឹកញាប់។ ត្រីដែលខ្ញុំរកបាន ខ្ញុំយកត្រីមួយចំនួនទៅចែកចាយតាមសហករណ៍ ស្រុក និងខេត្តនានា។ ចំណែកត្រីដែលនៅសេសសល់ ខ្ញុំយកទៅធ្វើជាត្រីប្រហុក និងរម្ងាស់ធ្វើជាទឹកត្រី សម្រាប់ចែកទៅសហករណ៍ ភូមិ ឃុំ ស្រុក និងខេត្ត។ យូរៗម្តង ខ្ញុំលួចផ្ញើទឹកត្រីទៅឲ្យគ្រួសាររបស់ខ្ញុំ។

នៅឆ្នាំ១៩៧៥ អង្គការរៀបការឲ្យខ្ញុំជាមួយប្រពន្ធរបស់ខ្ញុំឈ្មោះ ភួន ហើយពេលខ្ញុំរៀបការនោះមានតែ៣គូប៉ុណ្ណោះ។ ខ្ញុំនិងប្រពន្ធរបស់ខ្ញុំរស់នៅជាមួយគ្នាបានរយៈពេលតែ៣ថ្ងៃប៉ុណ្ណោះ ប្រពន្ធរបស់ខ្ញុំក៏ស្លាប់ដោយសាររន្ទះបាញ់។ មកដល់ឆ្នាំ១៩៧៧ អង្គការបានរៀបការឲ្យខ្ញុំជាមួយនឹងប្រពន្ធទីពីរទៀត ហើយយើងបានរស់នៅជុំគ្នារហូតមកដល់សព្វថ្ងៃ។ បន្ទាប់ពីរៀបការរួច អង្គការស្នើខ្ញុំឲ្យទៅធ្វើស្រែនៅក្នុងបរិវេណវត្តជីផុច។ នៅទីនោះ ការងាររបស់ខ្ញុំកាន់តែលំបាកជាងពេលមុនទៅទៀត ពិសេសគឺមិនមានអាហារហូបចុកគ្រប់គ្រាន់។ ខ្មែរក្រហមបានប្រើខ្ញុំឲ្យជីកក្របីឲ្យស៊ីស្មៅ ភ្ជួរស្រែ និងរែកសំណាប។ នៅពេលមានផែនការបន្ទាន់ ខ្ញុំត្រូវធ្វើការរហូតដល់ម៉ោង២រំលងអធ្រាត្រទើបបានសម្រាក ព្រោះខ្ញុំត្រូវតែបញ្ចប់ការងារឲ្យរួចរាល់។ លុះដល់ម៉ោង៥ភ្លឺស្រាងៗ ខ្ញុំត្រូវងើបឡើងដើម្បីដឹកក្របីឲ្យស៊ីស្មៅបន្តទៀត។ ថ្ងៃខ្លះខ្ញុំសម្រាកបានតែ៣ម៉ោងប៉ុណ្ណោះ។

នៅដើមខែមករា ឆ្នាំ១៩៧៩ ខ្មែរក្រហមបញ្ជូនខ្ញុំឲ្យទៅកាន់តំបន់ភាគខាងលិចដើម្បីទៅធ្វើការនៅទីនោះ។ ប៉ុន្តែខ្ញុំបានស្នើសុំកម្មាភិបាលខ្មែរក្រហមត្រឡប់មករស់នៅភូមិកំណើតវិញ ព្រោះខ្ញុំឮថាប្រជាជនដែលបានត្រូវខ្មែរក្រហមបញ្ជូនទៅខេត្តភាគខាងលិច ត្រូវបានកម្មាភិបាលខ្មែរក្រហមនៅទីនោះធ្វើបាប និងយកទៅសម្លាប់ចោល។



យ៉ុន យ៉ាង (រូបខាងស្តាំ) ផ្តល់បទសម្ភាសន៍អំពីរឿងរ៉ាវក្នុងរបបខ្មែរក្រហមដល់លោក ផេង ពង្សរ៉ាស៊ី និងក្រុមការងារមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង ក្នុងឱកាសចូលរួមវេទិកាប្រវត្តិសាស្ត្រគ្រួសារ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅខេត្តពន្លៃ

ថុន ស្រីពេជ្រ



មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានធ្វើវេទិកាអប់រំសហគមន៍ ដើម្បីពិភាក្សាអន្តរជំនាន់រវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុចាប់ពី៥០ឆ្នាំ ជាមួយសិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយមកពីអនុវិទ្យាល័យ និងវិទ្យាល័យផ្សេងគ្នាក្នុងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទិវានៃការចងចាំអំពើប្រល័យពូជសាសន៍នៅកម្ពុជា ខិតជិតចូលមកដល់ ហើយរដ្ឋាភិបាលកំពុងតែរៀបចំទីកន្លែងដើម្បីរំឭកនៃការចងចាំជាបណ្តើរៗនៅស្តូបនៃខេត្តព្រៃវែង។ ប្រជាជនដែលមានអាយុចាប់ពី៥០ឆ្នាំឡើង នៅចងចាំមិនភ្លេចចំពោះរបប ៣ឆ្នាំ ៨ខែ ២០ថ្ងៃនេះ។ ដូច្នេះហើយបានជាមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានធ្វើវេទិកាអប់រំសហគមន៍នេះឡើង ដើម្បីពិភាក្សាអន្តរជំនាន់រវាងអ្នករស់រានមានជីវិត ដែលមានអាយុចាប់ពី៥០ឆ្នាំ ជាមួយសិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយមកពីអនុវិទ្យាល័យ និងវិទ្យាល័យផ្សេងគ្នាក្នុងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ វេទិកានេះបានផ្តោតសំខាន់ទៅលើការរំឭកឡើងវិញពី «ការបង្កើតសហករណ៍ខ្មែរក្រហម និងឈ្វេងយល់ពីទុក្ខលំបាក ការសម្លាប់ និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងសម័យនោះ ដែលជាផលប៉ះពាល់បន្ទាប់ពីការបង្កើតសហករណ៍»។ វេទិកានេះត្រូវបានរៀបចំឡើង នាព្រឹកថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣



មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានធ្វើវេទិកាអប់រំសហគមន៍ ដើម្បីពិភាក្សាអន្តរជំនាន់រវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុចាប់ពី៥០ឆ្នាំ ជាមួយសិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយមកពីអនុវិទ្យាល័យ និងវិទ្យាល័យផ្សេងគ្នាក្នុងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងបរិវេណវត្តពន្លៃ ស្ថិតនៅភូមិពន្លៃ ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង ដោយមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១០នាក់ និងសិស្សដែលជាយុវជនជំនាន់ក្រោយចំនួន២០នាក់ មកចូលរួម។

នៅវេលាម៉ោង៩៖៣០នាទីព្រឹក លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំអំពើប្រល័យពូជសាសន៍នៅកម្ពុជា បានណែនាំខ្លួនក្រុមការងារ និងបង្ហាញអំពីការិយាល័យមជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាកន្លែងតម្កល់ទុកឯកសារខ្មែរក្រហមជិត១លានទំព័រ ដែលជាឯកសារក្រដាស ។ ក្រៅពីនេះមាន ឯកសារសម្ភាសន៍អ្នករស់រានមានជីវិតនៅតាមស្រុកភូមិ ឯកសាររូបថតនៅក្នុងសម័យខ្មែរក្រហម ឯកសារទាក់ទងរណ្តៅសាកសព ទីតាំងសម្លាប់ និងឯកសារខ្សែភាពយន្តនៅក្នុងរបបខ្មែរក្រហម និងក្រោយសម័យខ្មែរក្រហម។ បន្ទាប់មកលោក នាយ ឆ្នួយ ប្រធានភូមិពន្លៃមានមតិស្វាគមន៍ និងបើកដំណើរការកម្មវិធី។

ជាកិច្ចបន្តលោក ផេង ពង្សរ៉ាស៊ី បានធ្វើបទបង្ហាញខ្លីស្តីអំពីការបង្កើតសហករណ៍ បុជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងរបបខ្មែរក្រហម។ ការបង្កើតសហករណ៍នេះ គឺជាការបង្កើតឲ្យមានការកាប់សម្លាប់ ការធ្វើទារុណកម្ម ការអត់ឃ្លាន ការធ្វើការងារពលកម្មធ្ងន់ធ្ងរ ការបាក់កម្លាំង ការបែកបាក់ក្រុមគ្រួសារ ការខ្វះខាតថ្នាំសង្កូវដើម្បីព្យាបាល ការបំបិទសិទ្ធិសេរីភាព និងការដកហូតទ្រព្យសម្បត្តិឯកជន។

ជាមួយគ្នានេះ អ្នករស់រានមានជីវិតឈ្មោះ ស្រី សំអាន បានឡើងមានប្រសាសន៍អំពីទំនាក់ទំនងគ្នារវាងសម័យខ្មែរក្រហម និងសម័យបច្ចុប្បន្ន ដែលជាសង្គមពីរខុសប្លែកគ្នា។ «បច្ចុប្បន្នប្រជាជនរស់នៅមានសិទ្ធិសេរីភាពអាចដើរទៅណាមកណាបានដោយសេរី ហើយរស់នៅដោយមិនមានភាពភ័យខ្លាច។ ផ្ទុយមកមើលសម័យខ្មែរក្រហម ក្នុងរយៈពេល៣ឆ្នាំ៨ខែ២០ថ្ងៃ បានសម្លាប់មនុស្សជាង២លាននាក់។ សំអាន បានបន្ថែមថា ប្រទេសដទៃក៏បានធ្វើបដិវត្តន៍ដូចប្រទេសកម្ពុជាយើងដែរ ដូចជា ប្រទេសវៀតណាម ប៉ុន្តែមិនបានសម្លាប់មនុស្សដូចរបបនេះឡើយ។ សព្វថ្ងៃនេះប្រទេសកម្ពុជាមានសន្តិភាពពេញលេញ មានទីផ្សារ និងមានការលក់ដូរ។ ចំណែកវិស័យសំណង់ និងប្រព័ន្ធអប់រំក៏មានការរីកចម្រើនដែរ។ សិស្សានុសិស្សសម័យឥឡូវរៀនបានខ្ពង់ខ្ពស់ខុសប្លែកពីសិស្សសម័យខ្មែរក្រហម ដែលមិនបានរៀនសូត្រ។ នៅក្នុងរបបខ្មែរក្រហមសិស្សានុសិស្សណាចង់បានសញ្ញាបត្រត្រូវទៅយកនៅវាលស្រែ។ ដូច្នេះចៅៗទាំងអស់គ្នាគួរចងចាំ និងត្រូវមានស្មារតីកុំយកគំរូតាមសម័យកាលនៃរបបខ្មែរក្រហម»។

អ៊ំប្រុស ប៊ិនតូម បានមានប្រសាសន៍ថា «នៅពេលដែល ប៉ុល ពត ចូលមកភូមិ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅលើកដីនៅកំចាយមារ ដែលកាលនោះមិនទាន់ហូបបាយរួមទេ។ អស់រយៈពេល៤ខែ ទើបអង្គការរំសាយអង្គភាពរបស់ខ្ញុំ និងឲ្យខ្ញុំវិលត្រឡប់មកផ្ទះវិញ។ ពេលមកដល់ផ្ទះ ខ្ញុំបានដឹងថាប្អូនស្រីរបស់ខ្ញុំបានស្លាប់ ហើយម្តាយបានឈឺ។ ខ្ញុំមិនអាចសម្រាកនៅផ្ទះបានយូរថ្ងៃទេ ព្រោះអង្គការបានប្រើខ្ញុំឲ្យធ្វើការងារបន្តទៀត។ លើកនេះខ្ញុំត្រូវបែកពីឪពុកម្តាយ

និងគ្រួសារទៀត។ ខ្មែរក្រហមប្រើខ្ញុំដូចគោ ដូចក្របី ប៉ុន្តែមិនបានផ្តល់អាហារឲ្យហូបចុកគ្រប់គ្រាន់ឡើយ។ មួយថ្ងៃៗខ្ញុំហូបតែសម្លគល់ចេក។ ដូច្នេះសូមឲ្យចៅៗចងចាំជានិច្ចថា របប៣ឆ្នាំ ៨ខែ២០ថ្ងៃ នេះមិនបានចម្រើនដល់ប្រទេសយើងទេ មានតែការកាប់សម្លាប់ប្រជាជនអស់ជាច្រើននាក់។

អ៊ុំស្រី ហែម សៀ បានរៀបរាប់ថា ដូចជារូបខ្ញុំ អង្គការបានហៅឲ្យទៅច្រូតស្រូវ។ ខ្ញុំហូបបាយរួមជាមួយប្រជាជនឯទៀត។ នៅសម័យនោះតឹងតែងខ្លាំងណាស់។ បើយើងឈឺគ្រុនផ្តាសាយគឺមិនមានថ្នាំអ្វីគ្រប់គ្រាន់ដើម្បីព្យាបាលទេ ហើយត្រូវបានអង្គការលួចតាមដានទៀតថា យើងឈឺពិតមែនឬអត់។ អង្គការបានធ្វើទុក្ខបុកម្នេញមកលើបងប្អូនយើង។ ជួនកាលយើងមិនបានបង្កើតឲ្យមានកំហុសផង ក៏អង្គការចោទថាមានទោសកំហុសដែរ ហើយយកទៅរៀនសូត្រ និងសម្លាប់ដោយគ្មានញញើតដៃ។

ក្រោយស្តាប់ការចែករំលែកពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរួចមក លោក ដេង ពង្សរ៉ាស៊ី បានលើកទឹកចិត្តឲ្យសិស្សានុសិស្សទាំងអស់ ពេលដែលត្រឡប់ទៅផ្ទះវិញ សូមអានសៀវភៅប្រវត្តិ-សាស្ត្រខ្មែរក្រហមឲ្យបានច្រើន និងសួរនាំបទពិសោធន៍លោកតាលោកយាយរបស់ខ្លួនដែលឆ្លងកាត់របបខ្មែរក្រហមបន្ថែមទៀត។ មុននឹងបញ្ចប់ ការពិភាក្សាជាអន្តរជំនាន់បានបញ្ចប់នៅវេលាម៉ោង១១៖៣០នាទី





មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានធ្វើវេទិកាអប់រំសហគមន៍ ដើម្បីពិភាក្សាអន្តរជំនាន់រវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុចាប់ពី៥០ឆ្នាំ ជាមួយសិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយមកពីអនុវិទ្យាល័យ និងវិទ្យាល័យផ្សេងគ្នាក្នុងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ព្រឹក លោក ផេង ពង្សរ៉ាស៊ី ក៏បានលើកឡើងអំពីកីឡាប្រកួតស៊ីហ្គេម លើកទី៣២ ដែលប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះ ។ លោក ផេង ពង្សរ៉ាស៊ី បានបន្ថែមថា រាល់ប្រភេទកីឡាទាំងអស់នៅស៊ីហ្គេម និងនៅក្នុងប្រទេសដទៃ ប្រទេសកម្ពុជារបស់យើងក៏មានប្រភេទកីឡានោះដែរ។ ប្រទេសកម្ពុជាយើងទើបតែរួចផុតពីរបបខ្មែរក្រហម ប៉ុន្តែវិស័យកីឡាហាក់មានការរីកចម្រើនៗ ប្រទេសយើងអាចយកបានមេដាយមាសជូនជាតិគួរជាទីពេញចិត្ត និងមានមោទកភាព។ រហូតមកដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣នេះ ប្រទេសកម្ពុជា ឈរនៅលេខរៀងទី២បន្ទាប់ពីប្រទេសវៀតណាម។

លោកអាចារ្យនៃវត្តពន្លៃដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក៏បានទៅមើលកីឡាប្រកួត ស៊ីហ្គេម នៅទីលានផ្ទាល់ ព្រោះគាត់យល់ថា កីឡាស៊ីហ្គេម ពិតជាមានសារសំខាន់ចំពោះប្រទេសរបស់យើង។ គាត់គិតថានេះជាឱកាសតែម្តងគត់សម្រាប់គាត់។ ដូច្នេះ សូមប្រជាជនទាំងអស់ចូលរួមទស្សនាការផ្សាយបន្តផ្ទាល់រហូតដល់ចប់កម្មវិធី ព្រោះជាមុខជាមាត់នៃប្រទេសរបស់យើង និងលើកទឹកចិត្តដល់កីឡាកររបស់យើងទាំងអស់គ្នា។

ជាចុងក្រោយ លោក នាយ ឆួយ ប្រធានភូមិពន្លៃឡើងនិយាយបិទកម្មវិធី និងផ្តាំផ្ញើទៅកាន់សិស្សានុសិស្សទាំងអស់ឲ្យយកចិត្តទុកដាក់ចំពោះការរៀនសូត្រ និងអានសៀវភៅដែល មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងចែកឲ្យ ដូចជា សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទស្សនាវដ្តីស្វែងរកការពិត។

## ចំណាប់អារម្មណ៍សិស្ស

ខ្ញុំឈ្មោះ សុភ័ក្ត្រ ស្រីពេជ្រ ភេទស្រី អាយុ១៨ឆ្នាំ គឺជាសិស្សនៃវិទ្យាល័យអង្គរស ថ្នាក់ទី១២។ ខ្ញុំមានអារម្មណ៍ថាសប្បាយចិត្ត នៅពេលបានឃើញលោកតាលោកយាយដែលជាសាក្សីរស់បានមកចែករំលែកបទពិសោធន៍ទៅកាន់ក្មេងៗជំនាន់ក្រោយដូចជារូបខ្ញុំ។ ខ្ញុំមានអារម្មណ៍អាណិតអាសូរនិងយល់ពីទុក្ខលំបាករបស់គាត់ក្នុងរបប ប៉ុល ពត។ ជាចុងក្រោយ ខ្ញុំសូមសំណូមពរឲ្យមានការបន្តបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីកុំឲ្យកូនខ្មែរជំនាន់ក្រោយភ្លេច និងចងចាំពីរបបនេះជារៀងរហូត។ ខ្ញុំនឹងយកចំណេះដឹងពីការរៀនសូត្រនេះដើម្បីអភិវឌ្ឍន៍ប្រទេសជាតិនាពេលខាងមុខ និងទប់ស្កាត់កុំឲ្យរបបកម្ពុជាប្រជាធិបតេយ្យកើតឡើងសាជាថ្មីម្តងទៀត។



មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានធ្វើវេទិកាអប់រំសហគមន៍ ដើម្បីពិភាក្សាអន្តរជំនាន់រវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុចាប់ពី៥០ឆ្នាំ ជាមួយសិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយមកពីអនុវិទ្យាល័យ និងវិទ្យាល័យផ្សេងគ្នាក្នុងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# យុវជនជំនាន់ក្រោយយល់ដឹងកាន់តែច្បាស់អំពីការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅរបស់ខ្មែរក្រហម

## បន្ទាប់ពីទស្សនកិច្ចសិក្សាទីតាំងសម្លាប់មនុស្ស និងតម្កល់អដ្ឋិធាតុទួលជ្រៃ

ភា រស្មី



សិស្សានុសិស្សមកពីវិទ្យាល័យមេសាងទស្សនកិច្ចទីតាំងសម្លាប់មនុស្ស និង តម្កល់អដ្ឋិធាតុទួលជ្រៃ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដឹកនាំសិស្សានុសិស្សចំនួន៣៣នាក់ ក្នុងចំណោមនោះស្រី១៥នាក់ ទស្សនកិច្ចសិក្សាទៅកាន់កន្លែងតម្កល់អដ្ឋិធាតុជនរងគ្រោះក្នុងរបបខ្មែរក្រហមមួយកន្លែង ស្ថិតនៅក្នុងបរិវេណវត្ត ទួលជ្រៃ ក្នុងភូមិទួលជ្រៃ ឃុំបាបោង ស្រុកពាមរក៍ ខេត្តព្រៃវែង ដែលមានចម្ងាយ ប្រមាណ ២៥ គីឡូម៉ែត្រពីទីរួមខេត្តព្រៃវែង តាមកំណាត់ផ្លូវជាតិលេខ១១ ឆ្ពោះទៅកាន់ទីប្រជុំជនអ្នកលឿង។ ការធ្វើទស្សនកិច្ចសិក្សានេះ គឺដើម្បីឆ្លើយតបទៅនឹងសំណួររបស់ក្មេងប្រុសម្នាក់ឈ្មោះ ហ៊ាប សំណាង ជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យ មេសាង ដែលបានសួរថា «តើសកម្មភាពក្នុងរបបខ្មែរក្រហមនៅតាមមូលដ្ឋាន ពិតដូចការរៀបរាប់នៅក្នុងសៀវភៅ ប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យដែរឬទេ? សំណួរនេះបានបង្ហាញពីអារម្មណ៍និងភាពមិនទាន់ជឿជាក់ច្បាស់ក្នុងចិត្តនៅឡើយថា តើពិតជាមានអំពើព្រៃផ្សៃកើតមាននៅក្នុងរបបខ្មែរក្រហមដែរឬយ៉ាងណា។

អំឡុងពេលនោះ លោក ផេង ពង្សរ៉ាស៊ី ដែលជាគ្រូទេសក្នុងកម្មវិធីវេទិកាថ្នាក់រៀនចុងសប្តាហ៍ បានពន្យល់លម្អិតទាក់ទងនឹងព្រឹត្តិការណ៍សំខាន់ៗ ដែលកើតមានក្នុងរបបខ្មែរក្រហម ព្រមទាំងបានលើកឧទាហរណ៍មួយចំនួនស្តីពីការជួបសម្ភាសន៍



សិស្សានុសិស្សមកពីវិទ្យាល័យមេសាងទស្សនកិច្ច ទីតាំងសម្លាប់មនុស្ស និង តម្កល់អដ្ឋិធាតុទួលជ្រៃ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





និងសាច់រឿងរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ប្រាប់ទៅកាន់សិស្សានុសិស្ស។ ដើម្បីឲ្យយុវជនឈ្មោះ សំណាង ឈ្វេងយល់កាន់តែច្បាស់ពីរឿងរ៉ាវកើតមានក្នុងប្រទេសកម្ពុជាចន្លោះឆ្នាំ ១៩៧៥ ដល់ ១៩៧៩ លោក ដេង ពង្សរ៉ាស៊ី សន្យាថានឹងនាំ សំណាង និងយុវជនទាំងអស់ ទៅជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងទៅពិនិត្យមើលដោយផ្ទាល់ភ្នែកនូវទីតាំងតម្កល់អដ្ឋិធាតុជនរងគ្រោះ ដែលបានស្លាប់ក្នុងរបបខ្មែរក្រហមនៅទួលជ្រៃ។ ក្រោយមក ក៏មានដំណើរទស្សនកិច្ចនេះឡើង ដោយមានការអញ្ជើញអ្នករស់រានមានជីវិតចំនួនប្រាំនាក់ មករៀបរាប់ពីបទពិសោធន៍របស់ខ្លួនឆ្លងកាត់របបខ្មែរក្រហម និងប្រវត្តិទីតាំងទួលជ្រៃ ដែលជាទីតាំងសម្លាប់មនុស្សរបស់ខ្មែរក្រហម ប្រាប់ដល់សិស្សានុសិស្សទាំងនោះ។

ពេលមកដល់ទួលជ្រៃ យុវជនទាំងអស់ ខ្លះឈរ ខ្លះអង្គុយ ស្តាប់យ៉ាងយកចិត្តទុកដាក់ចំពោះរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងឈ្វេងយល់កាន់តែច្បាស់ថែមទៀតពីព្រឹត្តិការណ៍ដែលបានកើតឡើងនៅទីនេះ។ អាចារ្យវត្តទួលជ្រៃឈ្មោះ សុខ យាង បានរៀបរាប់យ៉ាងលម្អិតពីរឿងរ៉ាវដែលបានកើតឡើងនៅបរិវេណភូមិទួលជ្រៃតាំងពីឆ្នាំ១៩៧០ គឺក្រោយពេលកើតមានព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ រហូតដល់ចុងឆ្នាំ១៩៧៨។ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមម្នាក់ទៀតឈ្មោះ ឡុក រៀបរាប់ពីជីវិតដ៏លំបាកនៅក្នុងរបបខ្មែរក្រហម និងប្រាប់ពីហេតុការណ៍ដែលគាត់បានឃើញផ្ទាល់ភ្នែកនូវសាកសពមនុស្សយ៉ាងច្រើន និងរណ្តៅសាកសពពាសពេញនៅលើទួលជ្រៃ។ ឡុក បានបន្ថែមថា លោកយាយតែងតែឃើញស្រស់ៗនូវព្រលឹងសាកសពមនុស្សដែលស្លាប់នៅទួលជ្រៃ និងបានបញ្ជាក់ថា ព្រលឹងទាំងនោះហាក់

តាមថែរក្សាជីវិតរបស់គាត់ទៀតផង។ ឡុក បានមករស់នៅលើទីទួលជ្រែងដំបូងគេក្រោយឆ្នាំ១៩៧៩។ មុនដំបូងគាត់មានអារម្មណ៍ខ្លាចខ្មោចដែរ ប៉ុន្តែក្រោយមកពេលដែលគាត់ខស្សាហ៍ឃើញវិញ្ញាណនៅនឹងភ្នែកញឹកញាប់ពេក ទើបគាត់លែងខ្លាចខ្មោចរហូតមកដល់សព្វថ្ងៃនេះ។

ចំណែក អាចារ្យវត្តទួលជ្រែម្នាក់ទៀត ឈ្មោះ ទេព កុនបានយំសោកនៅចំពោះមុខសិស្សានុសិស្សដោយសារគាត់បាត់បង់សាច់ញាតិបងប្អូនរបស់គាត់ទាំងអស់នៅ ទួលជ្រែនេះ។ គាត់មិនបានរៀបរាប់ច្រើនក្រៅពីនេះទេ ដោយសារតែគាត់រន្ធត់និងសោកសង្រេងង។ សូមបញ្ជាក់ថា ទួលជ្រែគឺជាទីទួលមួយដែលពុំមានមនុស្សរស់នៅឡើយកាលពីមុនរបបខ្មែរក្រហម។ មានតែផ្ទះរបស់អ្នកភូមិមួយចំនួនតូចប៉ុណ្ណោះដែលស្ថិតនៅក្បែរទីទួលនេះកាលពីរបបលន់ នល់។ នៅក្នុងរបបខ្មែរក្រហម ទីទួលនេះបានប្រែក្លាយទៅជាកន្លែងកប់សាកសពទាហាន លន់ នល់, សាកសពយោធា និងកម្មាភិបាលខ្មែរក្រហមជំនាន់សោ ភឹម និងសាកសពប្រជាជនដែលត្រូវខ្មែរក្រហមសម្លាប់ពីបទប្រព្រឹត្តកំហុសតិចតួចដូចជាលួចអាហារហូបជាដើម។

ក្រោយឆ្នាំ១៩៧៩ រណ្តៅកប់សាកសពស្ទើរតែទាំងអស់ត្រូវបានប្រជាជនគាស់ដើម្បីរកមាស និងវត្ថុមានតម្លៃដែលស្ថិតនៅជាប់នឹងខោអាវសាកសព។ ឆ្អឹងសាកសពជាច្រើនត្រូវបានលើកចេញពីរណ្តៅ និងនាំយកមកដាក់តម្កល់នៅក្នុងវត្តពាម ដែលស្ថិតនៅចម្ងាយប្រមាណពីរគីឡូម៉ែត្រពីទីទួលនេះ។ ដោយសារតែខ្វះការថែទាំ អដ្ឋិធាតុភាគច្រើន ត្រូវបានបំផ្លាញដោយសត្វពាហនៈ និងមនុស្ស ហើយអដ្ឋិធាតុមួយចំនួនតូចដែលនៅសេសសល់ ត្រូវនាំយកមកដាក់តម្កល់នៅក្នុងចេតិយមួយនៅក្នុងបរិវេណវត្តទួលជ្រែ បន្ទាប់ពីវត្តនេះត្រូវបានកសាងឡើងនៅឆ្នាំ២០១៣។ ហ៊ាប សំណាង បានស្តាប់យ៉ាងយកចិត្តទុកដាក់។ យុវជន សំណាង ដែលកំពុងឈរនៅក្នុងចំណោមសិស្សានុសិស្សទាំង៣៣នាក់ មកពីវិទ្យាល័យ មេសាង ស្តាប់ការរៀបរាប់របស់អ្នករស់រានមានជីវិតទាំងអស់ បានសម្តែងឲ្យឃើញទឹកមុខស្រពាប់ស្រពោន មិននិយាយស្តី និងហាក់ដូចជាជឿជាក់លើពាក្យសម្តីពិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនោះ។ អាចារ្យ សុខ ឃាង បានបញ្ជាក់ថា រឿងរ៉ាវដែលគាត់ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបាននិយាយនៅពេលនេះ គឺជារឿងរ៉ាវពិតដែលបានកើតមានចំពោះអ្នកភូមិទួលជ្រែប្រាកដមែន។ លោកបន្តថា អ្នកភូមិទាំងអស់ដែលមានវ័យចំណាស់ៗ គឺសុទ្ធសឹងតែមានប្រវត្តិរឿងរ៉ាវស្រដៀងគ្នាចំពោះការបាត់បង់សមាជិកគ្រួសារនៅក្នុងរបបខ្មែរក្រហម។

បន្ទាប់ពីអ្នករស់រានមានជីវិតទាំងអស់បញ្ចប់ការចែករំលែករឿងរ៉ាវជីវិតរបស់ខ្លួនរួចមក យុវជនទាំងអស់ត្រូវបាននាំទៅកាន់ចេតិយមួយកន្លែងស្ថិតនៅភាគខាងត្បូងព្រះវិហារ។ ទីនោះគឺជាកន្លែងតម្កល់អដ្ឋិធាតុដែលនៅសេសសល់បន្តិចបន្តួច។ លោក សុខ ឃាង បានពន្យល់ដល់ក្មេងៗទាំងអស់ពីដើមហេតុដែលនាំឲ្យមានការនាំយកអដ្ឋិធាតុមកតម្កល់នៅ ទីនេះ និងបានប្រាប់ថា ជារៀងរាល់ឆ្នាំឲ្យតែមានពិធីបុណ្យផ្សេងៗ គឺមានប្រជាជនរស់នៅជុំវិញបរិវេណទួលជ្រែ និងប្រជាជនមកពីទីជិតឆ្ងាយចូលមកធ្វើបុណ្យដើម្បីឧទ្ទិសកុសលជូនសាច់ញាតិដែលបានស្លាប់នៅ ទីនោះ។



សិស្សានុសិស្សមកពីវិទ្យាល័យមេសាងទស្សនកិច្ចទីតាំងសម្លាប់មនុស្ស និង តម្កល់អដ្ឋិធាតុទួលជ្រែ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សវិទ្យាល័យមេសាង ចូលរួមបណ្តុះបណ្តាល កិច្ចការស្រាវជ្រាវអំពីប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

## រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

ផេង ពង្សរ៉ាស៊ី



នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ សិស្សានុសិស្សវ័យក្មេងចំនួន១៥នាក់ មកពីវិទ្យាល័យ មេសាង ស្រុកមេសាង ខេត្តព្រៃវែង បានមកទទួលការបណ្តុះបណ្តាលពីវិធីសាស្ត្រស្រាវជ្រាវកម្រិតបឋម នៅការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ស្ថិតនៅក្នុងទីរួមខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ សិស្សានុសិស្សវ័យក្មេងចំនួន១៥នាក់ មកពីវិទ្យាល័យមេសាង ស្រុកមេសាង ខេត្តព្រៃវែងបានមកទទួលការបណ្តុះបណ្តាលពីវិធីសាស្ត្រស្រាវជ្រាវកម្រិតបឋម នៅការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ស្ថិតនៅក្នុងទីរួមខេត្តព្រៃវែង។ វគ្គបណ្តុះបណ្តាលនេះប្រព្រឹត្តទៅពេញមួយថ្ងៃជាមួយនឹងមាតិកាមួយចំនួនរួមមាន ៖ ១) ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ២) វិធីសាស្ត្រក្នុងការអនុវត្តកិច្ចការស្រាវជ្រាវ ៣) ការជ្រើសរើសប្រធានបទស្រាវជ្រាវ ៤) ការបែងចែកក្រុមស្រាវជ្រាវ ៥) ការកំណត់កាលវិភាគអនុវត្តកិច្ចការស្រាវជ្រាវ និង ៦) ការចុះទៅកាន់មូលដ្ឋានដើម្បីអនុវត្តសាកល្បងពីកិច្ចសម្ភាសន៍។

## ហេតុអ្វីបណ្ដុះបណ្ដាលកិច្ចការស្រាវជ្រាវ?

អត្ថបទ និងសំណេរស្រាវជ្រាវជាច្រើនស្ដីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ធ្លាប់ត្រូវបានសរសេរដោយអ្នកស្រាវជ្រាវ, និស្សិតដែលនឹងត្រូវបញ្ចប់ការសិក្សា, បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ឬ មន្ត្រីរាជការនៅស្ថាប័នពាក់ព័ន្ធ។ ប៉ុន្តែយើងពុំទាន់ឃើញមានការសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរក្រហមដោយក្មេងៗ ដែលជាសិស្សកម្រិតវិទ្យាល័យនៅឡើយទេ។ ម្យ៉ាងទៀត ការសិក្សានៅកម្រិតវិទ្យាល័យអំពីប្រវត្តិសាស្ត្រខ្មែរក្រហម គឺនៅមានកម្រិតតិចតួច ហើយការយល់ដឹងអំពីប្រវត្តិសាស្ត្រនេះតាមរយៈគ្រូបង្រៀន គឺនៅពុំទាន់គ្រប់គ្រាន់ក្នុងការឈ្វេងយល់ស៊ីជម្រៅអំពីប្រវត្តិសាស្ត្រនេះទេ។ ក្មេងៗទាំងនោះ គួរតែឈ្វេងយល់ឲ្យស៊ីជម្រៅបន្ថែមទៀតតាមការសិក្សាស្រាវជ្រាវ និងការជួបសន្ទនាជាមួយចាស់ៗនៅក្នុងភូមិ ដែលត្រូវជាជីដូនជីតា និងសាច់ញាតិរបស់ខ្លួន។ ក្មេងៗមួយចំនួននៅមិនទាន់ជឿថារបបខ្មែរក្រហមបានកើតឡើង ហើយបានសម្លាប់មនុស្សអស់រាប់លាននាក់ទេ។ ស្របពេលជាមួយគ្នានេះ ជីដូនជីតា ឬចាស់ទុំក្នុងភូមិ កាន់តែលែងមានទំនុកចិត្តក្នុងការចែករំលែកបទពិសោធន៍របស់ខ្លួនប្រាប់ទៅក្មេងៗទៀត ព្រោះក្មេងៗទាំងនោះនៅមានភាពស្ទាក់ស្ទើរក្នុងការជឿថាមានរបបខ្មែរក្រហមកាលពីអតីតកាល។

ចំណោទបញ្ហាទាំងនេះ បានជំរុញឲ្យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង គិតគូរ និងជំរុញលើកទឹកចិត្តឲ្យក្មេងៗឈ្វេងយល់អំពីវិធីសាស្ត្រស្រាវជ្រាវ ដើម្បីធ្វើការស្រាវជ្រាវពីភាពពិតប្រាកដនៅក្នុងសង្គមកម្ពុជាក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០។ ម៉្យាងទៀត យើងជឿជាក់ថា ការសន្ទនា និងការផ្ទេរចំណេះដឹងដែលបានមកពីការស្រាវជ្រាវផ្ទាល់របស់អ្នកស្រាវជ្រាវវ័យក្មេង ទៅកាន់មិត្តភក្តិ មិត្តរួមថ្នាក់ និងអ្នកដែលមានវ័យស្របាលគ្នា គឺមានប្រសិទ្ធភាពបំផុត។ សិស្សានុសិស្សអាចធ្វើបទបង្ហាញពីកិច្ចការស្រាវជ្រាវរបស់ខ្លួននៅក្នុងថ្នាក់ ហើយធ្វើជាម្ចាស់លើសំណេរស្រាវជ្រាវរបស់ខ្លួន។

## គោលបំណងនៃវគ្គបណ្ដុះបណ្ដាលគឺ៖

១) លើកកម្ពស់ការយល់ដឹងពីមាតិកាប្រវត្តិសាស្ត្រកាន់តែស៊ីជម្រៅ។

២) លើកកម្ពស់ភាពជាអ្នកដឹកនាំក្នុងកិច្ចការស្រាវជ្រាវឲ្យកាន់តែប្រសើរឡើង។

៣) បង្កើនចំណេះដឹងពីកិច្ចការស្រាវជ្រាវនៅកម្រិតវិទ្យាល័យ។

៤) បង្កើនទំនាក់ទំនងនៅក្នុងសង្គម និងការសន្ទនាអន្តរជំនាន់រវាងក្មេងៗ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

៥) កសាងប្រវត្តិសាស្ត្រភូមិដោយខ្លួនឯងដើម្បីទុកជាឯកសារប្រវត្តិសាស្ត្រ។

## កម្មវិធីបណ្ដុះបណ្ដាលនេះគឺ៖

### ពេលព្រឹក៖

- បទបង្ហាញពីមាតិកាប្រវត្តិសាស្ត្រ «ការជម្លៀសប្រជាជនដោយបង្ខំ» និងសំណួរ-ចម្លើយ។
- បទបង្ហាញពីវិធីសាស្ត្រស្រាវជ្រាវ (កម្រិតបឋម) និងដំណាក់កាលនៃការចុះអនុវត្តការស្រាវជ្រាវ។
- ការជ្រើសរើសប្រធានបទស្រាវជ្រាវ និងការពិភាក្សាពីប្រធានបទ ( ដែលបានជ្រើសរើសរួចហើយ )។
- បង្កើតសំណួរស្រាវជ្រាវចេញពីប្រធានបទ។
- បង្កើតសំណួរគោលចេញពីសំណួរស្រាវជ្រាវ។
- បង្កើតកម្រងសំណួរសម្រាប់សម្ភាសន៍ ចេញពីសំណួរគោល។

### ពេលរសៀល៖

- ការបែងចែកក្រុមស្រាវជ្រាវ។
- ការសម្ភាសន៍សាកល្បងជាមួយសិស្សគ្នាឯង។
- ការបែងចែកកាលវិភាគសម្រាប់កិច្ចការស្រាវជ្រាវ។
- ការចុះទៅកាន់មូលដ្ឋានដើម្បីអនុវត្តការសម្ភាសន៍សាកល្បងជាមួយអ្នករស់រានមានជីវិត។



នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៤ សិស្សានុសិស្សវ័យក្មេងចំនួន១៥នាក់ មកពីវិទ្យាល័យ មេសាង ស្រុកមេសាង ខេត្តព្រៃវែង បានមកទទួលការបណ្តុះបណ្តាលពីវិធីសាស្រ្តស្រាវជ្រាវកម្រិតបឋម នៅការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ស្ថិតនៅក្នុងទីរួមខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## សកម្មភាពបណ្តុះបណ្តាល

### បទបង្ហាញពីមាតិកាប្រវត្តិសាស្រ្ត «ការជម្លៀសប្រជាជនដោយបង្ខំ»៖

លោក ផេង ពង្សរ៉ាស៊ី គឺជានាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និងជាគ្រូខ្មេស បានណែនាំពីវត្ថុបំណងនៅក្នុងថ្ងៃនេះ និងបានបង្ហាញពីមាតិកានៃវគ្គបណ្តុះបណ្តាលសម្រាប់រយៈពេលមួយថ្ងៃពេញ។ មុននឹងធ្វើបទបង្ហាញពីមាតិកាប្រវត្តិសាស្រ្តខ្មែរក្រហម លោក ផេង ពង្សរ៉ាស៊ី បានផ្តល់អនុសាសន៍ខ្លះៗទៅកាន់អ្នកចូលរួមថា ការធ្វើកិច្ចការស្រាវជ្រាវគឺជាការដោះស្រាយចម្ងល់របស់អ្នកស្រាវជ្រាវអំពីប្រធានបទអ្វីមួយ ហើយដំណោះស្រាយដែលបានមកពីការស្រាវជ្រាវ គឺជាមេរៀនដែលគួរឈ្វេងយល់។

លោក ផេង ពង្សរ៉ាស៊ី បានចំណាយពេលវេលាជាងកន្លះម៉ោង ដើម្បីធ្វើបទបង្ហាញអំពី«ការជម្លៀសប្រជាជនដោយបង្ខំ» របស់ខ្មែរក្រហម។ បទបង្ហាញនេះ បង្ហាញពីចេតនាច្បាស់លាស់មួយរបស់គ្រូខ្មេស ដើម្បីឲ្យអ្នកស្រាវជ្រាវវ័យក្មេងទាំងអស់ឈ្វេងយល់ឲ្យកាន់តែច្បាស់អំពីព្រឹត្តិការណ៍នៃការជម្លៀសប្រជាជនដោយបង្ខំរបស់ខ្មែរក្រហម ដែលបានកើតឡើងតាំងពីមុនការចូលកាន់កាប់ប្រទេសកម្ពុជារបស់ខ្លួន នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ បទបង្ហាញនេះ មានគោលបំណងចង់ឲ្យអ្នកស្រាវជ្រាវវ័យក្មេងផ្តោតការយកចិត្តទុកដាក់ទៅលើព្រឹត្តិការណ៍នៃការជម្លៀស ហើយលើកជាសំណួរផ្សេងៗ ដែលអាចឈានដល់ការកំណត់ប្រធានបទក្នុងការស្រាវជ្រាវ។

### បទបង្ហាញអំពីវិធីសាស្រ្តស្រាវជ្រាវ (កម្រិតបឋម) និងដំណាក់កាលនៃការចុះអនុវត្តការស្រាវជ្រាវ

លោក ផេង ពង្សរ៉ាស៊ី ចាប់ផ្តើមការធ្វើបទបង្ហាញរបស់ខ្លួនអំពីការបង្ហាញធាតុផ្សំសំខាន់ៗចំនួនបី ដែលចាំបាច់បំផុតក្នុងការសិក្សាស្រាវជ្រាវ។ ធាតុផ្សំទាំងនោះគឺ ឯកសារ ទីតាំង និងមនុស្សដែលជាគោលដៅក្នុងការសម្ភាសន៍។ បន្ទាប់មកលោក ផេង ពង្សរ៉ាស៊ី បានបន្តទៅចំណុចផ្សេងៗទៀត រួមមាន៖ ឥរិយាបទក្នុងពេលសម្ភាសន៍, សំណួរចាំបាច់ប្រើក្នុងពេលសម្ភាសន៍, ការរៀបចំកម្រងសំណួរ, ការជ្រើសរើសគោលដៅសម្ភាសន៍, ការប្រមូលទិន្នន័យកិច្ចសម្ភាសន៍, ការធ្វើប្រតិចារឹកកិច្ចសម្ភាសន៍, ការរៀបចំអត្ថបទតាមកាលបរិច្ឆេទ, ការរៀបចំគម្រោងស្រាវជ្រាវ, ការរៀបចំគម្រោងសំណេរ និងការសរសេរ។





នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៤ សិស្សានុសិស្សវ័យក្មេងចំនួន១៥នាក់ មកពីវិទ្យាល័យ មេសាង ស្រុកមេសាង ខេត្តព្រៃវែង បានមកទទួលការបណ្តុះបណ្តាលពីវិធីសាស្ត្រស្រាវជ្រាវកម្រិតបឋម នៅការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ស្ថិតនៅក្នុងទីរួមខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់ពីបានបង្ហាញនិងពិភាក្សាគ្នាពីចំណុចខាងលើរួចមកលោក ផេង ពង្ស៍រ៉ាស៊ី បានផ្តល់ពេលវេលាដល់អ្នកចូលរួមលើកពីចម្ងល់ផ្សេងៗទាក់ទងនឹងចំណេះដឹងពីការជម្លៀសប្រជាជនដោយបង្ខំរបស់ខ្មែរក្រហម។ លោក ផេង ពង្ស៍រ៉ាស៊ី បានលើកជាសំណួរទៅកាន់អ្នកចូលរួមថា «តើប្អូនមានចម្ងល់អ្វីខ្លះ ទាក់ទងនឹងការជម្លៀសដោយបង្ខំ?»។ លោក ផេង ពង្ស៍រ៉ាស៊ី បានបន្ថែមថា «ចម្ងល់របស់ប្អូនគួរតែជាចម្ងល់ដែល ទាមទារឲ្យប្អូនធ្វើការស្រាវជ្រាវទៅលើសំណួរជាមុនសិន ទើបអាចរកចម្លើយឃើញ»។ នេះមានន័យថា សំណួរដែលនឹងត្រូវលើកឡើង គឺជាសំណួរស្រាវជ្រាវដែលផ្តោតលើវិសាល-ភាព ហេតុផល និងវិធីដែលមានព្រឹត្តិការណ៍មួយបានកើតមានឡើង។ នៅទីបំផុតសំណួរស្រាវជ្រាវមួយត្រូវបានលើកយកមកពិភាក្សា ហើយអ្នកចូលរួមទាំងអស់បានឯកភាពគ្នាក្នុងការកំណត់ប្រធានបទស្រាវជ្រាវតូចមួយ ស្តីអំពីឥទ្ធិពលនៃការជម្លៀសប្រជាជនដោយបង្ខំនៅស្រុកមេសាង។

សិស្សានុសិស្សវ័យក្មេង បាននាំគ្នារិះគិតស៊ីជម្រៅពីប្រធានបទនេះ ដោយមានការផ្តល់យោបល់ពីគ្រូខទ្វេស និងគ្រូជំនួយម្នាក់ទៀតឈ្មោះ ប៉ុត ម៉ាក់ ដែលជាគ្រូបង្រៀនប្រវត្តិវិទ្យា។ ដំបូង សិស្សនាំគ្នាពិភាក្សាអំពី«សំណួរស្រាវជ្រាវ»។ បន្ទាប់មក ពិភាក្សាអំពី «សំណួរគោល» ចេញពីសំណួរស្រាវជ្រាវ ហើយចុងក្រោយ គឺជាការពិភាក្សាអំពី «សំណួរលម្អិតមួយចំនួនសម្រាប់ការចុះទៅសម្ភាសន៍» ដែលជាផ្នែកសំខាន់ៗនៃសំណួរគោលនីមួយៗ។

នៅពេលរសៀល សិស្សទាំងអស់ត្រូវបានបែងចែកជាក្រុមៗ ដើម្បីទទួលបន្ទុកធ្វើកិច្ចការងារស្រាវជ្រាវតាមផ្នែកនីមួយៗដែលជាចំណងជើងរងនៃ«ឥទ្ធិពលនៃការជម្លៀសប្រជាជនដោយបង្ខំនៅឃុំស្វាយជ្រុំ ស្រុកមេសាង» ហើយការរៀបចំកាលវិភាគសម្រាប់កិច្ចការងារនេះ ក៏ត្រូវបានធ្វើឡើងផងដែរ។ បន្ទាប់មក សិស្សតាមក្រុមនីមួយៗដែលបានបែងចែករួច បានអនុវត្តការសម្ភាសន៍សាកល្បងរបស់ខ្លួនជាមួយសមាជិកក្រុម និងមានឱកាសក្នុងការចុះទៅកាន់មូលដ្ឋានជួបសម្ភាសន៍សាកល្បងជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីពង្រឹងសមត្ថភាពសម្ភាសន៍របស់ខ្លួន។

នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលនេះ គ្រូខទ្វេស បានផ្តល់យោបល់បន្ថែម ទាក់ទងនឹងការសម្ភាសន៍ថា អ្នកស្រាវជ្រាវគួរតែមានភាពឆ្លាតវៃក្នុងការសួរ និងកត់ត្រានូវអ្វីដែលជាព្រឹត្តិការណ៍សំខាន់ៗដែលអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមបាននិយាយប្រាប់។ លើសពីនេះទៀត គ្រូខទ្វេសបានរំឭកឲ្យអ្នកស្រាវជ្រាវទាំងអស់អនុវត្តតាមកាលវិភាគ ដែលបានធ្វើរួចរាល់ ដើម្បីធានាថា កិច្ចការងារស្រាវជ្រាវនឹងត្រូវបញ្ចប់ទាន់ពេលវេលា និងមានគុណភាព។

*ក្រោយពីចប់វគ្គបណ្តុះបណ្តាលសិស្សានុសិស្សបាន បង្ហាញនូវចំណាប់អារម្មណ៍ ដូចខាងក្រោម៖*

### ១) ញឹម ភារក្ស



ញឹម ភារក្ស ភេទប្រុស អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យមេសាង រស់នៅភូមិដីដុច ឃុំដីដុច ស្រុកមេសាង ខេត្តព្រៃវែង រៀបរាប់ថា នៅថ្ងៃនេះ ខ្ញុំពិតជារំភើបខ្លាំងណាស់ ដែលបានមកសិក្សាពីប្រវត្តិសាស្ត្រដែលខ្ញុំមិនបានកើតទាន់ និងមិនបានឃើញផ្ទាល់ភ្នែក ប៉ុន្តែទិដ្ឋភាពដែលលោកគ្រូបានពន្យល់ណែនាំ ធ្វើឲ្យខ្ញុំឈឺចាប់ប្រៀបបានដូចជារូបខ្ញុំនៅក្នុងសម័យនោះដែរ។ លោកគ្រូរបស់ខ្ញុំ បាននាំរូបខ្ញុំមកសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហម នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ ចំណែកលោកគ្រូ ផេង ពង្សរ៉ាស៊ី ដែលជាគ្រូខ្ទេសបាននិយាយអំពីរបបប្រល័យពូជសាសន៍ ឆ្នាំ១៩៧៥-១៩៧៩ និងនិយាយពីការជម្លៀសប្រជាជនដោយបង្ខំ។ លោកគ្រូ ផេង ពង្សរ៉ាស៊ី បានដាក់ការងារស្រាវជ្រាវតាមភូមិឃុំ ដែលប្រធានបទនិយាយអំពីការជម្លៀសប្រជាជន ហើយសំណួរដែលក្រុមរបស់ខ្ញុំផ្តោតសំខាន់នោះគឺ «ទាក់ទងនឹងការឈឺចាប់ផ្លូវកាយរបស់ប្រជាជន»។ សម្រាប់ប្រធានបទនេះ ខ្ញុំគិតថាល្អខ្លាំងណាស់ ព្រោះបានបង្កើនចំណេះដឹង និងបានដឹងពីរឿងរ៉ាវរបស់ចាស់ៗនៅក្នុងភូមិ។ ក្នុងនាមខ្ញុំជាសិស្សថ្នាក់ទី១២ ខ្ញុំមានការតាំងចិត្តយ៉ាងមុតមាំក្នុងការស្រាវជ្រាវពីប្រវត្តិសាស្ត្រតាមរយៈការសិក្សាស្រាវជ្រាវពីប្រជាជននៅតាមភូមិឃុំ ហើយក៏តាំងចិត្តធ្វើការងារនេះឲ្យល្អសម្រាប់អ្នកជំនាន់ក្រោយ។

### ២) ប៊ុនធឿន សារ៉ា

ប៊ុនធឿន សារ៉ា ភេទស្រី អាយុ១៦ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យមេសាង រស់នៅភូមិប្រហ៊ូត ឃុំត្រពាំងស្រែ ស្រុកមេសាង ខេត្តព្រៃវែង



រៀបរាប់ថា នៅថ្ងៃនេះ ខ្ញុំពិតជាសប្បាយរីករាយ ព្រោះខ្ញុំបានទទួលចំណេះដឹងថ្មីៗប្លែកៗ និងរីករាយក្នុងការទទួលមេរៀនពីលោកគ្រូ។ ចំពោះមេរៀនថ្ងៃនេះលោកគ្រូបង្រៀនពីការជម្លៀសប្រជាជននៅក្នុងរបបខ្មែរក្រហម ក៏ដូចជាការរៀបចំកិច្ចការស្រាវជ្រាវ។ សម្រាប់កិច្ចការស្រាវជ្រាវដែលលោកគ្រូបានដាក់ គឺការជម្លៀសប្រជាជនដោយបង្ខំ ហើយប្រធានបទដែលក្រុមនាងខ្ញុំត្រូវស្រាវជ្រាវគឺ «ការប៉ះពាល់ទៅលើបញ្ហាស្មារតីប្រជាជន» ថា «តើនៅក្នុងរបបខ្មែរក្រហមមានផលប៉ះពាល់អ្វីខ្លះដល់ស្មារតីប្រជាជន?»។ ចំពោះប្រធានបទនេះគឺធ្វើឲ្យយើងចង់សិក្សាស្រាវជ្រាវពីផលប៉ះពាល់ទៅលើបញ្ហាស្មារតីរបស់ប្រជាជន បន្ទាប់ពីរបបខ្មែរក្រហមកើតឡើង ហើយខ្ញុំតាំងចិត្តថាធ្វើប្រធានបទនេះឲ្យល្អ ព្រោះលោកគ្រូបានពន្យល់ណែនាំខ្ញុំយ៉ាងច្រើនពីរបៀបធ្វើកិច្ចការស្រាវជ្រាវ។

### ៣) គង់ ចាន់ណា



គង់ ចាន់ណា ភេទស្រី អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យមេសាងរស់នៅភូមិពោធិតាមុំ ឃុំស្វាយជ្រុំ ស្រុកមេសាង ខេត្តព្រៃវែង រៀបរាប់ថា ខ្ញុំពិតជាសប្បាយចិត្តដែលបានសិក្សាពីប្រវត្តិសាស្ត្រដ៏ជូរចត់របស់ខ្មែរ។ នៅក្នុងថ្ងៃនេះ ខ្ញុំទទួលបានចំណេះដឹងទាក់ទងនឹងវិធីសាស្ត្រស្រាវជ្រាវ និងចងក្រងឯកសារ ហើយខ្ញុំនឹងចែករំលែកទៅមិត្តដទៃទៀត ដែលមិនបានចូលរៀនដូចខ្ញុំ។ បន្ថែមពីនេះទៀត ខ្ញុំបានដឹងថា របបកម្ពុជាប្រជាធិបតេយ្យគឺជារបបដែលគួរឲ្យខ្លាចបំផុត ព្រោះមេដឹកនាំមិនបានខ្វល់ពីប្រជាជន និងបណ្តោយឲ្យអ្នកក្រោមបង្គាប់ធ្វើបាបប្រជាជន គំរាមកំហែង វាយដំប្រជាជនយ៉ាងព្រៃផ្សៃ។ លើសពីនេះ ប្រជាជនដែល

រស់នៅក្នុងរបបនោះ ទទួលរងនូវវិប្បដិសារី និងរងនូវផលប៉ះពាល់មកលើរូបរាងកាយ ផ្លូវចិត្ត និងប៉ះពាល់មកដល់ជីវភាពរស់នៅ។ ថ្ងៃនេះ ក្រុមរបស់ខ្ញុំបានទទួលប្រធានបទស្រាវជ្រាវមួយដែលនិយាយអំពី ផលពិបាកផ្លូវចិត្តរបស់ប្រជាជនដែលត្រូវបានជម្លៀសដោយបង្ខំ។ ចំពោះប្រធានបទនេះខ្ញុំពិតជាពេញចិត្តខ្លាំងណាស់ ព្រោះនៅពេលដែលខ្ញុំសិក្សាស្រាវជ្រាវរួច ខ្ញុំនឹងបានដឹងអំពីទឹកចិត្តរបស់អ្នកដែលឆ្លងកាត់របបខ្មែរក្រហម តាមរយៈការរៀបរាប់របស់គាត់ និងដឹងពីផលលំបាករបស់គាត់ដែលរស់នៅក្នុងរបបដែលមានការគំរាមកំហែង បំបិទសិទ្ធិសេរីភាពមនុស្ស និងប្រព្រឹត្តលើមនុស្សដូចជាសត្វធាតុ។ ចំពោះប្រធានបទនេះ ខ្ញុំមានជំនឿចិត្តថា ខ្ញុំនឹងអាចធ្វើវាបាន ហើយខ្ញុំក៏បានគិតក្នុងចិត្តរួចហើយថា បន្ទាប់ពីបញ្ចប់វេទិកានេះ ខ្ញុំនឹងសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមយ៉ាងហោចណាស់ឲ្យបាន១០នាក់។ មូលហេតុដែលខ្ញុំគិតថា សម្ភាសន៍ឲ្យបាន១០នាក់ ព្រោះខ្ញុំទទួលបានការណែនាំពីលោកគ្រូ ដេង ពង្សរ៉ាស៊ី ដែលបានពន្យល់យ៉ាងល្អអំពីវិធីសាស្ត្រស្រាវជ្រាវ និងសម្ភាសន៍។ ម្យ៉ាងទៀត ក្រុមរបស់ខ្ញុំមានគម្រោងបែងចែកសមាជិកក្រុមឲ្យទៅសម្ភាសន៍យាយតា និងសាច់ញាតិរបស់ខ្លួន ហើយខ្ញុំនឹងសម្ភាសន៍ អ៊ំរបស់ខ្ញុំឲ្យបាន៣នាក់ក្នុងរយៈពេល២សប្តាហ៍នេះ។

### ៤) ម៉េត មល់



ម៉េត មល់ ភេទប្រុស អាយុ ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី ១២ នៃវិទ្យាល័យមេសាង រស់នៅភូមិស្វាយជ្រុំ ឃុំស្វាយជ្រុំ ស្រុកមេសាង ខេត្តព្រៃវែង រៀបរាប់ថា កម្មវិធីសិក្សាស្រាវជ្រាវ និងសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម គឺល្អណាស់សម្រាប់សិស្សានុសិស្សដូចជាខ្ញុំ ព្រោះខ្ញុំបានដឹងអំពីប្រវត្តិ-សាស្ត្រ ប្រទេសរបស់ខ្លួន។ ចំណេះដឹងដែលខ្ញុំទទួលបាននៅក្នុងថ្ងៃនេះគឺបទពិសោធន៍នៃការរស់នៅរបស់ប្រជាជនខ្មែរ ទាំងអស់ដែលបានឆ្លងកាត់ការលំបាកកន្លងមក។ មួយវិញទៀត ខ្ញុំបានដឹងអំពីវិធីសាស្ត្រស្រាវជ្រាវឯកសារ ចងក្រងឯកសារទុកឲ្យក្មេងជំនាន់ក្រោយទៀត។ ការចងក្រងឯកសារ គឺជាមេរៀនមួយដើម្បីឲ្យកូនចៅជំនាន់ក្រោយចេះការពារ និងបដិសេធការដឹកនាំដែលមិនល្អ និងគាំទ្រទៅលើថ្នាក់ដឹកនាំដែលចេះគិតគូរពីប្រជាជន។ ចំពោះមេរៀនទាក់ទងរបបខ្មែរក្រហម ខ្ញុំទទួលបានចំណេះដឹងទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុង ទីប្រជុំជនឲ្យទៅធ្វើស្រែចម្ការ លើកទំនប់ ជីកប្រឡាយ។ ការជម្លៀសប្រជាជនធ្វើឡើងដោយការគំរាមកំហែង និងការបាញ់សម្លាប់ប្រជាជន។ ចំពោះប្រធានបទដែលខ្ញុំទទួលបានក្នុងថ្ងៃនេះ គឺការជម្លៀសប្រជាជនចេញពីទីក្រុងទៅជនបទ។ ខ្ញុំយល់ថា ប្រធានបទនេះល្អខ្លាំងណាស់សម្រាប់ក្រុមខ្ញុំដើម្បីយកទៅសិក្សាស្រាវជ្រាវ និងចងក្រងឯកសារដាក់ចូលក្នុងកម្មវិធីសិក្សាបន្តទៅទៀត។ នៅថ្ងៃអនាគតខ្ញុំចង់ធ្វើជាអ្នកដឹកនាំនយោបាយមួយរូប ដើម្បីលុបបំបាត់អំពើពុករលួយនៅក្នុងប្រទេសកម្ពុជា។

### ៥) សុខ រីយា



សុខ រីយា ភេទស្រី មានអាយុ១៦ឆ្នាំ រៀននៅថ្នាក់ ១២ នៃវិទ្យាល័យមេសាង រៀបរាប់ថាវគ្គបណ្តុះបណ្តាលនេះធ្វើឲ្យខ្ញុំបានដឹងច្រើនជាងមុនពីរបបខ្មែរក្រហម។ ម្យ៉ាងទៀត ខ្ញុំទទួលបាននូវបទពិសោធន៍ថ្មីជាច្រើន ជាពិសេស គឺរបៀបនៃការចុះសិក្សាស្រាវជ្រាវទាក់ទងប្រធានបទដែលលោកគ្រូបានដាក់ឲ្យធ្វើ ដែលប្រធានបទនោះនិយាយអំពីឥទ្ធិពល ឬផលប៉ះពាល់នៃការជម្លៀសប្រជាជនដោយបង្ខំ។ ខ្ញុំមានការពេញចិត្តចំពោះប្រធានបទដែលលោកគ្រូដាក់ឲ្យធ្វើ ក៏ព្រោះតែប្រធានបទនេះមិនលំបាកពេក ហើយក៏មិនស្រួលពេកដែរសម្រាប់ខ្ញុំ។ ប៉ុន្តែទោះបីជាយ៉ាងណា ខ្ញុំមានការប្តេជ្ញាចិត្តខ្ពស់

រហូតដល់ទៅ៨០ភាគរយ ក្នុងការបំពេញកិច្ចការនេះឲ្យបានជោគជ័យ និងទាន់ពេលវេលាក្នុងរយៈពេល៣ខែ។ ខ្ញុំសន្យាថា នឹងខិតខំប្រឹងប្រែងធ្វើកិច្ចការនេះឲ្យបានល្អ។ ជាចុងក្រោយ ខ្ញុំសូមអរគុណដល់លោកគ្រូដែលបានបង្រៀនសិស្សទាំងអស់អំពីរបៀបស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរក្រហម។

## ៦) ហាន នីហ័រ



ហាន នីហ័រ ភេទស្រី មានអាយុ ១៥ឆ្នាំ រៀននៅថ្នាក់ទី១២ នៃវិទ្យាល័យមេសាង រៀបរាប់ថា ខ្ញុំចង់មករៀននៅទីនេះ គឺខ្ញុំចង់ដឹងអំពីការស្រាវជ្រាវ និងហេតុការណ៍ផ្សេងៗដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងចង់ស្រាវជ្រាវឲ្យកាន់តែច្បាស់អំពីព្រឹត្តិការណ៍ផ្សេងៗដែលបានកើតឡើងពីដំណាក់កាលមួយទៅដំណាក់កាលមួយ និងហេតុការណ៍កើតឡើងនៅក្នុងរបបនីមួយៗ ថារបបនេះមានអ្វីខ្លះបានកើតឡើង ជាពិសេស របបខ្មែរក្រហមបានធ្វើអ្វីខ្លះមកលើយាយតាយើង។ តាមរយៈការសិក្សារៀនសូត្រ និងតាមរយៈតាយាយដែលធ្លាប់បាននិយាយប្រាប់ខ្ញុំកន្លងមក ខ្ញុំគិតថាពួកគាត់ជួបទុក្ខលំបាកជាច្រើន ហើយគាត់ក៏មានសំណាងដែលបានរួចរស់ជីវិតពីរបបខ្មែរក្រហម។ យាយតារបស់ខ្ញុំធ្លាប់បាននិយាយប្រាប់ខ្ញុំថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬក៏របប ប៉ុល ពត គាត់បានជួបទុក្ខលំបាកជាច្រើនដោយសារការបង្អត់អាហារ ការចាប់គូឲ្យរៀបការដោយមិនបានស្រឡាញ់គ្នា ការធ្វើការងារហួសកម្លាំង និងមិនបានសម្រាកគ្រប់គ្រាន់ ជាពិសេសមិនបានហូបអាហារដែលយើងចង់ហូប។ ពេលយើងធ្វើអ្វីមួយត្រូវធ្វើដោយលួចលាក់ ព្រោះយើងស្ថិតនៅក្រោមការតាមដានរបស់អង្គការ។ ក្រៅពីនេះ ក្រុមគ្រួសាររស់នៅដោយមិនទុកចិត្តគ្នា។ ចំពោះការស្រាវជ្រាវពីប្រវត្តិសាស្ត្រខ្មែរក្រហម ខ្ញុំមានការជឿជាក់ថា ខ្ញុំអាចធ្វើបានចំពោះប្រធានបទដែលលោកគ្រូបានដាក់ឲ្យក្រុមរបស់ខ្ញុំសិក្សាស្រាវជ្រាវអំពី ៖ តើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការជម្លៀសប្រជាជនទាំងបង្ខំបានផ្តល់ផលប៉ះពាល់អ្វីខ្លះមកលើរាងកាយប្រជាជនកម្ពុជា។ ខ្ញុំតាំងចិត្តថាខ្ញុំនឹងធ្វើកិច្ចការនេះឲ្យបានល្អ ព្រោះខ្ញុំចង់បានស្នាដៃមួយដែលជារបស់ខ្លួនជាពិសេសខ្ញុំចង់ពង្រឹងភាពក្លាហានរបស់ខ្ញុំនៅក្នុងការជួបសំណេះសំណាលជាមួយតាយាយនៅក្នុងភូមិ។ រហូតមកដល់សម័យនេះ ការរស់នៅមានភាពងាយស្រួល ដូច្នេះយើងគប្បីខិតខំសិក្សារៀនសូត្រ ជាពិសេស ខិតខំស្រាវជ្រាវអំពីប្រវត្តិសាស្ត្ររបស់ប្រទេសយើងឲ្យបានច្រើន។





នៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៤ សិស្សានុសិស្សវ័យក្មេងចំនួន១៥នាក់ មកពីវិទ្យាល័យ មេសាង ស្រុកមេសាង ខេត្តព្រៃវែង បានសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម បន្ទាប់ពីទទួលការបណ្តុះបណ្តាលពីវិធីសាស្ត្រស្រាវជ្រាវកម្រិតបឋម នៅការិយាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ស្ថិតនៅក្នុងទីរួមខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)


















# បណ្ណាល័យមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង

បណ្ណាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកបម្រើជូនសិស្ស និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ អង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយ ដែលមានចំណាប់អារម្មណ៍អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ប្រសាលាក្តីខ្មែរក្រហម។

បណ្ណាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង គឺជាកន្លែងប្រមូលផ្តុំ និងតម្កល់ឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅបណ្ណាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង មាន៥ប្រភេទ។ ប្រភេទឯកសារទីមួយ គឺឯកសារជាក្រដាសសន្លឹក ដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបី គឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួន គឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំ គឺជាខ្សែភាពយន្ត ឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈបណ្ណាល័យមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង សាធារណជនអាចមកស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។



## បណ្ណាល័យមជ្ឈមណ្ឌលឯកសារ ខេត្តព្រៃវែង

មានទីតាំងស្ថិតនៅផ្ទះលេខ១៧/១ ភូមិទី៣ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។

ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ព្រឹក ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងលោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង តាមរយៈ ទូរសព្ទលេខ ៖ ០១២ ៦៩៦ ៩៦១ ឬ អ៊ីម៉ែល ៖ truthrasy.p@ dccam.org ។

សូមអរគុណ!











# បងស្រី ប្រាក់ អឿន និងប្តី រួមទាំងកូនៗ ៨នាក់ ត្រូវខ្មែរក្រហមសម្លាប់នៅខេត្តពោធិ៍សាត់

***សេន ពន្លឺ***



ប្រាក់ ឈួន មានអាយុ៧១ឆ្នាំ រស់នៅភូមិស្វាយបុណ្យ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ប្រាក់ ឈួន មានអាយុ ៧១ឆ្នាំ រស់នៅភូមិស្វាយបុណ្យ ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ មុនពេលដែលកងទ័ពខ្មែរក្រហមបានទទួលជ័យជម្នះ ខ្មែរក្រហមមិនទាន់រៀបចំហូបរួម និងធ្វើការងាររួមនៅក្នុងភូមិខ្ញុំទេ។ លុះបានមួយរយៈក្រោយមកពេលខ្មែរក្រហមទទួលជ័យជម្នះ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទើបខ្មែរក្រហមចាប់ផ្តើមបង្កើតជាសហករណ៍ ហើយប្រជាជនត្រូវហូបរួម និងធ្វើការងាររួមគ្នា។

បន្ទាប់មកទៀត នៅចន្លោះពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ ខ្ញុំត្រូវបានប្រធានកងចល័តប្រើឲ្យជីកប្រឡាយ និងលើកទំនប់ស្ថិតនៅភូមិមេសាង ភូមិទានភ្លឺ ភូមិសា ឡូងសា ឡី ភូមិក្រាំងចំបក់ ដើម្បីយកទឹកសម្រាប់ធ្វើស្រែមួយឆ្នាំពីរដង ដូចជានៅភូមិសំរោងវត្ត។ ខ្មែរក្រហមឲ្យខ្ញុំក្រោកទៅជីកប្រឡាយតាំងតែពីម៉ោង២ទៀបភ្លឺ។ ដោយសារប្រឡាយមានជម្រៅជ្រៅ ដូច្នេះម៉ោង៩ព្រឹក ខ្ញុំរែកដីឡើងលើខ្នងទំនប់លែងរួច ព្រោះហត់នឿយខ្លាំងពេក។ ចំពោះការងារជីកប្រឡាយ គឺខ្មែរក្រហមបានកំណត់មួយក្រុមមានគ្នា៣០នាក់ ត្រូវជីកប្រឡាយបណ្តោយ១០ម៉ែត្រ ជម្រៅ១,៥ម៉ែត្រ ក្នុងមួយថ្ងៃឲ្យហើយ។ នៅពេលកំពុងជីកប្រឡាយ ខ្ញុំមានជំងឺរាកធ្ងន់ធ្ងរ ដូច្នេះប្រធានកងបញ្ជូនខ្ញុំឲ្យទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យស្ថិតនៅភូមិប្រមូលដុំ។

នៅឆ្នាំ១៩៧៧ ខ្ញុំត្រូវបានប្រធានក្រុមឲ្យទៅច្រូតស្រូវនៅស្រុករំដួល ខេត្តស្វាយរៀង ដោយខ្ញុំត្រូវធ្វើដំណើរដោយថ្មើរជើង។ នៅពេលខ្ញុំដើរទៅដល់ស្ពានតាហោ ក្នុងក្រុងស្វាយរៀង គឺគ្មានស្ពានដើរឆ្លងកាត់ឡើយ ដូច្នេះប្រធានក្រុមបានឲ្យក្រុមខ្ញុំដើរឆ្លងទឹក។ ទឹកព្រែកពេលនោះមិនសូវជ្រៅប៉ុន្មានទេគឺត្រឹមទ្រូងខ្ញុំ ហើយខណៈពេលនោះដែរ ក៏ចាប់ផ្តើមមានសង្គ្រាមជាមួយកងទ័ពវៀតណាមដែរ។ នៅពេលទៅដល់ស្រុករំដួល ខ្មែរក្រហមកំណត់ឲ្យខ្ញុំច្រូតស្រូវក្នុងមួយថ្ងៃឲ្យបាន៣ហិកតា ដោយត្រូវក្រោកទៅច្រូតតាំងតែពីម៉ោង២ទៀបភ្លឺ ចំណែកបាយមួយពេល ខ្មែរក្រហមកំណត់ចែកអង្ករឲ្យ១២០កំប៉ុង សម្រាប់មនុស្ស១៣០នាក់។ នៅទីនោះសម្លឹពិបាកហូបដោយសារតែចុងភៅដាក់បន្លែចម្រុះគ្រប់សព្វ។

ពេលខ្លះ ប្រធានកងប្រើខ្ញុំឲ្យទៅទូលកណ្តាប់ស្រូវពីស្រែដែលនៅឆ្ងាយ

យកមកទុក ដោយទូលស្រូវម្តងចំនួនបីកណ្តាប់ធំ បើគិតជាស្រូវប្រហែលមួយតៅ។ ពេលខ្លះខ្ញុំនឿយហត់ ទូលមិនដល់គោលដៅ ទើបស្រែកឲ្យគេជួយក៏មាន។

បន្ទាប់មក ខ្មែរក្រហមឲ្យខ្ញុំត្រឡប់មកស្រុកមេសាងវិញ ដើម្បីស្ទូងស្រូវមួយថ្ងៃឲ្យអស់សំណាប១ដួន ក្នុងទំហំក្បាលដី៧ម៉ែត្រ និងបណ្តោយ១០០ម៉ែត្រ។ ខ្ញុំត្រូវក្រោកទៅស្ទូងតាំងតែពីម៉ោង៥ទៀបភ្លឺ។ ក្រោយមកទៀត ខ្ញុំចូលធ្វើការក្នុងកងពិសេស ហើយត្រូវបានខ្មែរក្រហមចល័តឲ្យទៅស្ទូងស្រូវនៅភូមិថ្មី ឃុំដីផុច ប៉ុន្តែទៅទីនោះប្រធានកងមិនបានកំណត់ទំហំដីឬចំនួនកណ្តាប់ដើម្បីស្ទូងនោះទេ។

នៅក្នុងរបបខ្មែរក្រហម បងប្អូនខ្ញុំបង្កើតមានចំនួនពីរនាក់ ត្រូវបានខ្មែរក្រហមសម្លាប់នៅខេត្តពោធិ៍សាត់ ក្នុងនោះបងស្រីខ្ញុំទីមួយមានឈ្មោះប្រាក់ អឿន មានកូន៨នាក់ រួមទាំងប្តីរបស់គាត់។ ការដែលអង្គការបញ្ជូនបងទីមួយខ្ញុំទៅនោះ ដោយសារគាត់ទៅចុះឈ្មោះ ទៅនៅខេត្តពោធិ៍សាត់ ព្រោះគាត់បានស្តាប់ឮពេលអង្គការហៅទៅប្រជុំថា នៅទីនោះមានត្រាវដាំដុះមើមធំៗ ហើយត្រីក៏សម្បូរទៀត។ ចំណែកប្អូនប្រុសពៅខ្ញុំម្នាក់ទៀតត្រូវអង្គការបញ្ជូនទៅធ្វើទាហាន ហើយក៏បាត់ដំណឹងតាំងពីពេលនោះមក។ ឆ្នាំដែលខ្មែរក្រហមបញ្ជូនបងប្អូនខ្ញុំទាំងពីរទៅគឺប្រហែលជានៅឆ្នាំ១៩៧៨។

នៅដើមឆ្នាំ១៩៧៩ ខ្ញុំនិងប្រជាជនក្នុងភូមិត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅអ្នកលឿងរួចបន្តទៅទិសខាងលិច។ ពេលជម្លៀសនោះ គឺមានចោរហ្វាយស្រុកឈ្មោះ ជន ជិះសេះដេញខ្ញុំនិងប្រជាជនពីក្រោយ។ ក្រោយពេលកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពស្ម័គ្រចិត្តវៀតណាមវាយចូលមកដល់ ខ្ញុំក៏វិលត្រឡប់មករស់នៅផ្ទះនៅឯស្រុកកំណើតវិញ។



វាលស្រែនៅក្នុងស្រុកមេសាង ខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# បងប្អូនខ្ញុំចំនួន៤នាក់ ដែលចូលធ្វើបដិវត្តន៍ខ្មែរក្រហម បានស្លាប់ និងបាត់ខ្លួនរហូតមកដល់សព្វថ្ងៃ

**ភា រស្មី**

ខ្ញុំឈ្មោះ ហ៊ឹម តន ភេទស្រី អាយុ ៦៣ឆ្នាំ ក្នុងឆ្នាំ២០០៥ រស់នៅភូមិអង្គរស ឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ ខ្ញុំមានឪពុកឈ្មោះ ហ៊ឹម ឡុក និងម្តាយឈ្មោះ ខៀវ បាន់។ ខ្ញុំមានបងប្អូនបង្កើតចំនួន៧ នាក់។ ខ្ញុំមានប្តីឈ្មោះ សំ ឡូត និងមានកូនម្នាក់ឈ្មោះ ពៅ ចាន់ត្រា។ ខាងក្រោមនេះគឺជារឿងរ៉ាវអំពីបងប្អូនរបស់ខ្ញុំដែលបានបាត់ខ្លួន បន្ទាប់ពីចូលបដិវត្តន៍ខ្មែរក្រហម ៖

ប្អូនទី៤របស់ខ្ញុំឈ្មោះ ហ៊ឹម យ៉ុង ភេទស្រី បានចូលបដិវត្តន៍នៅក្នុងឆ្នាំ១៩៧០។ កាលពីក្មេង យ៉ុង បានរៀនសូត្ររយៈពេលតែពីរឆ្នាំតែប៉ុណ្ណោះ ព្រោះប្រទេសជាតិកើតមានសង្គ្រាមនៅឆ្នាំ១៩៧០។ បន្ទាប់ពីឈប់រៀនប្អូនរបស់ខ្ញុំបានមករស់នៅជួបជុំគ្រួសារក្នុងភូមិអង្គរស និងជួយធ្វើស្រែចម្ការឪពុកម្តាយរបស់ខ្ញុំវិញ។ នៅឆ្នាំ១៩៧១ ឈ្មោះ សុខ ប៊ិតចំរើន ដែលធ្វើការជាមួយក្រុមរណសិរ្សនៅតំបន់២៥ និងសមាជិកប្រមាណចំនួន១០នាក់ បានមកផ្សព្វផ្សាយ និងជ្រើសរើសប្រជាជននៅក្នុងភូមិអង្គរសឲ្យចូលរួមធ្វើបដិវត្តន៍។ សុខប៊ិតចំរើនចូលមកធ្វើការនៅក្នុងភូមិអង្គរសបានដោយមានការជួយសម្របសម្រួលពីមេភូមិ និងមេឃុំអង្គរស។

អំឡុងពេល សុខ ប៊ិតចំរើន ចូលមកផ្សព្វផ្សាយប្អូនរបស់ខ្ញុំឈ្មោះ ហ៊ឹម យ៉ុង រួមនឹងប្រជាជនចំនួន១១នាក់



ហ៊ឹម យ៉ុង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ផ្សេងទៀតបានស្ម័គ្រចិត្តចូលរួមជាមួយបដិវត្តន៍។ នៅពេលចូលធ្វើបដិវត្តន៍ដំបូង នារីៗចូលធ្វើជាពេទ្យ ចំណែកប្រុសៗចូលធ្វើយោធា។ បន្ទាប់ពីប្អូនរបស់ខ្ញុំចូលបដិវត្តន៍បានរយៈពេល១ឆ្នាំ សុខ ប៊ិតចំរើន បាននាំប្អូនខ្ញុំនិងអ្នកភូមិ១១នាក់ទៀតត្រឡប់មកលេងស្រុកកំណើត និងជ្រើសរើសអ្នកភូមិចូលធ្វើបដិវត្តន៍បន្ថែមទៀត។ នៅពេលដែលប្អូនរបស់ខ្ញុំឈ្មោះ យ៉ុង ត្រឡប់ទៅវិញក៏បាននាំប្អូនពៅភ្លោះ២នាក់គឺប្អូនស្រី ហ៊ឹម យឿន និងប្អូនប្រុស ហ៊ឹម សាវ៉ន ទៅជាមួយដែរ។ នៅក្នុងរបបខ្មែរក្រហម បងប្អូនរបស់ខ្ញុំចំនួន៤នាក់គឺ ទី១) ឈ្មោះ ហ៊ឹម យ៉ុង ទី២) ហ៊ឹម យឿន ទី៣) ហ៊ឹម សាវ៉ន និងទី៤) បងប្រុស ហ៊ឹម សារឿន បានចូលរួមជាមួយបដិវត្តន៍។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមបានទទួលជ័យជម្នះទៅលើរបប លន់ នល់ ទាំងស្រុង។ បន្ទាប់ពីទទួលបានជ័យជម្នះ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យធ្វើជាតំណាងសមាគមនារីដើម្បីដឹកនាំក្រុមនារីធ្វើការងារ ដូចជាធ្វើស្រែសាមគ្គី (ក្រុមប្រវាស់ដៃ) និងដាំបន្លែដើម្បីទុកហូបតាមផ្ទះ។ អំឡុង

ពេលនោះមានប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញជាច្រើនគ្រួសារចូលមករស់នៅជាមួយប្រជាជនក្នុងភូមិអង្គរស។ ប្រជាជនជម្លៀសទាំងនោះធ្វើការងារ និងទទួលរបបអាហារដូចប្រជាជនក្នុងភូមិដែរ។ ចំណែកឯបងសារឿន បន្ទាប់ពីកងទ័ពខ្មែរក្រហមទទួលបានជោគជ័យ គាត់បានត្រឡប់មកផ្ទះវិញដែលពេលនោះខ្ញុំឃើញជើងរបស់គាត់ពិការដោយសារត្រូវគ្រាប់អំឡុងពេលសង្គ្រាម។ បងសារឿនបានឡើងតួនាទីគ្រប់គ្រងយោធានៅស្រុកមេសាង ជំនួស តាជ្រោង និងតាគល់។ គ្រួសាររបស់ខ្ញុំនៅពេលនោះ មិនសូវលំបាកប៉ុន្មានទេ ព្រោះមានបងប្អូនចូលធ្វើបដិវត្តន៍។

នៅឆ្នាំ១៩៧៧ បន្ទាប់ពីមានព្រឹត្តិការណ៍ចោទ សោ ភឹម ថាក្បត់ អង្គការបានមកចាប់បង សារឿន យកទៅសម្លាប់ចោល ប៉ុន្តែខ្ញុំមិនបានដឹងថាយកគាត់ទៅសម្លាប់នៅទីណាឡើយ។ ចំណែកប្រពន្ធរបស់បង សារឿន ឈ្មោះ ជី នង និងកូនចំនួន៣នាក់ទៀតអង្គការបានបញ្ជូនទៅកាន់ខេត្តពោធិ៍សាត់ និងបាត់ដំបង ហើយបាត់ដំណឹងតាំងពីពេលនោះមក។ ចំណែកឪពុកម្តាយ បងប្អូន និងក្រុមគ្រួសាររបស់ខ្ញុំ ក៏អង្គការបញ្ជូនទៅតំបន់ដីខ្លាញ់នៅខេត្តពោធិ៍សាត់ដែរ។ អង្គការបានប្រាប់គ្រួសាររបស់ខ្ញុំថា នៅទីនោះមានអាហារហូបគ្រប់គ្រាន់ ហើយការរស់នៅងាយស្រួលជាងនៅភូមិអង្គរស ប៉ុន្តែការពិតគឺធ្វើការងារលំបាកជាងមុន ហើយការហូបចុកកាន់តែតិចទៅៗ។

ខ្ញុំនិងក្រុមគ្រួសារបានទៅរស់នៅសហករណ៍ចាហ៊្វួយ ស្ថិតនៅក្នុងភូមិបឹងដុង ឃុំស្វាយដូនកែវ ស្រុកបាកាន ខេត្តពោធិ៍សាត់។ ការងាររបស់ខ្ញុំគឺដើររើសគួរស្រូវ និងលើកប្រព័ន្ធភ្លឺស្រែ។ នៅទីនោះខ្ញុំបានជួបប្អូនស្រីឈ្មោះ ហ៊ឹម យឿន ហើយបម្រុងនាំនាងមកជួបឪពុករបស់ខ្ញុំវិញ ប៉ុន្តែប្អូន យឿន ប្រាប់ខ្ញុំថា រវល់ការងារមិនបានមកជាមួយខ្ញុំទេ។ ឪពុករបស់ខ្ញុំខកបំណងយ៉ាងខ្លាំងព្រោះមិនបានជួបកូនស្រីពៅរបស់គាត់ ធ្វើឲ្យគាត់ធ្លាក់ខ្លួនឈឺ ហើយក្រោយមកក៏ស្លាប់។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំនិងក្រុមគ្រួសារបានវិលត្រឡប់មករស់នៅស្រុកកំណើតវិញ ហើយចាប់ផ្តើមធ្វើស្រែចិញ្ចឹមជីវិតបន្ត។ រយៈពេលពីរឆ្នាំក្រោយមក ម្តាយរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺហើយស្លាប់ ចំណែកប្អូនរបស់ខ្ញុំទាំងអស់ដែលចូលរួមជាមួយខ្មែរក្រហមក៏ស្លាប់និងបាត់ខ្លួនទៀត។ ទោះបីយ៉ាងណាខ្ញុំនៅតែមានសេចក្តីសង្ឃឹមថាប្អូនរបស់ខ្ញុំនៅរស់រានមានជីវិតនៅឡើយ។




ប្រវត្តិរូប ហ៊ឹម យ៉ុង ពេលចូលរួមជាមួយបដិវត្តន៍។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

*រូបក្របមុខ៖*

*សូ វណ្ណា ហៅ សោ ភឹម ( ឈរនៅកណ្តាលក្នុងសម្លៀកបំពាក់ពណ៌ខ្មៅ ) និងកងទ័ពខ្មែរក្រហមធ្វើដំណើរទៅទស្សនកិច្ចកងកម្លាំងប្រយុទ្ធស្ម័គ្រចិត្តកុម្មុយនីស្តរបស់វៀតណាម ក្នុងឆ្នាំ១៩៧៣។ រូបថតនេះត្រូវបានថតភ្លាមៗបន្ទាប់ពីកងខ្ទាមដែលជាសម្ព័ន្ធមិត្តចាប់ផ្តើមធ្វើការវាយប្រហារទៅលើមូលដ្ឋានទ័ព ឃុំក្រចៅ ក្នុងខេត្តកំពង់ចាម ដែលជាផ្នែកមួយនៃសង្គ្រាមស៊ីវិលប្រឆាំងនឹងរដ្ឋាភិបាលនៃរបបសាធារណរដ្ឋខ្មែរដឹកនាំដោយលោកសេនាប្រមុខ លន់ នល់។ ក្រោយមក សោ ភឹម បានក្លាយទៅជាលេខាបក្សកុម្មុយនីស្តកម្ពុជាប្រចាំភូមិភាគបូព៌ានៃកម្ពុជាប្រជាធិបតេយ្យ។ សោ ភឹម បានធ្វើអត្តឃាតនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៧៨។*

*( បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា/ភ្នាក់ងារសារព័ត៌មានវៀតណាម )*

*រូបក្របក្រោយ៖*

*សូ វណ្ណា ហៅ សោ ភឹម (រូបទីមួយ រាប់ពីឆ្វេង ក្នុងសម្លៀកបំពាក់ពណ៌ខ្មៅ ) និងកងទ័ពខ្មែរក្រហមធ្វើដំណើរទៅទស្សនកិច្ចកងកម្លាំងប្រយុទ្ធស្ម័គ្រចិត្តកុម្មុយនីស្តរបស់វៀតណាម ក្នុងឆ្នាំ១៩៧៣។ រូបថតនេះត្រូវបានថតភ្លាមៗ បន្ទាប់ពីកងខ្ទាមដែលជាសម្ព័ន្ធមិត្តចាប់ផ្តើមធ្វើការវាយប្រហារទៅលើមូលដ្ឋានទ័ព ឃុំក្រចៅ ខេត្តកំពង់ចាម ដែលជាផ្នែកមួយនៃសង្គ្រាមស៊ីវិលប្រឆាំងនឹងរដ្ឋាភិបាលនៃរបបសាធារណរដ្ឋខ្មែរដឹកនាំដោយលោកសេនាប្រមុខ លន់ នល់។ ក្រោយមក សោ ភឹម បានក្លាយទៅជាលេខាបក្សកុម្មុយនីស្តកម្ពុជាប្រចាំភូមិភាគបូព៌ានៃកម្ពុជាប្រជាធិបតេយ្យ។ សោ ភឹម បានធ្វើអត្តឃាតនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៩៧៨។*

*( បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា/ភ្នាក់ងារសារព័ត៌មានវៀតណាម )*




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ១២ ៨៨២ ៥០៥*

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 1110

Tel: (855) 12 882 505 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Special Issue 2024 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.